ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា ( នីតិកាលទី៣ )
គណៈកម្មការនីតិកម្ម និងយុត្តិធម៌

# ឯកសារជំនួយស្មារតី
# ស្តីពី
# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
# នៅថ្នាក់ខេត្ត

(ខែមីនា ឆ្នាំ២០១៧)

រៀបចំ និងចងក្រងដោយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា និងលេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

# អារម្ភកថា

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា តែងមានកម្មវិធីជាប្រចាំចុះបំពេញបេសកកម្ម ការងារតាមបណ្តាមូលដ្ឋាន ដើម្បីធ្វើការសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ទាំងឡាយដែលបានចូលជាធរមានជាពិសេសអំពីពល់បញ្ហាដែលទាក់ទងនិងវិស័យជាសមត្ថកិច្ចរបស់ខ្លួន។

យើងសង្កេតឃើញថាក្នុងចំណោមប្រជាជនយើងដែលភាគច្រើនជាអ្នករស់នៅទីជនបទជារឿយៗតែងតែកើតមាននូវជម្លោះដែលភាគច្រើនជាជម្លោះរវាងបុគ្គល និងបុគ្គលក្នុងរង្វង់គ្រួសារ និងជម្លោះគ្រួសារមួយ និងគ្រួសារផ្សេងទៀត។ បញ្ហាអំពើហិង្សាក្នុងគ្រួសារ ហិង្សាលើស្ត្រី បញ្ហាដីធ្លី រឿងកិច្ចសន្យា និងរឿងព្រហ្មទណ្ឌតូចតាចតែងកើតមានឡើងច្រើនជាងគេក្នុងចំណោមជម្លោះទាំងឡាយ។

ម៉្យាងវិញទៀត ស្ថាប័នតុលាការ នៅមិនទាន់អាចដោះស្រាយគ្រប់ជម្លោះដែលបានកើតឡើងទាំងអស់នោះទេ។ប្រជាជននៅជនបទយល់ឃើញថាការធ្វើដំណើរទៅតុលាការមានចម្ងាយឆ្ងាយគាត់ត្រូវការចំណាយថវិកាច្រើនហើយម៉្យាងទៀតនៅតុលាការក៏មានសំណុំរឿងច្រើនផងដែរ។

រយៈកាលកន្លងមករាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើន : ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋឆ្នាំ១៩៩៩ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ២០០២ហើយគណៈរដ្ឋមន្ត្រី ក៏បានធ្វើការអនុម័តទៅលើយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការនៅក្នុងឆ្នាំ២០០៣ និងផែនការសកម្មភាពក្នុងឆ្នាំ២០០៥។

គោលបំណងនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ និងតុលាការគឺជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុភាព និងស្ថិរភាពច្បាប់ និងយុត្តិធម៌ប្រកាន់ខ្ជាប់នូវគោលការណ៍សិទ្ធិបុគ្គលនីតិរដ្ឋ និងភាពចែកដាច់ពីគ្នានៃអំណាចក្នុងប្រព័ន្ធប្រជាធិបតេយ្យ។ ដើម្បីទទួលបាននូវភាពជោគជ័យ ក្នុងការអនុវត្តគោលបំណងនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវគោលដៅយុទ្ធសាស្ត្រប្រាំពីរចំណុចដែលក្នុងនោះគឺគោលដៅទីប្រាំមួយបានណែនាំនូវយុទ្ធសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ចំណែកឯផែនការសកម្មភាពដែលមានគោលបំណង

បង្កើតស៊ើបអង្កេត និងពង្រឹងនូវវិធីសាស្ត្រផ្សេងៗនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានយកចិត្តទុកដាក់ជាពិសេសតាំងពីនៅថ្នាក់ ឃុំ ស្រុក ខេត្ត រហូតដល់ថ្នាក់ជាតិ ។

គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា រៀបរៀងឯកសារជំនួយស្មារតីនេះឡើងដែលបានដកស្រង់នូវខ្លឹមសារសំខាន់ៗពីបទដ្ឋានគិតយុត្តមួយចំនួនដែលបានចូលជាធរមានសម្រាប់ដល់ការស្រាវជ្រាវ និងប្រើប្រាស់របស់អាជ្ញាធរដែលមានសមត្ថកិច្ចៗវាអាចបានរួមចំណែកជាសំខាន់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាពិសេសគឺ គណៈកម្មការផ្សះផ្សាទំនាស់ឃុំ សង្កាត់ មណ្ឌលសេវាកម្មយុត្តិធម៌ និងគណៈកម្មការសុរិយោដីក្រុង ស្រុក ខ័ណ្ឌ ក្នុងដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការកាន់តែទទួលបាននូវជោគជ័យ និងបានរួមចំណែកពង្រឹងប្រព័ន្ធយុត្តិធម៌សង្គមនៅកម្ពុជាយើងៗ

# មាតិកា

I-អំពីការិយាល័យប្រជាពលរដ្ឋ....................................................................០៦
II-អំពីការដោះស្រាយវិវាទនៅមូលដ្ឋាន........................................................២១
III-គណៈកម្មការសុរិយោដី.......................................................................២៣
IV-អំពីមាត្រាមួយចំនួននៃច្បាប់ និងប្រការទាំងឡាយនៃលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយទំនាស់នៅស្រុក ក្រុង បញ្ជូនមកខេត្ត ដែលគួរយល់ដឹង
+.អំពីកម្មសិទ្ធិ.......................................................................................៤៤
+.អំពីបរិហាកេរ្តិ៍ជាសាធារណៈឬជេរប្រមាថ.......................................................៤៨
+.អំពីការជំពាក់ប្រាក់និងកិច្ចសន្យា..............................................................៤៩
+.អំពីការផ្តាច់ពាក្យរៀបការ.........................................................................៥៧
+.អំពីទ្រព្យសម្បត្តិ....................................................................................៥៨
+.អំពីការបង្កការខូចខាតទ្រព្យសម្បត្តិ...........................................................៦១
+.អំពីការបង្ករបួសស្នាមតូចតាច...................................................................៦២
+.អំពីអំពើហិង្សាក្នុងគ្រួសារ..........................................................................៦២
V-នគរបាលយុត្តិធម៌....................................................................................៦៦
១-មន្ត្រីនគរបាលយុត្តិធម៌.............................................................................៦៦
២-ភ្នាក់ងារនគរបាលយុត្តិធម៌..........................................................................៧០
៣-មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀត មាននីតិសម្បទាពិសេសដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើស..៧២
+.*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*.....................................................៧៣
++*ច្បាប់ស្តីពីព្រៃឈើ*..............................................................................៧៣
-*មន្ត្រីរដ្ឋបាលព្រៃឈើទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌*.......៧៣
-*ជំពូកទី១៤ នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ*..........................៧៣
++*ច្បាប់ស្តីពីជលផល*................................................................................៧៩
-*មន្ត្រីរដ្ឋបាលជលផលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌*........៧៩
-*ជំពូកទី១៤ នីតិវិធីដោះស្រាយបទល្មើសជលផល*...........................៧៩
++*ច្បាប់ស្តីពីសហគមន៍កសិកម្ម*...................................................................៨៥
-*ជំពូកទី៦ ការតាមដាននិងការដោះស្រាយវិវាទ*...............................៨៥

+ក្រសួងបរិស្ថាន.......................................................................................៨៦
++ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ..........................................................................៨៦
-មន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិទទួលនីតិសម្បទាជាមន្ត្រីនគរបាល យុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌........................................៨៦
-ជំពូកទី៩ ការអនុវត្តច្បាប់ និងនីតិវិធីដោះស្រាយបទល្មើស.........៨៦
+ក្រសួងហិរញ្ញវត្ថុ.......................................................................................៩០
++ច្បាប់ស្ដីពីគយ.......................................................................................៩០
-មន្ត្រីគយទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌.............៩០
++ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ
++ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ..........................................................៩៩
-ជំពូកទី១០ ការដោះស្រាយវិវាទ និងបណ្ដឹងតវ៉ា..........................៩៩
++អនុក្រឹត្យស្ដីពីលទ្ធកម្មសាធារណៈ..................................................១០០
-ជំពូកទី៨ ការប្ដឹងតវ៉ា និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម...............១០០
++ច្បាប់ស្ដីពីការធានារ៉ាប់រង...................................................................១០១
-ជំពូកទី៩ ការផ្សះផ្សាវិវាទ.......................................................................១០១
+ក្រសួងកិច្ចការនារី..................................................................................១០២
++ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ
-មន្ត្រីនៃក្រសួងកិច្ចការនារីទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌...១០២
+ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍...................................................១០៥
++ច្បាប់ស្ដីពីទូរគមនាគមន៍........................................................................១០៥
-មន្ត្រីអធិការកិច្ចទូរគមនាគមន៍ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌......១០៥
-ជំពូកទី១២ ការដោះស្រាយវិវាទនៃច្បាប់ស្ដីពីទូរគមនាគមន៍........១១១
+ក្រសួងទេសចរណ៍.......................................................................................១១១
++ច្បាប់ស្ដីពីទេសចរណ៍.......................................................................................១១១
-មន្ត្រីអធិការកិច្ចទេសចរណ៍ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌...... ១១១
-ជំពូកទី៧ ការដោះស្រាយវិវាទទេសចរណ៍.............................១១២

+អង្គភាពប្រឆាំងអំពើពុករលួយ..........១១៣
++ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ..........១១៣
-មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌..........១១៣
+ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ..........១១៧
++ច្បាប់ស្តីពីការងារ..........១១៧
-ជំពូកទី១២ ការដោះស្រាយវិវាទការងារ..........១១៧
+ក្រសួងមុខងារសាធារណៈ..........១២១
++ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ..........១២១
-ជំពូកទី១៧ អំពីការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ..........១២១
+ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់..........១២៣
++ច្បាប់ស្តីពីអសុរាមិករណ៍..........១២៣
-ជំពូកទី៦ ការដោះស្រាយទំនាស់..........១២៣
+សហជីព..........១២៤
++ច្បាប់ស្តីពីសហជីព..........១២៤
-ជំពូកទី១៤ ការដោះស្រាយវិវាទរបស់សហជីពឬសមាគមនិយោជក.....១២៤
+សមាគមននិងអង្គការមិនមែនរដ្ឋាភិបាល..........១២៩
++ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល..........១២៩
VI-**គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព**..........១៣៣

I-**អំពីការិយាល័យប្រជាពលរដ្ឋ៖**

**+អនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧**

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

-**មាត្រា១**( *នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បកចុះថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០១៧)បានចែងថា: អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹងតួនាទីការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពសំដៅបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។*

-**មាត្រា២**( *នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : អនុក្រឹត្យនេះមានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅថ្នាក់ក្រោមជាតិ។*

-**មាត្រា៣**( *នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា :* ***អនុក្រឹត្យនេះមានវិសាលភាពអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងដែលពាក់ព័ន្ធការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។***

*អនុក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះវិវាទនៅមូលដ្ឋាន និងវិវាទដែលច្បាប់ ឬដែលរាជរដ្ឋាភិបាលបានកំណត់ឲ្យស្ថាប័ន ឬយន្តការដាក់លាក់ណាមួយសម្រុះសម្រួលដោះស្រាយទេ។*

**មាត្រា៤**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

-បណ្តឹងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ សំដៅដល់ការតវ៉ា ឬការទាមទារ ឬការមិនពេញចិត្តដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ទីរ អង្គភាពជំនាញ ព្រមទាំងភ្នាក់ងារទទួលសមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

-ការសម្រុះសម្រួលដោះស្រាយបណ្តឹង សំដៅដល់ដំណើរការនៃការស្វែងរកដំណោះស្រាយមួយសមស្របដោយអនុលោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

-ការស៊ើបអង្កេត សំដៅដល់ដំណើរការស្រាវជ្រាវ ស្វែងរកភស្តុតាងដើម្បីបញ្ជាក់ការពិត ឬមិនពិត ចំពោះអង្គហេតុដូចមាននៅក្នុងពាក្យបណ្តឹង។

-វិវាទនៅមូលដ្ឋាន សំដៅដល់វិវាទមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នា ឬដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា។

-ភ្នាក់ងារទទួលសមត្ថកិច្ច សំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលទទួលការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។

## ជំពូកទី២
## ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
### ផ្នែកទី១
### រចនាសម្ព័ន្ធ តួនាទី ភារកិច្ច សមត្ថកិច្ច និងសិទ្ធិអំណាច

-**មាត្រា៥**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ត្រូវបង្កើតឲ្យមានយន្តការអព្យាក្រឹតមួយសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលមានឈ្មោះថា "ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត"។

-**មាត្រា៦**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា: ការិយាលប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងមានអនុប្រធានមួយ (១)រូប ជាជំនួយការ។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយ គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដូចដែលបានកំណត់នៅក្នុងផ្នែកទី៣ ជំពូកទី២ នៃអនុក្រឹត្យនេះ។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់អភិបាលរាជធានី ខេត្តសាមី ផ្អែកតាមលទ្ធផលរបស់គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលបានទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ មិនអាចកាន់មុខតំណែងផ្សេងទៀតក្នុងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រកបមុខរបរវិជ្ជាជីវៈណាមួយ ឬមុខរបរផ្សេងទៀតដែលមានទំនាស់ផលប្រយោជន៍នឹងមុខងាររបស់ខ្លួនឡើយ។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានអាណត្តិការងារប្រាំ (៥) ឆ្នាំ។

នៅពេលចប់អាណត្តិ ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជាថ្មីទៀតបាន ដោយផ្អែកទៅតាមលក្ខខណ្ឌ និងលក្ខណសម្បត្តិដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ។

**មាត្រា៧**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានពីរផ្នែកចំណុះដូចខាងក្រោម ៖

-ផ្នែកទទួលពាក្យបណ្តឹង និងកិច្ចការរដ្ឋបាល

-ផ្នែកច្បាប់ និងស៊ើបអង្កេត

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(២)រូប ព្រមទាំងបុគ្គលិកមួយចំនួន។ ប្រធាន អនុប្រធានផ្នែកត្រូវជ្រើសរើសចេញពីក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលដែលមានលក្ខណសម្បត្តិ សមត្ថភាព ជំនាញ និងបទពិសោធការងារសមស្រប។

ប្រធានផ្នែកមានឋានៈស្មើនឹងនាយកទីចាត់ការសាលារាជធានី ខេត្ត។ អនុប្រធានផ្នែកមានឋានៈស្មើនឹងនាយករងទីចាត់ការសាលារាជធានី ខេត្ត។

ប្រធាន អនុប្រធានផ្នែកត្រូវបានតែងតាំងដោយដីការបស់រដ្ឋបាលរាជធានី ខេត្ត តាមសំណើរបស់ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

បុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អាចជ្រើសរើសចេញពីក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬមន្ត្រីជាប់កិច្ចសន្យា។

-**មាត្រា៨**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

-ប្រមូល និងទទួលពាក្យបណ្តឹងនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-សម្រាំង និងវាយតម្លៃពាក្យបណ្តឹងដែលទទួលបាន

-បញ្ជូនពាក្យបណ្តឹងទាំងឡាយណាដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងតាមដានការដោះស្រាយ ដើម្បីជូនព័ត៌មានទៅ ម្ចាស់ពាក្យបណ្តឹង

-ចាត់វិធានការស៊ើបអង្កេតបណ្តឹងរដ្ឋបាល លើកអនុសាសន៍អំពីវិធានការដោះស្រាយបណ្តឹង និងតាមដានការអនុវត្តវិធានការដោះស្រាយបណ្តឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-ផ្តល់ព័ត៌មានត្រឡប់ដល់ប្រជាពលរដ្ឋអំពីលទ្ធផលនៃការដោះស្រាយបណ្តឹង

-ផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-រៀបចំយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងដំណើរការទទួលនិងសម្រុះសម្រួល ដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ខ្លួន

-រាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងារនិងការដោះស្រាយបណ្តឹង។

-**មាត្រា៩**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា :ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានសមត្ថកិច្ចស៊ើបអង្កេត រាយការណ៍ និងផ្តល់អនុសាសន៍ទៅលើបណ្តឹងរដ្ឋបាលដែលស្ថិតក្នុងដែនសមត្ថកិច្ចពាក់ព័ន្ធនឹង ៖

-សេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត ដែលផ្ទុយនឹងគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬដែលប៉ះពាល់ដល់ផលប្រយោជន៍របស់បុគ្គល ឬសហគមន៍

-ការបំពេញការងារ និងអាកប្បកិរិយារបស់បុគ្គលិកក្រុមប្រឹក្សារាជធានី ខេត្ត បុគ្គលិកមន្ទីរអង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត និងភ្នាក់ងារទទួលសមត្ថកិច្ច

-ការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពជំនាញនៅថ្នាក់រាជធានី ខេត្ត

-ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត មន្ទីរអង្គភាពជំនាញ និងរបស់ភ្នាក់ងារទទួលសមត្ថកិច្ច។

-**មាត្រា១០**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា: ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានសិទ្ធិអំណាចដូចខាងក្រោម៖

-ប្រើប្រាស់បុគ្គលិក ថវិកា សម្ភារៈ និងមធ្យោបាយនានារបស់អង្គភាពខ្លួនសម្រាប់អនុវត្តសកម្មភាពផ្អែកតាមផែនការសកម្មភាព និងថវិការបស់ខ្លួនដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា

-ស៊ើបអង្កេតបណ្តឹងដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ព្រមទាំងលើកអនុសាសន៍អំពីវិធានការដោះស្រាយ ប៉ុន្តែពុំមានសិទ្ធិចេញសេចក្តីសម្រេចដើម្បីចាត់វិធានការដោះស្រាយ ឬដាក់ទណ្ឌកម្មឡើយ

-ស្នើសុំកិច្ចសហការ ឬការចូលរួមពីបុគ្គលិកនៃអង្គភាពនានានៃរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរអង្គភាពជំនាញនានាតាមការចាំបាច់

-កោះអញ្ជើញបុគ្គល ឬប្រធានអង្គភាពដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងឲ្យចូលមកបំភ្លឺតាមការចាំបាច់

-ពិនិត្យមើលឯកសារ និងវត្ថុតាងផ្សេងៗដែលពាក់ព័ន្ធនឹងបណ្តឹងនៅតាមអង្គភាពពាក់ព័ន្ធនានា ដោយពុំចាំបាច់ជូនដំណឹងជាមុន និងអាចដកហូតយកឯកសារនិងវត្ថុតាងទាំងនោះមករក្សាទុកជាបណ្តោះអាសន្នតាមការចាំបាច់

-រាយការណ៍ជូនអភិបាលរាជធានី ខេត្ត អំពីការមិនសហការក្នុងការស៊ើបអង្កេតរបស់ប្រធានអង្គភាពនិងឬបុគ្គលដែលពាក់ព័ន្ធបណ្តឹង និងការមិនចាត់វិធានការដោះស្រាយ ឬការចាត់វិធានការដោះស្រាយមិនសមស្របរបស់ប្រធានអង្គភាពចំពោះពាក្យបណ្តឹងនានាដែលពាក់ព័ន្ធនឹងអង្គភាពនោះ។ ក្នុងករណីដែលអភិបាលរាជធានី ខេត្ត មិនបានចាត់វិធានការដោះស្រាយឲ្យបានសមស្របប្រធានការិយាល័យប្រជាពលរដ្ឋអាចរាយការណ៍ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីដោះស្រាយ និងអាចរាយការណ៍ជូនក្រសួងមហាផ្ទៃ ដើម្បីសម្របសម្រួលដោះស្រាយប្រសិនបើក្រុមប្រឹក្សាមិនអាចដោះស្រាយបាន។

## ផ្នែកទី២

## លក្ខខណ្ឌ និងលក្ខណសម្បត្តិបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោតជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងការបាត់បង់មុខតំណែង

**មាត្រា១១**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវដាក់ពាក្យសុំមកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្តនៅក្នុងការដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

បេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចខាងក្រោម៖

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុចាប់ពី៣៥ឆ្នាំទៅ៦៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត

-សញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬ រដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយទំនាស់

-មានបទពិសោធក្នុងការងារពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬរដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយទំនាស់យ៉ាងតិច៣ឆ្នាំ

-ជាបុគ្គលស្អាតស្អំ មានកេរ្តិ៍ឈ្មោះល្អ មានការគោរពរាប់អានពីសហគមន៍របស់ខ្លួន

-មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរាជធានី ខេត្ត ដែលសាមីជនមានបំណងឈរឈ្មោះ។

នីតិវិធី និងបែបបទនៃការដាក់ពាក្យសុំ និងការសម្រាំងបេក្ខជនដែលមានលក្ខខណ្ឌ និងមានលក្ខណសម្បត្តិសមស្រប ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

-**មាត្រា១២**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ៖

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ

-សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ព្រះសង្ឃ ឬបុព្វជិតសាសនា

-ជនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ហើយមិនមាននីតិសម្បទាឡើងវិញ

-ជនដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សនយោបាយណាមួយ។

-**មាត្រា១៣** (នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម៖

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ ហើយ មិនមាននីតិសម្បទាឡើងវិញ

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ

-សាមីខ្លួនសុំលាឈប់ដោយធ្វើលិខិតជាលាយលក្ខណ៍អក្សរ

-សាមីខ្លួនបោះបង់ចោលការងារ

-សាមីខ្លួនត្រូវបានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត សម្រេចដកចេញពីមុខតំណែង។

## ផ្នែកទី៣
## គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-**<u>មាត្រា១៤</u>**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានសមាសភាពដូចខាងក្រោម៖

ក.ចំពោះរដ្ឋបាលខេត្ត ដែលមានសមាជិកក្រុមប្រឹក្សារបស់ខ្លួនតិចជាង ឬស្មើ ១៥រូប ៖

| | |
|---|---|
| -ប្រធានក្រុមប្រឹក្សាខេត្ត | ប្រធាន |
| -សមាជិកក្រុមប្រឹក្សាខេត្តទាំងអស់ | សមាជិក |
| -ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់១រូប | សមាជិក |
| -តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត៣រូប | សមាជិក |
| -តំណាងអង្គការសង្គមស៊ីវិល៣រូប | សមាជិក |

ខ.ចំពោះរដ្ឋបាលរាជធានី ខេត្តដែលមានសមាជិកក្រុមប្រឹក្សារបស់ខ្លួនច្រើនជាង១៥រូប៖

| | |
|---|---|
| -ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ប្រធាន |
| -សមាជិកក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ | សមាជិក |

-ប្រធានសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់ ឬប្រធានសមាគមក្រុមប្រឹក្សា

ក្រុង ស្រុក ឃុំ សង្កាត់១រូប សមាជិក

-តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត៧រូប សមាជិក

-តំណាងអង្គការសង្គមស៊ីវិល៧រូប សមាជិក

ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើជាសេនាធិការឲ្យគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវដាក់ចេញនូវសេចក្តីសម្រេចបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

នីតិវិធីជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាសមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

-**មាត្រា១៥**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោមៈ

-សម្រាំងបេក្ខជនសម្រាប់ឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-រៀបចំ និងបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-រៀបចំ និងបោះឆ្នោតអនុម័តទៅលើសំណើសុំដកហូតមុខតំណែងប្រធាន អនុប្រធាន ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត តាមសំណើរបស់សមាជិក១ភាគ៣នៃក្រុមប្រឹក្សារាជធានី ខេត្តសាមី ឬសមាជិក១ភាគ៣នៃគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

នីតិវិធី និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

-**មាត្រា១៦**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា :នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

## ផ្នែកទី៤
## ទីកន្លែងធ្វើការបុគ្គលិកនិងរបៀបរបបធ្វើការងារ

-**មាត្រា១៧** (នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ទីកន្លែងធ្វើការរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវស្ថិតនៅទីតាំងណាមួយសមស្របដែលប្រជាពលរដ្ឋមានជំនឿទុកចិត្ត និងមានលក្ខណៈងាយស្រួល ក្នុងការធ្វើទំនាក់ទំនង ការផ្តល់ព័ត៌មាន និងការដាក់ពាក្យបណ្តឹង។

រដ្ឋបាលរាជធានី ខេត្ត ត្រូវធានាឲ្យមានទីកន្លែងសមស្របសម្រាប់ការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តសាមី។

-**មាត្រា១៨**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : រដ្ឋបាលរាជធានី ខេត្ត ត្រូវធានាឲ្យមានបុគ្គលិកចំនួនសមស្របសម្រាប់បំពេញការងារប្រចាំថ្ងៃនៅការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវចាត់ចែងឲ្យមានបុគ្គលិកប្រចាំការ ព្រមទាំងកំណត់លក្ខខណ្ឌការងារ និងក្រមសីលធម៌ឲ្យបានច្បាស់លាស់ ដើម្បីធានាបាននូវការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយគណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

ប្រធាន អនុប្រធាន និងបុគ្គលិកនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវបំពេញការងារទៅតាមពេលវេលានៃម៉ោងធ្វើការរបស់មន្ត្រីរាជការស៊ីវិល ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។

ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវចាត់ឲ្យមានបុគ្គលិកជាតំណាងរបស់ខ្លួនទៅបំពេញការងារយ៉ាងតិចដប់ពីរ (១២) ម៉ោងក្នុងមួយសប្តាហ៍នៅក្នុងការិយាល័យ ច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

-**មាត្រា១៩**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវលើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់មុខតំណែង ដំឡើងឋានន្តរសក្តិ ថ្នាក់ លើកសរសើរ និងដាក់វិន័យបុគ្គលិក ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ គណៈអភិបាលរាជធានី ខេត្ត ត្រូវផ្តល់ការឯកភាពលើសំណើដែលបានស្នើឡើងស្របតាមគោលការណ៍

នីតិវិធី លក្ខណសម្បត្តិ និងឧបនិស្ស័យដែលបានកំណត់ដោយលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រាល់ការផ្លាស់ប្តូរ ការបញ្ចប់មុខតំណែង និងការដាក់វិន័យចំពោះបុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានការឯកភាពពីប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត សាមី។

ក្នុងករណីពុំមានការឯកភាពគ្នារវាងគណៈអភិបាលនិងប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អភិបាលរាជធានី ខេត្ត ឬប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវដាក់សំណើនេះជូនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងសម្រេច។

-**មាត្រា២០**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារាជធានី ខេត្តសាមី។

អនុប្រធាន និងបុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានគណនេយ្យភាពចំពោះប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត របស់ខ្លួន។

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរៀបចំ និងដាក់ជូនរបាយការណ៍ជាទៀតទាត់ជូនក្រុមប្រឹក្សារាជធានី ខេត្តសាមី និងចម្លងជូនក្រសួងមហាផ្ទៃជាទៀងទាត់តាមការកំណត់។

-**មាត្រា២១**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : របៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## គោលការណ៍ និងនីតិវិធីនៃការទទួល ការស៊ើបអង្កេត និង ការសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

-**មាត្រា២២** ( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ការទទួល ការស៊ើបអង្កេត និងការសម្រុះសម្រួលដោះស្រាយបណ្តឹងត្រូវធ្វើឡើង ដោយអញ្ញាក្រឹត តម្លាភាព យុត្តិធម៌ និងរក្សាការសម្ងាត់។

ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិដាក់ពាក្យបណ្ដឹងដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត មកការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដោយពុំមានបង់ថ្លៃសេវាឡើយ។

**-មាត្រា២៣**( នៃអនុក្រឹត្យស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាបេ លេខៈ១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រជាពលរដ្ឋគ្រប់រូបត្រូវបានលើកទឹកចិត្តក្នុងការផ្ដល់ព័ត៌មានកស្តុតាងនានា និងការធ្វើជាសាក្សីព្រមទាំងការទទួលបាននូវកិច្ចការពារឲ្យផុតពីការគំរាមកំហែង និងការសងសឹកណាមួយ។

**-មាត្រា២៤**( នៃអនុក្រឹត្យស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា: ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានទីកន្លែងសមស្រប និងបុគ្គលិកប្រចាំការសម្រាប់ទទួលពាក្យបណ្ដឹងនៅគ្រប់ម៉ោងធ្វើការរបស់រាជរដ្ឋាភិបាល ព្រមទាំងរៀបចំមធ្យោបាយសមស្របផ្សេងៗទៀតសម្រាប់ទទួលពាក្យបណ្ដឹង។

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីទីកន្លែង ម៉ោងធ្វើការងារ និងអំពីមធ្យោបាយទទួលពាក្យបណ្ដឹង។

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរៀបចំទុកដាក់ និងថែរក្សាពាក្យបណ្ដឹង ដែលទទួលបាននៅការិយាល័យធ្វើការងាររបស់ខ្លួនឲ្យបានគង់វង្ស។

**-មាត្រា២៥**( នៃអនុក្រឹត្យស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខៈ១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវសម្រាំងពាក្យបណ្ដឹងដែលទទួលបាន និងចាត់វិធានការស៊ើបអង្កេតចំពោះពាក្យបណ្ដឹងដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមនីតិវិធីកំណត់។ ចំពោះពាក្យបណ្ដឹងដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវបញ្ជូនពាក្យបណ្ដឹងទាំងនោះទៅអង្គភាពពាក់ព័ន្ធដើម្បីចាត់វិធានការដោះស្រាយ។

ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវធ្វើការតាមដានលទ្ធផលនៃការដោះស្រាយបណ្តឹង និងផ្តល់ព័ត៌មានត្រឡប់ដល់ដើមបណ្តឹង ឬប្រជាពលរដ្ឋដែលពាក់ព័ន្ធ។

**-មាត្រា២៦**( នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ក្នុងដំណើរការស៊ើបអង្កេត មន្រ្តីស៊ើបអង្កេតរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានសិទ្ធិអំណាចដូចខាងក្រោម ៖

-ពិនិត្យមើលឯកសារ និងវត្ថុតាងផ្សេងៗ ដែលពាក់ព័ន្ធនឹងបណ្តឹងរដ្ឋបាលនៅតាមអង្គភាពនានាដោយពុំចាំបាច់ជូនដំណឹងជាមុន និងអាចដកហូតយកឯកសារ និងវត្ថុតាងទាំងនោះមករក្សាទុកជាបណ្តោះអាសន្នតាមការចាំបាច់

-កោះអញ្ជើញប្រធានអង្គភាព និងឬមន្រ្តីពាក់ព័ន្ធដើម្បីមកបំភ្លឺ

-ចុះពិនិត្យនិងស្វែងរកភស្តុតាងជាក់ស្តែង និងសម្ភាសជាមួយប្រធានអង្គភាព និងឬមន្រ្តីពាក់ព័ន្ធ

-ពិគ្រោះយោបល់ជាមួយអ្នកច្បាប់ ឬអ្នកជំនាញពាក់ព័ន្ធ

-ស្នើសុំអន្តរាគមន៍ពីអភិបាលរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ក្នុងករណីមានការគំរាមកំហែងដល់មន្រ្តីស៊ើបអង្កេត

-ក្នុងករណីប្រធានអង្គភាព ឬមន្រ្តីពាក់ព័ន្ធមិនសហការ ឬមិនផ្តល់ព័ត៌មានក្នុងការស៊ើបអង្កេត ប្រធានការិយាល័យប្រជាពលរដ្ឋត្រូវស្នើសុំកិច្ចអន្តរាគមន៍ពីអភិបាល រាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ។

ការស៊ើបអង្កេតត្រូវធ្វើឡើងដោយយុត្តិធម៌ រក្សាការសម្ងាត់ អព្យាក្រឹត មិនលំអៀង និងមានលក្ខណៈច្បាស់លាស់។

អ្នកដែលពាក់ព័ន្ធទៅនឹងបណ្តឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការស៊ើបអង្កេតឡើយ។ អ្នកផ្តល់ព័ត៌មាន និងអ្នករៀបចំរបាយការណ៍ស៊ើបអង្កេតត្រូវបានការពារពីបណ្តឹងបរិហារកេរ្តិ៍ លើកលែងតែការផ្តល់ព័ត៌មាន និងរបាយការណ៍ដោយទុច្ចរិត។

**មាត្រា២៧**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រធានអង្គភាពដែលពាក់ព័ន្ធទៅនឹងបណ្តឹងត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ឬរបាយការណ៍ពីប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ការចាត់វិធានការដោះស្រាយ ឬការចាត់វិធានការទណ្ឌកម្មខាងវិន័យត្រូវផ្អែកទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀតឡើយ។

ក្នុងករណីបុគ្គលិករបស់អង្គភាពដែលពាក់ព័ន្ធបណ្តឹងមិនព្រមទទួលយកការអនុវត្តសេចក្តីសម្រេចរបស់ប្រធានអង្គភាពសាមី បុគ្គលិករូបនោះមានសិទ្ធិប្តឹងទៅប្រធានស្ថាប័នតាមឋានានុក្រម ឬប្តឹងទៅតុលាការ។

**មាត្រា២៨**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : នីតិវិធីនៃការទទួល ការស៊ើបអង្កេត និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

## ផ្នែកទី៦
## ថវិកាប្រតិបត្តិការ និងប្រាក់ឧបត្ថម្ភ

**មាត្រា២៩**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : អភិបាលរាជធានី ខេត្ត ត្រូវគ្រោងថវិកាសម្រាប់រ៉ាប់រងកិច្ចប្រតិបត្តិការនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត នៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត សាមីនីមួយៗ។

អភិបាលរាជធានី ខេត្ត ត្រូវធានាថាថវិកានេះនឹងត្រូវបានប្រើប្រាស់ដោយមិនមានភាពស្មុគស្មាញ ឬរាំងស្ទះដល់កិច្ចដំណើរការនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើយ។

**មាត្រា៣០**(នៃអនុក្រឹត្យស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាល លេខ:១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧) បានចែងថា : ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងប្រាក់ឧបត្ថម្ភប្រចាំខែរបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។ អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត។

បុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវទទួលប្រាក់បៀវត្សទៅតាមប្រព័ន្ធប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ឬមន្ត្រីជាប់កិច្ចសន្យា។

ប្រធាន អនុប្រធាន និងបុគ្គលិករបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អាចទទួលប្រាក់ឧបត្ថម្ភបន្ថែម និងអត្ថប្រយោជន៍ផ្សេងៗទៀតទៅតាមលទ្ធភាពធនធាន ដែលមាន។

*** *** ***

## II-អំពីការដោះស្រាយវិវាទនៅមូលដ្ឋាន៖

ការដោះស្រាយវិវាទនៅមូលដ្ឋាន ដូចមានចែងក្នុងមាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩២ មាត្រា៩៣ មាត្រា៩៤ និងមាត្រា៩៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុង ស្រុក ខណ្ឌ

**- ការដោះស្រាយវិវាទនៅមូលដ្ឋាននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត-ក្រុង ស្រុក ខណ្ឌ**

-មាត្រា៨៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ចែងថា: ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

-មាត្រា៩០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា : វិវាទនៅមូលដ្ឋាន គឺជាវិវាទមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នាឬដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា។

-មាត្រា៩១ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខ័ណ្ឌ ចែងថា:

ការដោះស្រាយវិវាទត្រូវផ្អែកតាមពាក្យបណ្តឹងរបស់ភាគីណាមួយ ឬភាគីទាំងសង្ខាងនៅក្នុងវិវាទទៅក្រុមប្រឹក្សាដែលភាគីនោះស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ។

-មាត្រា៩២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា : ក្រុមប្រឹក្សាត្រូវសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋានដោយផ្អែកតាមលក្ខណៈដែលអាចទទួលយកបានដោយភាគីនៅក្នុងវិវាទទាំងសងខាង។

ក្នុងករណីភាគីណាមួយនៅក្នុងវិវាទមិនអាចទទួលយកបាននូវការសម្រុះសម្រួលដោះស្រាយក្រុមប្រឹក្សាត្រូវណែនាំភាគីនោះអំពីនីតិវិធីតាមផ្លូវច្បាប់សម្រាប់បន្តដោះស្រាយវិវាទនោះ។

-មាត្រា៩៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា : ក្នុងករណីមានសំណូមពរឬការតវ៉ានានាពីប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្រុមប្រឹក្សាត្រូវពិនិត្យ និងដោះស្រាយសំណូមពរឬការតវ៉ានោះឲ្យបានសមស្រប។

ក្នុងករណីសំណូមពរឬការតវ៉ានោះស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនក្រុមប្រឹក្សាត្រូវចាត់វិធានការដោះស្រាយរួចហើយត្រូវជូនដំណឹងទៅប្រជាពលរដ្ឋវិញ។

ករណីសំណូមពរឬការតវ៉ានោះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនក្រុមប្រឹក្សាត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬក្រុមប្រឹក្សាដែលពាក់ព័ន្ធដើម្បីដោះស្រាយ។

-<u>មាត្រា៩២</u>នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា:

ក្នុងការសម្រុះសម្រួលដោះស្រាយវិវាទនៅមូលដ្ឋានក្រុមប្រឹក្សាមិនត្រូវធ្វើសេចក្តីសម្រេចទៅលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធករណីដូចខាងក្រោម:

-ការលែងលះ

-អំពើហិង្សាក្នុងគ្រួសារដែលមានលក្ខណ:ជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម

-បទល្មើសឧក្រិដ្ឋ ឬមជ្ឈិមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬករណីដែលស្ថិតនៅក្នុងក្របខ័ណ្ឌសណ្តាប់ធ្នាប់សាធារណៈ

-វិវាទដែលកំពុងដោះស្រាយដោយតុលាការ ឬដែលមានសេចក្តីសម្រេចពីតុលាការ។

-វិវាទដែលច្បាប់ ឬដែលរាជរដ្ឋាភិបាលបានកំណត់ឲ្យស្ថាប័ន ឬយន្តការជាក់លាក់ណា មួយសម្រុះសម្រួលដោះស្រាយ។

-<u>មាត្រា៩៤</u> នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា: នីតិវិធីក្នុងការដោះស្រាយវិវាទនៅមូលដ្ឋានត្រូវផ្អែកតាមច្បាប់ ឬអនុក្រឹត្យ។

*** *** ***

III-**គណៈកម្មការសុរិយោដី**

+**អំពីដីធ្លី**

+ **ប្រកាសអន្តរក្រសួងការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី លេខ០២ ប្រកៈ. ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖**

+**ប្រការ១** *(នៃប្រកាសអន្តរក្រសួងការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី លេខ០២ ប្រកៈ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) បានចែងថាវិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចទីមួយៗ ដូចតទៅ ៖*

*-វិវាទដីធ្លីដែលបាន ចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ។*

*-វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដីគឺដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី។*

+**ប្រការ២** *(នៃប្រកាសអន្តរក្រសួងការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី លេខ០២ ប្រកៈ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) បានចែងថា តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។*

+**ប្រការ៣** *(នៃប្រកាសអន្តរក្រសួងការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី លេខ០២ ប្រកៈ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) បានចែងថា បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួលនិងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះតុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ។*

+**ប្រការ៤** (*នៃប្រកាសអន្តរក្រសួងការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី លេខ០២ ប្រក.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*) *បានចែងថាវិវាទអំពី កិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ជាដើមជាសមត្ថកិច្ចរបស់តុលាការ។*

+**អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី លេខ:៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២**

+**មាត្រា៤** (*នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីលេខ៤៧ អនក្រ .បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២*) *បានចែងថា គណៈកម្មការសុរិយោដី មានរចនាសម្ព័ន្ធដូចតទៅ:*

*១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា* **គ.ស.ស.ខ** *មានទីតាំងនៅក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលស្រុក ខណ្ឌ។*

*២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា* **គ.ស.ខ.ក** *មានទីតាំងនៅ*

*ក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង។*

*៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា* **គ.ស.ជ** *មានទីតាំងនៅក្នុងទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។*

*គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។*

+**អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ: ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង**

*-មាត្រា១២ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក*

*គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោមៈ*

*-អភិបាល ឬអភិបាលរងខេត្ត ក្រុង ជាប្រធាន*

*-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក*

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុងដែលពាក់ព័ន្ធឲ្យចូលរួមជាសមាជិកអាជហុក។

-<u>មាត្រា១៣ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក</u>

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានភារកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា១០ និងមាត្រា១១ វាក្យខ័ណ្ឌទី២ នៃអនុក្រឹត្យនេះ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

-<u>មាត្រា១៤ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក</u>

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារការកិច្ចដូចតទៅៈ

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងរាល់ពាក្យបណ្តឹងទាក់ទងនិងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ក្នុងករណីការសម្រុះសម្រួលបានសំរេចត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ

-រៀបចំ និងតំកល់ទុកឯកសារ។

**+ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខៈ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង**

**ប្រការ ២៩** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា:

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឲ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ។ករណីសម្រុះសម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅឲ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

**ប្រការ ៣០** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសម្រេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ។ ករណីសម្រុះសម្រួលជំហានទី២ ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះសម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

**ប្រការ ៣១** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

ក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីបានទទួលបណ្តឹងវិវាទសម្រាប់ការសម្រុះសម្រួលជំហានដំបូង ឬការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាឲ្យចូលរួមជាសមាជិកអាដហុកដើម្បីសម្រុះសម្រួលវិវាទ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និងការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ប្រសិនបើមាន។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ។បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់ឲ្យភាគីបង្ហាញភស្តុតាងបន្ថែមនានា និងពេលវេលាសំរាប់សម្រុះសម្រួលវិវាទ។

**ប្រការ ៣២** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ភាគីអាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសម្រេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរារាំងមិនឲ្យសាមីខ្លួនចូលរួមក្នុងការដោះស្រាយវិវាទឬទេ។

**ប្រការ ៣៣** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា :

ភាគីទាំងឡាយអាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងនៅក្នុងលក្ខខណ្ឌ

តែមួយគឺភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ។ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាដហុកនិងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និងសមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និងសភាពការណ៍នៅក្នុងមូលដ្ឋាន។

**ប្រការ ៣៤** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា:

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬនៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួលវិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត។

នីតិវិធីរដ្ឋបាល សម្រាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៤ នៃប្រកាសនេះ។

**ប្រការ ៣៥** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា:

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដី ថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសម្រាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៦នៃប្រកាសនេះ។

អ្នកសម្រុះសម្រួលត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី។

**ប្រការ ៣៦** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

នីតិវិធីរដ្ឋបាលសម្រាប់បញ្ចាក់អំពីកិច្ចដំណោះស្រាយដែលសម្រេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៧ នៃប្រកាសនេះ។

**ប្រការ ៣៧** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា:

នីតិវិធីរដ្ឋបាលសម្រាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ ស្រុក ខណ្ឌដែលមានចែងលំអិតនៅក្នុងប្រការ២៨នៃប្រកាសនេះ។

**+ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារជូនអភិបាលនៃគណៈ-អភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី លេខ: ០៣២ប្រក.ដនស/គសដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០។**

-ប្រការ១ នៃប្រកាស លេខ០៣២ ប្រក.ដនស/គសដ

ត្រូវបានធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី។

**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

-មាត្រា១៧ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម:

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ ជាសមាជិក

-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធឲ្យមកចូលរួមជាសមាជិកអាដហុក។

-មាត្រា១៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាល ពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា១៦ និងវិវាទដែលមានចែងក្នុងចំណុចទី២នៃមាត្រា៣នៃអនុក្រឹត្យនេះ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**ការដោះស្រាយនៅថ្នាក់ជាតិ**

-មាត្រា២០ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសំរេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការដូចមាន ចែងក្នុងមាត្រា២៣ នៃអនុក្រឹត្យនេះ។

-មាត្រា២១ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលទាក់ទង នឹងវិវាទហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឲ្យមានការស៊ើបអង្កេតបន្ថែមទៀតពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសំរេចលើវិវាទ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទតាមការស្នើសុំ របស់ភាគីណាមួយ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយនោះភាគីផ្សេងៗទៀតមានសិទ្ធិទទួលបានការជូនដំណឹងជាមុនអំពីការពិគ្រោះយោបល់នេះដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់។

-មាត្រា២២ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសំរេច។

-មាត្រា២៣ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

ភាគីវិវាទមាន សិទ្ធិស្នើឲ្យមានការពិនិត្យឡើងវិញផ្នែកច្បាប់លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិដោយប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសំរេច។

ប្រសិនបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្របឬដោយមានវិវាទអំពីផលប្រយោជន៍ឬដោយមិនបានផ្តល់ហេតុផលសមរម្យឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួននោះគណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្នែកច្បាប់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ លេខាធិការដ្ឋានត្រូវធានាការពារសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ។

តុលាការ ត្រូវធ្វើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរមកគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី។

ប្រសិនបើគ្មានបណ្តឹងក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះនោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវចាត់ទុកជាស្ថាពរ។

-មាត្រា២៤ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

បន្ទាប់ពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសំរេចនោះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់។

-មាត្រា២៥ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមានផលប្រយោជន៍នៅក្នុងវិវាទសមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងឬ ថ្នាក់ជាតិមានផលប្រយោជន៍នៅក្នុងវិវាទសមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ។ ប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឲ្យធ្វើជាប្រធានអាដហុកដើម្បីដោះស្រាយករណីវិវាទនេះ។

-មាត្រា២៧ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផលអំពីការប្រជុំដើម្បីសម្រុះសម្រួលឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្សឬអង្គការណាមួយដើម្បីជួយខ្លួនក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់។

ភាគីវិវាទមានសិទ្ធិចូលខ្លួនដោយខ្លួនឯងនិងអាចរកជំនួយមនុស្សឬអង្គការណាមួយដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងពេលប្រជុំធ្វើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដី។

ភាគីវិវាទ មានសិទ្ធិបង្ហាញកស្តុតាងផ្ទាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងកស្តុតាងជាក់ស្តែងផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរអំពីវិវាទ។ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទត្រូវបានបើកឲ្យភាគីពាក់ព័ន្ធពិនិត្យ។

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿងនិងដំណើរការដោះស្រាយវិវាទដែលផ្អែកលើភស្តុតាងទាំងឡាយដែលអាចទុកចិត្តបាននិងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ។

ច្បាប់ចម្លងនៃសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ឲ្យភាគីវិវាទ នីមួយៗ។

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ។

**+ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខៈ១១២ ដនស/ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២**

**ដំណើរការដោះស្រាយវិវាទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

**ប្រការ ៣៨** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថាៈ

គណៈកម្មការសុរិយោដីថ្នាក់ជាតិមានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល។

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩ នៃប្រកាសនេះគណៈកម្មការសុរិយោដីថ្នាក់ជាតិ មិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាលត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬនៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង។

**ប្រការ ៣៩** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថាៈ

ក្នុងករណីវិវាទដែលតម្រូវឲ្យមានការសំរេច ឬដំណើរការដោះស្រាយជាបន្ទាន់ដូចជា ករណីមានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឲ្យចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ក្នុងស្ថានភាពនេះភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិឲ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើឲ្យស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និងសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ សេចក្តីសម្រេចបណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល។

**ប្រការ ៤០** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២ ) បានចែងថាៈ

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិតាមតម្រូវការដើម្បីដោះស្រាយវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធឲ្យចូលរួមជាសមាជិកអាដហុកដើម្បីដោះស្រាយវិវាទ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

**ប្រការ ៤១** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថាៈ

បន្ទាប់ពីត្រួតពិនិត្យកំណត់ហេតុផ្លូវការនៃវិវាទ ឬនៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ២៤ នៃប្រកាសនេះ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេចប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឲ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិគូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន។

**ប្រការ ៤២** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទសមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចតែងតាំងសមាជិកថ្មីជំនួសវិញ។

ភាគីអាច ដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទ អំពីផលប្រយោជន៍នោះត្រូវរារាំងមិនឲ្យចូលរួមក្នុងការដោះស្រាយវិវាទឬទេ។

**ប្រការ ៤៣** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២ ) បានចែងថា:

រាល់កិច្ចប្រជុំឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ។

សេចក្តីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬសវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និងប្រព័ន្ធសារព័ត៌មាន។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏ដោយមានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមានឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្តី។

**ប្រការ ៤៤** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២ ) បានចែងថា:

លើកលែងតែការប្រជុំសម្រាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នាគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឲ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគីយ៉ាងហោច១៥ថ្ងៃ នៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬសវនាការ។

**ប្រការ ៤៥** :(នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២ )បានចែងថា:

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការនៃរឿងវិវាទ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ បុគ្គលនោះហៅថាអ្នកការពារក្តីអាចផ្តល់ការណែនាំឬអាចតំណាងភាគីបាន។ អ្នកការពារក្តីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយតាមការយល់ព្រមរបស់ភាគីអាចនិយាយនិងអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបាន។ ទោះបីយ៉ាងណាក្តីបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះអ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ។

ប្រសិនបើអ្នកការពារក្តីបំពានវិធាននៃដំណើរការរឿងវិវាទគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី។ប្រសិនបើអ្នកការពារក្តីនៅតែបន្តបំពានទៀតគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឲ្យចូលរួមដំណើរដោះស្រាយវិវាទទៀតឡើយ។ប្រសិនបើអ្នកការពារក្តីត្រូវបានហាមឃាត់មិនឲ្យចូលរួមដំណើរការរឿងវិវាទនោះត្រូវផ្អាករហូតដល់ភាគីជ្រើសរើសអ្នកការពារក្តីថ្មីបាន ឬយល់ព្រមឲ្យបន្តដំណើរការដោយមិនមានអ្នកកាពារក្តី។គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ។

**ប្រការ ៤៦** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា :

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬអាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបឲ្យធ្វើសវនាការបាន។

រាល់សវនាការសក្ខីកម្មផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរអាចទទួលយកបាន។

គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែត្រូវធានាឲ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និងភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និងសមធម៌។

ភាគីនីមួយៗមានសិទ្ធបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត។បុគ្គលដែលផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ។

**ប្រការ ៤៧** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា :

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្តាប់ភស្តុតាងវិវាទ និងត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបានប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬដោយគណៈកម្មការរដ្ឋបាលហើយត្រូវចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្តីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយត្រូវធ្វើកំណត់សំគាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និងមូលដ្ឋានអង្គហេតុនៃសេចក្តីសំរេចរបស់ខ្លួន។ សេចក្តីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្ញើឲ្យភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬគ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឲ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ចំពោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិហើយត្រូវផ្តល់ព័ត៌មានអំពីរបៀបប្តឹងទៅតុលាការផង។

**ប្រការ ៤៨** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២)បានចែងថាៈ

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្តីសំរេចស្ថាពរនៅក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំឲ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិអនុលោមតាមប្រការ ៤៩ នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬគ្មានការស្នើសុំឲ្យធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបញ្ជូនសេចក្តីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ។

**ប្រការ ៤៩** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា :

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក៣រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគីហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយព័ត៌មាននិងគំនូសតាងចាំបាច់នានា។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និងលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំឲ្យមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ។ នៅក្នុងករណីនេះសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ។

**ប្រការ ៥០** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១២) បានចែងថា :

ភាគីណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នាឬជាបុគ្គលអំពីសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាកា។

**ប្រការ ៥១** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១២) បានចែងថា:

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែស្តីពីបណ្តឹងដែលបានទទួល និងចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្តឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្ញើរបាយការណ៍ប្រចាំខែទៅរាជរដ្ឋាភិបាល។ របាយការណ៍របស់គណៈកម្មការសុរិយោដីត្រូវបើកចំហនិងអនុញ្ញាតឲ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

**ប្រការ ៩២** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំនិងនីតិវិធីរបស់គណៈកម្មការសុរិយោដី លេខ១១៦)បានចែងថាៈ

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗ ដែលបានប្តឹងទៅគណៈកម្មការនោះ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្តីអះអាងភស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗទាក់ទងទៅនឹងវិវាទ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈនិងអនុញ្ញាតឲ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើសៀវភៅភ្ញៀវ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លងបុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន។

**ប្រការ ៩៣** : (នៃប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដីលេខ១១៦) បានចែងថាៈ

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយាដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

+ **<u>អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី</u>**

**+ព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦**

<u>មាត្រា៣</u> នៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ បានចែងថាអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានបេសកកម្ម តួនាទី និងភារកិច្ច ដូចខាងក្រោមៈ

-ទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំ ផ្សព្វផ្សាយឲ្យសាធារណជនយល់ដឹងអំពី ផលវិបាកបណ្តាលមកពីទំនាស់ដីធ្លី និងមានវិធានការដាក់វិន័យចំពោះជនល្មើសដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន។

-ទទួលសំណុំរឿងទំនាស់ដីធ្លីដែលហួសពីសមត្ថកិច្ចគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទំនាស់ដីធ្លី។

-ស្វែងយល់ ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី

-ឃ្លាំមើលការដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ នៃការដោះស្រាយទំនាស់ដីធ្លី ជូនប្រមុខរាជរដ្ឋាភិបាល។

មាត្រា៥ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ បានចែងថា អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទី និងភារកិច្ចដូចតទៅៈ

-ទទួល និងពិនិត្យសំណុំរឿងពាក្យបណ្តឹង និងចុះស្វែងយល់ ស៊ើបអង្កេត ហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតពាក់ព័ន្ធនឹងបញ្ហាទំនាស់ដីធ្លី ដើម្បីដាក់ជូនប្រធានអាជ្ញាធរជាតិដោះស្រាយ ទំនាស់ដីធ្លីពិនិត្យសម្រេចតាមដំណាក់កាល និងករណីនីមួយៗ។

-រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអំពីអង្គប្រជុំរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-ចុះស្វែងយល់ ស៊ើបអង្កេត និងឃ្លាំមើលសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយទំនាស់ដីធ្លីតាមការបញ្ជាណែនាំរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីទៅតុលាការ។

-រៀបចំ និងតំកល់ទុកឯកសារពាក់ព័ន្ធទំនាស់ និងបណ្តឹងដីធ្លី

-រៀបចំសេចក្តីព្រាងរបាយការណ៍ អំពីសកម្មភាពការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីជូនប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីតាមកាលកំណត់ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

-ផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធផលនៃដំណោះស្រាយទំនាស់ដីធ្លីដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានដោះស្រាយចប់ជាស្ថាពរ។

<u>មាត្រា៦</u> នៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ បានចែងថា អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីហើយ និងការចំណាយក្នុងកិច្ចដំណើរការជាបន្ទុកថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

+**<u>អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ ៦៥ អ.នក្រ.បក ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៦</u>**

-<u>មាត្រា២</u> (នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ ៦៥ អ.នក្រ.បក) បានចែងថាអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទីជាអង្គភាពប្រតិបត្តិ និងជាសេនាធិការផ្ទាល់នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងព្រមទាំងសមាជិកមួយចំនួនជាជំនួយការ។

-<u>មាត្រា៣</u> (នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ ៦៥ អ.នក្រ.បក) បានចែងថា អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានបេសកកម្មជួយអាជ្ញាធរក្នុងការដោះស្រាយ និងសម្របសម្រួលចំពោះរាល់វិវាទដីធ្លី និងមានភារកិច្ចដូចកំណត់ក្នុងមាត្រា៥ នៃ**ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦** ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ទន្ទឹមនឹងនេះយោងតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានសិទ្ធិចេញលិខិតណែនាំឲ្យផ្អាកជាបណ្តោះអាសន្នទីតាំងទំនាស់ មិនឲ្យធ្វើសកម្មភាពផ្សេងៗក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ។

-<u>មាត្រា១២</u> (នៃអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ ៦៥ អ.នក្រ.បក) បានចែងថា នាយកដ្ឋានទទួល និងដោះស្រាយបណ្តឹងមានតួនាទី និងភារកិច្ចដូចតទៅ:

១-ទទួល និងចុះលេខពាក្យបណ្តឹងចេញចូលតាមខេត្ត-ក្រុង និងរៀបចំកសាងសំណុំរឿង។

២-បញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ។

៣-កោះអញ្ជើញដើមបណ្តឹង និង/ឬ ចុងចម្លើយពាក់ព័ន្ធឲ្យមកបំពេញឯកសារបន្ថែមប្រសិនយល់ថាឯកសារមិនគ្រប់គ្រាន់និងធ្វើកំណត់ហេតុសួរយកចម្លើយជាបឋម។

៤-ធ្វើចំណាត់ថ្នាក់ កំណត់អាទិភាព និងប្រភេទវិវាទតាមវិស័យ។

៥-ប្រមូលទិន្នន័យនិងឯកសារបន្ថែមដោយធ្វើទំនាក់ទំនងជាមួយភាគីជំលោះ សាក្សីរដ្ឋអំណាចមូលដ្ឋាន ក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិសំរាប់ធ្វើការវិភាគឲ្យបានសុក្រឹត។

៦-សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះពិនិត្យវាស់វែងប្លង់និងព្រំដីវិវាទដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ទៅតាមខ្លឹមសារនៃសំណុំរឿងវិវាទ។

៧-រៀបចំសំណុំឯកសារវាយតំលៃលើលទ្ធផលចុះវាស់វែងនិងបញ្ជូនលទ្ធផលដំបូងខាងផ្នែកបច្ចេកទេសដើម្បីសុំគោលការណ៍និងសេចក្តីសំរេចពីអគ្គលេខាធិការនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។

៨-ធ្វើកំណត់បង្ហាញដោយសង្ខេបខ្លឹមសារបណ្តឹង លើកអង្គហេតុនិងអង្គច្បាប់ពាក់ព័ន្ធ និងផ្តល់យោបល់ជាបឋមជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យនិងសម្រេច។

៩-ផ្ញើសេចក្តីសម្រេចរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដែលមានសុពលភាពអាចអនុវត្តបានទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធី។

***　　***　　***

**IV-អំពីមាត្រាមួយចំនួននៃច្បាប់ និងប្រការនាំឲ្យនៃលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយទំនាស់នៅស្រុក ក្រុង បញ្ជូនមកខេត្ត ដែលគួរយល់ដឹង ៖**

+**អំពីកម្មសិទ្ធិ** (ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)

**ក្រមរដ្ឋប្បវេណី**

-មាត្រា១៣៨ នៃក្រមរដ្ឋប្បវេណី និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាននៅក្នុងទំហំដែលច្បាប់បានកម្រិត។

-មាត្រា១៣៩ នៃក្រមរដ្ឋប្បវេណី កម្រិតនៃកម្មសិទ្ធិដី

១-កម្មសិទ្ធិដី ត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកក្រោមដីនៅក្នុងទំហំនៃការកម្រិតដែលច្បាប់និងបទដ្ឋានគតិយុត្តបានកំណត់ហើយក្នុងទំហំដែលមានផលប្រយោជន៍ សម្រាប់កម្មសិទ្ធិករ។

២-កម្មសិទ្ធិករនៃដីមិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬរំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះបានឡើយ។

-មាត្រា១៤០ នៃក្រមរដ្ឋប្បវេណី ការបញ្ឈប់អំពើដែលរំខានដល់ជីវភាពរស់នៅ

១-ក្នុងករណីដែលអំពើរំខានដល់ជីវភាពរស់នៅដែលមកពីឧស្ម័ន ចំហាយទឹក ក្លិនផ្សែង ម្រេងភ្លើង កំដៅ សម្លេង រំញ័រ ជាអាទិ៍ ដែលកើតពីដីរបស់អ្នកដទៃស្ថិតនៅក្នុងទំហំនៃការប្រើប្រាស់ជាធម្មតា ហើយបទដ្ឋានគតិយុត្តមិនបានហាមឃាត់ទេ កម្មសិទ្ធិករនៃដីមិន អាចទាមទារឲ្យអ្នកដទៃបញ្ឈប់នូវអំពើដែលធ្វើឲ្យមានឥទ្ធិពលដល់ដីខ្លួនបានឡើយ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះកម្មសិទ្ធិករនៃដីដែលទទួលឥទ្ធិពលអាក្រក់ដ៏ធ្ងន់ធ្ងរតាមភាពជាក់ស្តែង អាចទាមទារឲ្យអ្នកដែលរំខានដល់ជីវភាពរស់នៅនោះសងសំណងសមរម្យបាន។ម៉្យាងទៀតបញ្ញត្តិនេះមិនរារាំងកម្មសិទ្ធិករដី ក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលឡើយ។

-មាត្រា១៨១ នៃក្រមរដ្ឋប្បវេណី ការជីកកកាយបេតិកភណ្ឌវប្បធម៌ និងរ៉ែក្នុងដី

១-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើគ្រប់ប្រភេទនៃបដិមា ចម្លាក់ក្រឡោតបុរាណវត្ថុឬបេតិកភណ្ឌវប្បធម៌ផ្សេងទៀតដែលរកឃើញនៅក្នុងដីរបស់ខ្លួនបានឡើយ។ វត្ថុទាំងនេះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋហើយកម្មសិទ្ធិករនៃដីដែលបានរកឃើញវត្ថុទាំងនេះ មានករណីយកិច្ចប្រគល់ឲ្យ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែ នៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអ្នកដែលត្រូវបានទទួលស្គាល់នូវសិទ្ធិជីក ដោយរដ្ឋតាមបញ្ញត្តិនៃច្បាប់ផ្សេងមានសិទ្ធិជីក និងទទួលវត្ថុនោះ។

-មាត្រា១៨២ នៃក្រមរដ្ឋប្បវេណី សិទ្ធិកាប់ចោលមែកឈើឆ្លងព្រំដី

នៅពេលដែលមែកឈើ ឬឫសឈើនៃដីជិតខាង បានលយចូលមកដីរបស់ខ្លួនកម្មសិទ្ធិករនៃដីអាចយកផលពីមែកឈើ ឬឫសឈើនោះ ឬកាប់មែកឈើ ឬឫសឈើនោះបាន ។

-មាត្រា១៨៣ នៃក្រមរដ្ឋប្បវេណី សិទ្ធិប្រើដីដែលជាប់គ្នា

កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ដើម្បីធ្វើរបង ឬសង់សំណង់ឬជួសជុលរបស់ទាំងពីរនេះ នៅព្រំប្រទល់ដីឬនៅក្បែរព្រំប្រទល់នោះ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាត ដោយសារការសាងសង់ ឬជួលជុលនេះកម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង។

-មាត្រា១៨៤ នៃក្រមរដ្ឋប្បវេណី សិទ្ធិចេញចូលដីបិទជិត

១-ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ និងដីដែលមានច្រកចេញនោះមិនគ្រប់គ្រាន់ ហើយមានឧបសគ្គធំខ្លាំងដើម្បីប្រើប្រាស់ដីនោះសម្រាប់ការធ្វើកសិកម្មឬឧស្សាហកម្មហៅថាដីបិទជិត។

២-កម្មសិទ្ធិករនៃដីបិទជិតមានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបានដោយបង់ប្រាក់សំណងតាមការខូចខាតដោយសារការឆ្លងកាត់នោះ។

៣-ជាគោលការណ៍ សិទ្ធិឆ្លងកាត់នេះ ត្រូវរៀបចំតាមទិស ឬផ្លូវដែលមានចម្ងាយជិតបំផុតពីដីបិទជិតទៅផ្លូវសាធារណៈ។ទោះបីជាមានបញ្ញត្តិនៃវាក្យខណ្ឌទី១ នៃកថាខណ្ឌនេះ ក៏ដោយសិទ្ធិឆ្លងកាត់នេះត្រូវតែរៀបចំនៅកន្លែងណាដែលមានការខូចខាតតិចបំផុតសម្រាប់កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកឲ្យឆ្លងកាត់នោះ។

៤-ប្រសិនបើដីបិទជិតកើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរ ការចែកមត៌ក ឬកិច្ចសន្យាផ្សេងទៀតសិទ្ធិឆ្លងកាត់អាចស្នើសុំបានតែចំពោះដីដែលនៅសល់ក្រោយពីការបែងចែកនោះប៉ុណ្ណោះ។ ក្នុងករណីនេះ កម្មសិទ្ធិករនៃដីបិទជិតមិនចាំបាច់បង់ប្រាក់សំណងឡើយ។ ប៉ុន្តែក្នុងករណីដែលមិនមានច្រកចេញគ្រប់គ្រាន់ទេ បញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ។

-<u>មាត្រា១៤៥</u> នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ

១-កម្មសិទ្ធិករនៃដីក្រោម មានករណីយកិច្ចទទួលទឹកដែលហូរតាមធម្មជាតិពីដីលើ។ កម្មសិទ្ធិករនៃដីក្រោម មិនអាចលើកទំនប់ ភ្លឺ របាំង ឬការផ្សេងទៀតទប់មិនឲ្យទឹកហូរបានឡើយ។ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអំពើអ្វីបន្ថែមបន្ទុករបស់កម្មសិទ្ធិករនៃដីក្រោមបានឡើយ។

២-ពេលមានការប្រែប្រួលដោយប្រធានសក្តិ ដែលគ្មានការទទួលខុសត្រូវរបស់ភាគីធ្វើឲ្យរាំងស្ទះទឹកហូរនៅដីក្រោមកម្មសិទ្ធិករនៃដីលើអាចធ្វើប្រឡាយឲ្យទឹកហូរដោយចេញសោហ៊ុយផ្ទាល់ខ្លួនបាន។

-<u>មាត្រា១៤៦</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិប្រើទឹកភ្លៀង ជាអាទិ៍

យោងទៅតាមវាក្យខណ្ឌទី៣ កថាខណ្ឌទី១ មាត្រា១៤៥ (ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ) នៃក្រមនេះ កម្មសិទ្ធិករនៃដីលើ មានសិទ្ធិប្រើប្រាស់ទឹកដែលមានប្រភពផុសឡើងនៅដីរបស់ខ្លួន និងទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន និងមានសិទ្ធិបង្ហូរបោលទឹកទាំងអស់នោះ។

-<u>មាត្រា១៤៧</u> នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចរក្សាការពារទឹកហូរ

កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចទុកឲ្យទឹកហូរទៅលើដីអ្នកជិតខាង តាមតម្រូវការនៃកសិកម្ម ហើយកម្មសិទ្ធិករនៃដីជិតខាងក៏មានករណីយកិច្ចដូចគ្នាដែរដោយយោគយល់ចំពោះដីដែលនៅឆ្ងាយទៀត។

-<u>មាត្រា១៤៨</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិធ្វើផ្លូវទឹកដើម្បីស្រោចស្រព

កម្មសិទ្ធិករដែលចង់ឲ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ ដើម្បីស្រោចស្រពដីរបស់ខ្លួនអាចធ្វើ និងរក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកនឹងដីរបស់ខ្លួនបាន ដោយបង់ប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវឆ្លងកាត់នោះ។

-<u>មាត្រា១៤៩</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិបង្ហូរចោលទឹកស្រោចស្រព

កម្មសិទ្ធិករនៃដីអាចបង្ហូរចោលទឹកដែលបានស្រោចស្រពលើដីរបស់ខ្លួនឆ្លងកាត់ដីក្រោមបានដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីក្រោមនោះ។

-<u>មាត្រា១៥០</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិបង្ហូរទឹកចោលនៃកម្មសិទ្ធិករនៃដីលិចទឹក

កម្មសិទ្ធិករនៃដីលិចទឹកទាំងស្រុងឬមួយចំណែកអាចបង្ហូរទឹកដែលបណ្តាលឲ្យមានការខូចខាតចេញពីដីរបស់ខ្លួនបានលុះត្រាតែគោរពបញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្តស្តីពីអនាម័យ។

-<u>មាត្រា១៥១</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិលើកនិងសិទ្ធិប្រើប្រាស់ទំនប់ជាអាទិ៍

១-កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ដែលចង់ប្រើប្រាស់ទឹកទន្លេ ស្ទឹងឬ ព្រែក ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើសិល្បៈការឲ្យចាំបាច់ដើម្បីយកទឹកនៅលើដី ដែលស្ថិតនៅមាត់ទឹកម្ខាងទៀតបានដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីនៅមាត់ទឹកម្ខាងទៀត។

២-កម្មសិទ្ធិករនៃដីដែលអនុញ្ញាតឲ្យធ្វើសិល្បៈការឲ្យនៅលើដីរបស់ខ្លួនអាចទាមទារប្រើប្រាស់រួមនូវទំនប់ទឹកជាអាទិ៍ពីអ្នកដែលបានធ្វើសិល្បៈការឲ្យនោះបានដោយយកល័ក្ខខ័ណ្ឌ ទទួលបន្ទុកពាក់កណ្តាលនៃសោហ៊ុយធ្វើ និងថែទាំ។ក្នុងករណីនេះ អ្នកដែលបានធ្វើសិល្បៈការឲ្យពុំមានករណីយកិច្ចបង់ប្រាក់សំណងដែលបានកំណត់នៅកថាខណ្ឌទី១ខាងលើនេះទេ ហើយអាចទាមទារឲ្យសងសំណងដែលខ្លួនបានបង់ហើយវិញបាន។

-<u>មាត្រា១៥២</u> នៃក្រមរដ្ឋប្បវេណី អំពើដែលរំខានដល់ជីវភាពរស់នៅ

កម្មសិទ្ធិករដែលមានបំណងធ្វើនៅលើដីរបស់ខ្លួន នូវអំពើដែលនឹងអាចរំខានដល់ជីវភាពរស់នៅរបស់អ្នកជិតខាងដោយ ការខួងអណ្តូង ការជីកស្នង់ការជីករុករកឬ ដោយការទុកវត្ថុមានគ្រោះថ្នាក់វត្ថុដែលរំខានដល់អ្នកដទៃ ឬវត្ថុគ្មានអនាម័យត្រូវអនុលោមតាមបញ្ញត្តិពិសេសដែលកំណត់អំពីចម្ងាយដែលត្រូវគោរព និងអំពើដែលត្រូវអនុវត្ត។

-មាត្រា១៨៣នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចដាក់រនាំងបាំងនៅបង្អួចកើយជាអាទិ៍

អ្នកដែលធ្វើបង្អួច កើយឬសិល្បៈការប្រហាក់ប្រហែលរបស់ទាំងអស់នេះ ដែលសម្លឹងទៅឃើញដីផ្ទះអ្នកជិតខាងនោះ នៅចម្ងាយតិចជាង២(ពីរ) ម៉ែត្រពីព្រំដីអ្នកជិតខាងត្រូវដាក់រនាំងបាំង។

-មាត្រា១៨៤ នៃក្រមរដ្ឋប្បវេណី ដើមឈើនៅជិតព្រំដី

កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬចុល្លព្រឹក្សដែលមានកម្ពស់លើសពី២(ពីរ)ម៉ែត្រ ក្នុងចម្ងាយ២(ពីរ) ម៉ែត្រពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ។ ក្នុងករណីដែលធ្វើផ្ទុយពីបញ្ញត្តិនេះ កម្មសិទ្ធិករនេះមានករណីយកិច្ចដកចេញតាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង។

+**អំពីបរិហារកេរ្តិ៍ជាសាធារណៈ ឬជេរប្រមាថ** (ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦)

**-បរិហារកេរ្តិ៍ជាសាធារណៈ**

-មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ បទបរិហារកេរ្តិ៍ជាសាធារណៈ គ្រប់ការអះអាងបំផ្លើស ឬការទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬស្ថាប័នគឺជាការបរិហារកេរ្តិ៍។

ត្រូវពិន័យជាប្រាក់ពី១០០.០០០(មួយសែន)រៀល ទៅ១០.០០០.០០០(ដប់លាន)រៀល បទបរិហាកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ:

១-តាមសំដីទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។

២-តាមលិខិតឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

**-ជេរប្រមាថជាសាធារណៈ**

-មាត្រា៣០៧នៃក្រមព្រហ្មទណ្ឌ បទជេរប្រមាថជាសាធារណៈ គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយឬគ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ។

ត្រូវពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀលបទដេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅ:

១-តាមពាក្យសំដីទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ។

២-តាមលិខិតឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

+**<u>អំពីការជំពាក់ប្រាក់ និងកិច្ចសន្យា</u>** (ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧)

-<u>មាត្រា៣៣៦</u> នៃក្រមរដ្ឋប្បវេណី ការបង្កើតកិច្ចសន្យាដោយសំណើនិងស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។

-<u>មាត្រា៣៤៥</u> នៃក្រមរដ្ឋប្បវេណី ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី២ (វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា)នេះ និងផ្នែកទី៣ (មោឃភាព និងការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ។

ខ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត។

គ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើធ្មៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។

-មាត្រា៣៥២ នៃក្រមរដ្ឋប្បវេណី ភាពខុសច្បាប់ ឬភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ក្នុងអត្ថន័យនៃកិច្ចសន្យា

១-ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីខាងក្រោមនេះ:

ក.អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។

ខ.អត្ថន័យនៃកិច្ចសន្យានោះផ្ទុយ នឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ។

២-ប្រសិនបើអត្ថន័យនៃកិច្ចសន្យាមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងៗទៀតក៏មិនធ្វើឲ្យខូចសេចក្ដីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេដែលត្រូវទុកជាមោឃៈ។

-មាត្រា៣៨២ នៃក្រមរដ្ឋប្បវេណី ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឲ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវចាត់ទុកជាការសងដែលនាំឲ្យកាតព្វកិច្ចរលត់។

-មាត្រា៣៨៥ នៃក្រមរដ្ឋប្បវេណីសិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះក៏ដោយម្ចាស់បំណុលមិនអាចទាមទារឲ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នា រវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឲ្យអនុវត្តតាមផ្លូវតុលាការ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឲ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការដោយសារមានករណីត្រូវនឹងកថាខណ្ឌទី២ ខាងលើនេះក៏ដោយប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត ហើយម្ចាស់បំណុលអាចទទួល និងរក្សាទុកនូវតាវកាលិកនេះដោយចាត់ទុកថាជាការសងបាន។

-<u>មាត្រា៣៨៦</u> នៃក្រមរដ្ឋប្បវេណី ការតវ៉ាឲ្យអនុវត្តព្រមគ្នា

ភាគីនីមួយៗនៃ<u>កិច្ចសន្យាអញ្ញមញ្ញ</u>[1]អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនរហូតដល់ពេលដែលភាគីម្ខាងទៀតផ្តល់នូវការអនុវត្តកាតព្វកិច្ច។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមិនទាន់ដល់ពេលកំណត់ដើម្បីអនុវត្ត។

-<u>មាត្រា៣៨៧</u> នៃក្រមរដ្ឋប្បវេណី ការតវ៉ាដោយមានការបារម្ភ

ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុននៅក្នុងកិច្ចសន្យាអញ្ញមញ្ញអាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានក្នុងករណីដែលមានការបារម្ភដែលគួរឲ្យកត់សម្គាល់ថាភាគីម្ខាងទៀតនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតដាក់ប្រាតិភោគ ឬចាត់ចែងវិធានការផ្សេងទៀតដើម្បីរំលត់ការបារម្ភនោះ។

-<u>មាត្រា៣៨៨</u> នៃក្រមរដ្ឋប្បវេណី ការអនុវត្តតាមបញ្ញត្តិស្តីពីការសង

ក្រៅពីបញ្ញត្តិនៃជំពូកទី៣ (ការអនុវត្តកិច្ចសន្យា) នេះបញ្ញត្តិស្តីពីការសងដែលបានកំណត់នៅក្នុងផ្នែកទី១ (ការសង) នៃជំពូកទី៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តកិច្ចសន្យា។

-<u>មាត្រា៣៨៩</u>នៃក្រមរដ្ឋប្បវេណី និយមន័យនិងទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច

ការមិនអនុវត្តកាតព្វកិច្ច សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចខាងក្រោមនេះ :

ក.កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឲ្យទាន់ពេលកំណត់ត្រូវអនុវត្តដោយសារការយឺតយ៉ាវក្នុងការអនុវត្ត។

ខ.អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច។

គ.កូនបំណុលមិនបានអនុវត្តឲ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។

ឃ.ករណីផ្សេងៗទៀត ដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។

---

[1] កិច្ចសន្យាអញ្ញមញ្ញជាកិច្ចសន្យាដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមក ដូចជា កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទំនិញ។

-មាត្រា៣៩០ នៃក្រមរដ្ឋប្បវេណី វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ច

ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឲ្យអនុវត្តដោយបង្ខំ សងសំណងនៃការខូចខាត ឬរំលាយកិច្ចសន្យាដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី២ ដល់ផ្នែកទី៤ នៃជំពូកទី៤នេះបាន។

-មាត្រា៣៩១ នៃក្រមរដ្ឋប្បវេណី ការយឺតយ៉ាវក្នុងការអនុវត្ត

កូនបំណុលត្រូវបានចាត់ទុកថាមានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ចនៅពេលដែលបានកំណត់ដូចខាងក្រោមនេះ:

ក.ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលដល់កាលកំណត់នោះ។

ខ.ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថាដល់ពេលកំណត់ហើយ។

គ.ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឲ្យអនុវត្ត។

-មាត្រា៣៩២ នៃក្រមរដ្ឋប្បវេណី អលទ្ធភាពក្នុងការអនុវត្ត

១-ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព។ អលទ្ធភាពនេះត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះត្រូវបានវាយតម្លៃថាមិនអាចធ្វើកើតតាមស្ថានភាពសង្គមឬសេដ្ឋកិច្ច។

២-ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ច នៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្ត ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ។

-មាត្រា៣៩៦ នៃក្រមរដ្ឋប្បវេណី ដីកាបង្គាប់ឲ្យអនុវត្តកាតព្វកិច្ចដោយតុលាការ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាច ទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន។ នីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។

-<u>មាត្រា ៣៩៧</u> នៃក្រមរដ្ឋប្បវេណី ទំនាក់ទំនងរវាងការទាមទារឲ្យអនុវត្តកាតព្វកិច្ច និង មធ្យោបាយផ្សេងៗ

ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចម្ចាស់បំណុលអាចទាមទារឲ្យសងការខូចខាត ជំនួសការទាមទារឲ្យអនុវត្តកាតព្វកិច្ចឬជាមួយការទាមទារឲ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនមានភាពផ្ទុយគ្នា។

-<u>មាត្រា៣៩៩</u> នៃក្រមរដ្ឋប្បវេណី បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ទោះបីជាកូនបំណុលមានសំអាង បញ្ជាក់ថាការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ។ ការប្រាក់ក្នុង អំឡុងពេលនៃការយឺតយ៉ាវនោះត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់។បើអត្រាការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។

-<u>មាត្រា៤០៣</u> នៃក្រមរដ្ឋប្បវេណី ការកំណត់ជាមុននូវចំនួននៃសំណង ជាអាទិ៍

១-ម្ចាស់បំណុលនិងកូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីល័ក្ខខ័ណ្ឌ និងចំនួនសំណងការខូចខាតបាន។

២-ការសន្យាពិសេសដែលឲ្យកូនបំណុលរួចផុតជាមុនពីការទទួលខុសត្រូវក្នុងការមិនអនុវត្ត កាតព្វកិច្ចដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួនមិនមានអានុភាពឡើយ។

៣-ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែមឬបន្ថយចំនួននោះបានទេ។ ប៉ុន្តែក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគី ទាំងសងខាងបានកំណត់ជាមុននោះច្រើនហួសហេតុពេក ឬតិចហួសហេតុពេកបើប្រៀបធៀបទៅ នឹងការខូចខាតដែលត្រូវបានកំណត់តាមបញ្ញត្តិនៃ មាត្រា៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះទើបតុលាការអាចបន្ថែមឬបន្ថយនូវប្រាក់សំណងដែលបានកំណត់ជាមុនបាន។

៤-ការកំណត់ជាមុននូវចំនួននៃសំណងមិនរារាំងការទាមទារឲ្យអនុវត្តកាតព្វកិច្ចឬឲ្យរំលាយកិច្ចសន្យាទេ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបាន ព្រមព្រៀងគ្នាដោយគិតជាមុនអំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះមិនត្រូវចងគូភាគីទេ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង។

-<u>មាត្រា៤០៦</u> នៃក្រមរដ្ឋប្បវេណី អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ចមានអំឡុងពេល៥(ប្រាំ)ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង។

-<u>មាត្រា៤១៣</u> នៃក្រមរដ្ឋប្បវេណី អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន មានអំឡុងពេល៥ (ប្រាំ)ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។

-<u>មាត្រា៤៣៤</u> នៃក្រមរដ្ឋប្បវេណី អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជន បានទេតតិយជននោះ មិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល។

៣-ម្ចាស់បំណុល និងកូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន។

-<u>មាត្រា៤៣៧</u> នៃក្រមរដ្ឋប្បវេណី សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាពលុះត្រាតែធ្វើចំពោះម្ចាស់បំណុលឬអ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសងកូនបំណុល នោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀតតាមការទាមទារពីម្ចាស់បំណុលនោះ។ ក្នុងករណីនេះអ្នកសងអាចទាមទារឲ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន។

-<u>មាត្រា៤៤០</u> នៃក្រមរដ្ឋប្បវេណី វិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ចនិងតាមគោលការណ៍នៃភាពសុចរិតនិងភាព ស្មោះត្រង់។

-<u>មាត្រា៤៤៣</u> នៃក្រមរដ្ឋប្បវេណី ពេលនៃការសង ការសងមុនពេលកំណត់

១-កូនបំណុលត្រូវសងនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា៣៩១(ការយឺតយ៉ាវក្នុងការអនុវត្ត) នៃក្រមនេះ។

២-កូនបំណុលអាចសងមុនពេលកំណត់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

-<u>មាត្រា៤៤៤</u> នៃក្រមរដ្ឋប្បវេណី ម៉ោងសង

កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀបទម្លាប់និងគោលការណ៍នៃភាពសុចរិតនិងភាពស្មោះត្រង់។

-<u>មាត្រា៤៤៥</u> នៃក្រមរដ្ឋប្បវេណី ទីកន្លែងដែលត្រូវសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើងនៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។

-<u>មាត្រា៤៤៧</u> នៃក្រមរដ្ឋប្បវេណី ការចេញលិខិតទទួល

អ្នកសងអាចទាមទារឲ្យអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការទទួលការសងនោះបាន។

-<u>មាត្រា៤៥០</u> នៃក្រមរដ្ឋប្បវេណី ការកាត់បំណុលតាមច្បាប់កំណត់

ក្នុងករណីដែលអ្នកសងនិងអ្នកទទួលការសងមិនបានធ្វើការជ្រើសរើសដើម្បីកាត់បំណុលនោះទេការកាត់បំណុលនោះត្រូវធ្វើឡើងតាមបញ្ញត្តិដូចខាងក្រោមនេះ :

ក-ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងបានមកដល់ និងកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន។

ខ-ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយឬមិនទាន់មកដល់នៅឡើយត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេសម្រាប់កូនបំណុល។

គ-ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុល ត្រូវកាត់កាតព្វកិច្ច ដែលពេលកំណត់ត្រូវសងបានមកដល់មុនគេ ឬនឹងមកដល់មុនគេ។

ឃ-ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និងមានពេលកំណត់ដែលត្រូវសងដូចគ្នា ត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ច នីមួយៗ។

-<u>មាត្រា៤៨២</u> នៃក្រមរដ្ឋប្បវេណី អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល៥(ប្រាំ)ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង។

-<u>មាត្រា៤៨៣</u>នៃក្រមរដ្ឋប្បវេណី អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករឬពាណិជ្ជករលក់ទៅឲ្យអ្នកដែលមិនមែនជាពាណិជ្ជករនិងថ្លៃសេវាដែលផលិតករឬពាណិជ្ជករផ្តល់ឲ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល២(ពីរ)ឆ្នាំ។

-<u>មាត្រា៤៨៤</u>នៃក្រមរដ្ឋប្បវេណី អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរដោយសាលក្រមឬសាលដីកាស្ថាពរឬដោយ ការផ្សះផ្សាតាមផ្លូវតុលាការឬដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជា មានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង៥(ប្រាំ)ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃ ការរំលត់សិទ្ធិនោះត្រូវមានអំឡុងពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ។

២-បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់នៅពេលនៃការចូលជាស្ថាពរ។

-<u>មាត្រា៥១៥</u> **នៃក្រមរដ្ឋប្បវេណី** និយមន័យនៃការលក់ទិញ

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអ្នកលក់មានករណីយកិច្ច ត្រូវផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។

-<u>មាត្រា៥១៦</u> **នៃក្រមរដ្ឋប្បវេណី** ការបង្កើតកិច្ចសន្យាលក់ទិញ

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែភាគីអាចកំណត់ការធ្វើលិខិតយថាភូតឬលិខិតឯកជនជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។

-<u>មាត្រា៥១៨</u> **នៃក្រមរដ្ឋប្បវេណី** ប្រាក់កក់

បើអ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់ អ្នកទិញអាច <u>រំលាយកិច្ចសន្យាលក់ទិញ ដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ។</u> ប៉ុន្តែភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយ ក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ។

+**<u>អំពីការផ្តាច់ពាក្យរៀបការ</u>** (ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧)

-<u>មាត្រា៩៤៥</u> **នៃក្រមរដ្ឋប្បវេណី** ការសងជំនូន ក្នុងករណីដែលកំជាប់ពាក្យបានរលាយភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឲ្យភាគីម្ខាងទៀតសងជំនូននោះមកវិញបាន។

-<u>មាត្រា៩៤៦</u> **នៃក្រមរដ្ឋប្បវេណី** ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោលដោយគ្មានមូលហេតុត្រឹមត្រូវភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន។

-មាត្រា៩៤៧ នៃក្រមរដ្ឋប្បវេណី អំឡុងពេលដាក់ពាក្យបណ្តឹង បណ្តឹងដែលទាក់ទង ទៅនឹងមាត្រា៩៤៥ (ការសងជំនូន) ឬមាត្រា៩៤៦(ការទទួលខុសត្រូវចំពោះការបដិសេធចោល ដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្តឹងនៅក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែលកំដាប់ពាក្យនោះ បានរលាយ។

+**អំពីទ្រព្យសម្បត្តិ** (ក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧)

-មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណី បានចែងថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនិងប្រព័ន្ធ ទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុនឬក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារ កាតព្វកិច្ច និងភាគបម្រុងបានឡើយ។

២-បើប្តីប្រពន្ធ មិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់)។

-មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណី បានចែងថា ភាពចាំបាច់នៃទម្រង់ជាលាយលក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងលក្ខខណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២-ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ។

-មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី បានចែងថា ទ្រព្យសម្បត្តិដោយឡែក ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះគឺជាទ្រព្យសម្បត្តិដោយឡែកដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និងចំណុច ខ ខាងលើនេះ ។

-<u>មាត្រា៩៧៣</u> នៃក្រមរដ្ឋប្បវេណី បានចែងថា <u>ទ្រព្យសម្បត្តិរួម</u> ទ្រព្យសម្បត្តិរួមគឺ ជាទ្រព្យសម្បត្តិទាំងឡាយដែលប្ដី ប្រពន្ធទាំងសងខាងឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និងចំណុច គ នៃមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ។

-<u>មាត្រា៩៧៤</u> នៃក្រមរដ្ឋប្បវេណី បានចែងថា <u>ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ</u>

១-ប្ដីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀតឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រងនិងរក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។

៤-បើការពិភាក្សាអំពីការគ្រប់គ្រងឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ ប្ដីប្រពន្ធមិនបាន សម្រេចឬបើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឲ្យធ្វើការចាត់ចែង ចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

-<u>មាត្រា៩៧៦</u> នៃក្រមរដ្ឋប្បវេណី បានចែងថា <u>ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ</u>

១-បើគ្មានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនអាចយកទៅលក់ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍និងដើម្បីរក្សាជីវភាពរស់នៅនោះប្ដីប្រពន្ធណាម្ខាងអាចលក់ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបានដោយទទួលការ អនុញ្ញាតពីតុលាការ។

៣-ក្នុងករណីដែលប្តីឬប្រពន្ធណាម្នាក់ បានលក់ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្នាក់ទៀតផង និងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាន នៅក្នុងអំឡុងពេល ២(ពីរ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុនឹងនៅក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេងៗ

-<u>មាត្រា៩៨០</u> នៃក្រមរដ្ឋប្បវេណី បានចែងថា <u>ការបែងចែកទ្រព្យសម្បត្តិ</u>

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តី ប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាមចំណុចនីមួយៗដូចកំណត់ខាងក្រោមនេះ:

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ភាគ២(មួយភាគពីរ)នៃទ្រព្យសម្បត្តិរួម។ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្នាក់តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់ កូនជាអាទិ៍។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។

+**អំពីការបង្ករការខូចខាតទ្រព្យសម្បត្តិ** ( ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩)

-មាត្រា៤១៨នៃក្រមព្រហ្មទណ្ឌ បទធ្វើឲ្យមានការខូចខាតស្រាល អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លិចបំផ្លាញធ្វើឲ្យទ្រុឌទ្រោមឬ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ថ្ងៃទៅ៦(ប្រាំមួយ)ថ្ងៃ និងពិន័យជាប្រាក់ពី១.០០០(មួយពាន់)រៀល ទៅ ១០០.០០០(មួយសែន)រៀល ប្រសិនបើការខូចខាតមានលក្ខណៈស្រាល។

បទប្បញ្ញត្តិនៃមាត្រានេះមិនត្រូវអនុវត្តទៅលើទ្រព្យសម្បត្តិវប្បធម៌សាធារណៈ ឬឯកជនដែលជាផ្នែកនៃបេតិកភណ្ឌជាតិរបស់ព្រះរាជាណាចក្រកម្ពុជាទេ។

-មាត្រា៤១០នៃក្រមព្រហ្មទណ្ឌ បទធ្វើឲ្យខូចខាតដោយចេតនា អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោមឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន) រៀល ទៅ៤.០០០.០០០ (បួនលាន)រៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល។

-មាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ស្ថានទម្ងន់ទោស បទល្មើសដែលមានចែងក្នុងមាត្រា៤១០ (បទធ្វើឲ្យខូចខាតដោយចេតនា)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន)រៀលទៅ១០.០០០.០០០ (ដប់លាន) រៀល នៅក្នុងករណីដូចតទៅ :

១-កាលបើបទល្មើសនេះ បានប្រព្រឹត្តដោយបុគ្គលច្រើនរូបធ្វើសកម្មភាពក្នុងឋានៈជា ចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែងជាលំនៅឋាន។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែង សម្រាប់តម្កល់មូលនិធិតម្លៃទំនិញ ឬសម្ភារៈ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ដល់សំណង់គ្រឹះស្ថានសាធារណៈឬផ្លូវសាធារណៈ។

៥កាលបើបទល្មើសនេះបានប្រព្រឹត្តនាំឲ្យខូចប្រយោជន៍ដល់ដំណាំ ឬកសិផល។

៦-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឲ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

+**អំពីការបង្ករបួសស្នាមតូចតាច** (ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩)

-មាត្រា២២៨ នៃក្រមព្រហ្មទណ្ឌ បទហិង្សាស្រាល អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឲ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥.០០០(ប្រាំពាន់)រៀល ទៅ១០០.០០០ (មួយសែន)រៀល។

+.**អំពីអំពើហិង្សាក្នុងគ្រួសារ**( ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥)

មាត្រា៣៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថារដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ ជាពិសេសអំពីការទទួលខុសត្រូវក្នុងគ្រួសារការគោរពសិទ្ធិគ្នាទៅវិញទៅមក ដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធី ព្រមទាំងណែនាំឲ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារដល់ជនរងគ្រោះ។

រដ្ឋជម្រុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឲ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហាដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា។

-មាត្រា៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថាការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយបើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាលឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ។

-មាត្រា១៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមានអាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សាឬសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរបានទេ។

-ដីកាការពារសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

-មាត្រា១៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្តក្រុងដើម្បីសុំឲ្យចេញដីកាការពារ។

ចៅក្រមដែលទទួលចាត់ការត្រូវចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានជនមុខសញ្ញា។

-មាត្រា២៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានចែងថា ដីកាការពារមានពីរដំណាក់កាល :

១-ដំណាក់កាលទី១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ។

២-ដំណាក់កាលទី២ ហៅថាដីកាការពារមានរយៈពេល៦ (ប្រាំមួយ)ខែ ចេញក្នុងពេល ដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬមុនមានសាលក្រមស្ថាពរ។

មាត្រា២ អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ ៖ ១.ប្តី ឬប្រពន្ធ។ ២.កូនក្នុងបន្ទុក។ ៣.ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។

មាត្រា១៣ ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើតឬជឿជាក់ថានឹងកើតឡើងអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយៈ

-ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬអាចប្រើប្រាស់

-បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។

-ផ្តល់ឲ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់។

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឲ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងក្នុងមាត្រា២០ និងមាត្រា២៦ នៃច្បាប់នេះ។ ជនមុខសញ្ញាក្នុងច្បាប់នេះគឺសំដៅដល់អ្នកដែលបានប្រព្រឹត្តកំពុងប្រព្រឹត្ត និងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។

<u>មាត្រា១៨</u> ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា៤៣ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ ដែលមានជាអាទិ៍ ៖

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង

-ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឲ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ

-ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច

-ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ។

<u>មាត្រា១៩</u> បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតឡើងហើយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុង ទីកន្លែងកើតហេតុទោះជាពុំមានដីកាតុលាការអនុញ្ញាតឲ្យចូលក៏ដោយក្នុងករណីទាំងឡាយដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ចយល់ដោយ សមហេតុផលថា មានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល៤៨ម៉ោងកន្លងផុតឬនឹងអាចកើតឡើងក្នុងអំឡុងពេល២៤ម៉ោងខាងមុខ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឲ្យបានជាក់លាក់អំពីហេតុការណ៍នោះរួចរាយការណ៍ជាបន្ទាប់ ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច។

<u>មាត្រា១៦</u> ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឲ្យចេញដីកាការពារ។

ចៅក្រមដែលទទួលចាត់ការ ត្រូវចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានជនមុខសញ្ញា។

<u>មាត្រា១៧</u> ក្នុងការចូលរួមអនុវត្តន៍នីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បី ផ្សះផ្សា ឬសម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬមជ្ឈិមធ្ងន់ធ្ងរបានទេ។

<u>មាត្រា១៨</u> អាជ្ញាធរមានសមត្ថកិច្ចអាចឃាត់ខ្លួនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការដូចមានចែងក្នុងមាត្រា២៤ និងមាត្រា២៥ នៃច្បាប់នេះដោយពុំចាំបាច់មានដីកាតុលាការ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ដែលពុំមានដីកាពីតុលាការ ត្រូវហាមឃាត់។

ក្នុងករណីអនុវត្តន៍តាមបញ្ញត្តិនៃវាក្យខណ្ឌទី១ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់កសាងសំណុំរឿងនិងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ក្នុងអំឡុងពេលអតិបរិមាដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីចាត់ការវិធានការបន្ថែមឲ្យស្របច្បាប់។

<u>មាត្រា១៩</u> អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិកជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញាទោះអំពើហិង្សានេះបានកន្ទងផុតហើយក៏ដោយ។

បណ្តឹងអាជ្ញាត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះនិងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន។

***   ***   ***

## V-**នគរបាលយុត្តិធម៌**

(ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧)

**-មាត្រា៥៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌ បេសកកម្មរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ។

នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង។

**-មាត្រា៥៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌ សមាសភាពរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌រួមមាន :

១-មន្ត្រីនគរបាលយុត្តិធម៌។

២-ភ្នាក់ងារនគរបាលយុត្តិធម៌។

៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។

**១-មន្ត្រីនគរបាលយុត្តិធម៌** (ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧)

**-មាត្រា៦០**នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌:

១-មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិចបំផុត២(ពីរ)ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

២-នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំរើការងារយ៉ាងតិចបំផុត ២(ពីរ)ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

៣-អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម:

ក-អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាលនិងអភិបាលរងស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

ខ-ប្រធាននិងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាននិងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

ឃ-ប្រធាន និងអនុប្រធាននាយកដ្ឋាន,ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ឃ-ប្រធាននិងអនុប្រធាននាយកដ្ឋាន,ប្រធាននិងអនុប្រធានការិយាល័យ ប្រធាននិងអនុប្រធានផ្នែកនៃៈ

-នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

-មន្ទីរប្រឆាំងគ្រឿងញៀន

-នាយកដ្ឋាននគរបាលទេសចរណ៍

-ស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច-ប្រធាននិងអនុប្រធានការិយាល័យ,ប្រធាននិងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជាៈ

-ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល

-ការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្មនិង

-ការិយាល័យជនបរទេស។

ឆ-អធិការ និងអធិការរង ប្រធាននិងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ។

ជ-ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាននិងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"។ ប្រធាននិងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាននិងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ"ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ប្រធាន និងអនុប្រធានអគ្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ-ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"។

ញ-មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ-មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ-មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ-ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ-ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាលឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**-មាត្រា៦៣** នៃក្រមនីតិវិធីព្រហ្មទណ្ឌ សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថាខ្លួននឹងបំពេញដោយកក្តីភាពនូវមុខងាររបស់ខ្លួន។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយនៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**-មាត្រា៦៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ នីតិវិធីខាងវិន័យ រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួនត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញាឬដោយចៅក្រមស៊ើបសួរដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីវិន័យ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យនេះ។

-<u>មាត្រា៦៥</u> នៃក្រមនីតិវិធីព្រហ្មទណ្ឌ <u>ទណ្ឌកម្មខាងវិន័យ</u> ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

កាលណាមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើស ក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួនយុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឲ្យយុត្តាធិការផ្សេងចាត់ការវិញបានដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា។

-**<u>មាត្រា៦៧</u>** នៃក្រមនីតិវិធីព្រហ្មទណ្ឌ មណ្ឌលរដ្ឋបាលបំពេញការងារមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗមានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួន ត្រូវបានចាត់តាំងឲ្យទៅបំពេញការងារ។នៅភ្នំពេញមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ច នៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះនៅកន្លែងណាក៏ដោយ។ សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់ មណ្ឌលរដ្ឋបាលដែលមន្ត្រីនោះត្រូវចាត់តាំងឲ្យទៅបំពេញការ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

-**<u>មាត្រា៦៨</u>** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការពន្យាតសមត្ថកិច្ចដែនដី ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា៨៦(និយមន័យបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះ ត្រូវចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីការចាត់ឲ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ចៅក្រមនេះអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។

ចៅក្រមដែលបានអនុញ្ញាតឲ្យមានការពន្យាតសមត្ថកិច្ចត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។

**-មាត្រា៧១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ហេតុនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែងនិងធ្វើការស៊ើបអង្កេតបឋម ក្នុងលក្ខខណ្ឌនៃមាត្រា៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត)ដល់មាត្រា១១០(អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម) នៃក្រមនេះ ។

កាលណាការស៊ើបសួរបានចាប់ផ្តើមមន្ត្រីនគរបាលយុត្តិធម៌ អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរនៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា១៧៣ (ដីកាចាត់ឲ្យស៊ើបសួរជំនួស) ដល់មាត្រា១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌)នៃក្រមនេះ។

**២ភ្នាក់ងារនគរបាលយុត្តិធម៌** (ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧)

**-មាត្រា៧៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌មានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌:

១-នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។

២-ភ្នាក់ងារនគរបាលជាតិផ្សេងទៀត។

៣-នាយទាហាននៃកងរាជអាវុធហត្ថដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។

៤-យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ។

**-មាត្រា៧៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌ សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថនេះត្រូវធ្វើឡើងនៅ ចំពោះមុខសាលាដំបូង។ សម្បថនេះពុំចាំបាច់ធ្វើ

ឡើងវិញឡើយនៅពេលដែលបានទទួលនូវគុណសម្បត្តិ ជាភ្នាក់ងារនគរបាលយុត្តិធម៌ នាពេលក្រោយទៀត។រូបមន្តសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

-**មាត្រា៧៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកកម្ម:

១-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ។

២-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ ធ្វើរបាយការណ៍។ របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតា។

ក្នុងករណីណាក៏ដោយភ្នាក់ងារនគរបាលយុត្តិធម៌ ពុំអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះត្រូវចាត់ទុកជាមោឃៈ។

-**មាត្រា៧៩** នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញាឬដោយចៅក្រម ស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយ។ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការ បន្តនៃនីតិវិធីវិន័យ។

-**មាត្រា៨០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។ កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសនៅក្នុងការបំពេញមុខងាររបស់ខ្លួនតុលាការកំពូលអាចផ្ទេរអំណាចឲ្យទៅយុត្តាធិការផ្សេងចាត់ការវិញបានដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា។

+**នគរបាលជាតិ និងកងរាជអាវុធហត្ថ**(ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧)

-**មាត្រា៨១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា : ការកំណត់សមត្ថកិច្ច

ក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថ ត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៥៦(បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនេះ។

លើសពីនេះទៅទៀត ចំពោះ បទល្មើសយោធាមានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌។

កិច្ចប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ត្រូវកំណត់ដោយអនុក្រឹត្យ។

អង្គភាពនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចថ្នាក់ជាតិអាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ។

**៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង់សមត្ថកិច្ចរបស់ខ្លួន**

-**មាត្រា៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា :

ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យពិនិត្យបទល្មើសត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។ បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង។ រូបមន្តនៃពាក្យសម្បថត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

ចំពោះការពិនិត្យបទល្មើសមន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍។ របាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ។

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា

ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រីឬភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ។

ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**+រដ្ឋបាលព្រៃឈើ**

+**ច្បាប់ស្តីពីព្រៃឈើ** (ព្រះរាជក្រម នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២)

**ជំពូកទី១៤ នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ**

-**មាត្រា៧៦** នៃច្បាប់ស្តីពីព្រៃឈើ

បទល្មើសព្រៃឈើ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចរិតពិសេស ដូចមានចែងក្នុងច្បាប់នេះ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត បទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ។

ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងវង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន។

ប្រតិបត្តិការរបស់ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាល យុត្តិធម៌ ត្រូវអនុវត្តន៍ស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-**មាត្រា៧៧**នៃច្បាប់ស្តីពីព្រៃឈើ

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើមន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសំគាល់ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ។

**-មាត្រា៧៨** នៃច្បាប់ស្តីពីព្រៃឈើ

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ឬថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែងអាជ្ញាធរទាំងនោះ

១-ត្រូវជូនពត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើឬការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្នរួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ដើម្បីចាត់ការតាមនីតិវិធី។

៣-មិនត្រូវប្រមូលប្រក់ពិន័យឬរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ។

**-មាត្រា៧៩** នៃច្បាប់ស្តីពីព្រៃឈើ

ដើម្បីអនុវត្តន៍ភារកិច្ចរបស់ខ្លួន <u>មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មាន</u>សិទ្ធិ ដូចតទៅ ៖

១.អាចឲ្យបុគ្គលណាមួយឆ្លើយតបសំណួរ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ។

២.ចូលធ្វើការត្រួតពិនិត្យ ឬឆែកឆេរគ្រប់ទីកន្លែង រួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។

៣.ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះបើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនិងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិចូលឆែកឆេរនៅក្នុងទីធ្លាអគារឬក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនសង្ស័យ និងមានសាក្សី២(ពីរ)នាក់ ដែលជាអ្នកជិតខាង ឬអ្នកម្ចាស់ផ្ទះ។

-មាត្រា៨០ នៃច្បាប់ស្ដីពីព្រៃឈើ

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ក្នុងករណីបទល្មើសជាក់ស្ដែងត្រូវចាប់ឃាត់ជាបណ្ដោះអាសន្ន ៖

១.រាល់ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលស្មើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

២.សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ។

៣.គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និងសត្វព្រៃ។

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់៤៨ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ។

-មាត្រា៨១ នៃច្បាប់ស្ដីពីព្រៃឈើ

ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ។

ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌។

-មាត្រា៨២ នៃច្បាប់ស្ដីពីព្រៃឈើ

វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោមៈ

១-ផល អនុផលព្រៃឈើ ឬផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស។

២-សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

វត្ថុតាងដូចមានចែងក្នុងកថាខ័ណ្ឌទី១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្ដោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរតាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជំរះរបស់តុលាការ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផលអនុផលព្រៃឈើល្មើសឬផលប្រមាញ់ល្មើសអ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្ដោះអាសន្នដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសមគំនិត។

ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និងសំណាកសត្វព្រៃដែលបានឃាត់ទុក ហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬបំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ។

-**មាត្រា៨៣** នៃច្បាប់ស្តីពីព្រៃឈើ

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទា ជានគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ។

-**មាត្រា៨៤** នៃច្បាប់ស្តីពីព្រៃឈើ

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ។

-**មាត្រា៨៥** នៃច្បាប់ស្តីពីព្រៃឈើ

អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើមាន:

១-បទល្មើសព្រៃឈើថ្នាក់ទី១ មានអាជ្ញាយុកាលដប់ប្រាំ(១៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

២-បទល្មើសព្រៃឈើថ្នាក់ទី២ មានអាជ្ញាយុកាលប្រាំ(៥)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

៣-បទល្មើសព្រៃឈើថ្នាក់ទី៣ មានអាជ្ញាយុកាលមួយ(១)ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស។

ការអនុវត្តន៍អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើ ត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ។

-**មាត្រា៨៨**នៃច្បាប់ស្តីពីព្រៃឈើ

មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូលឬមួយផ្នែកមួយរយៈដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទាននិកប្រព្រឹត្តល្មើស នឹងបទប្បញ្ញត្តិនៃច្បាប់នេះឬល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទានរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់។

-**មាត្រា៨៩**នៃច្បាប់ស្តីពីព្រៃឈើ

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចណាមួយធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះមានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ។

ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលព្រៃឈើក្នុងករណីមិនអាចទទួលយកបានជននោះ អាចធ្វើបណ្តឹងតវ៉ាទៅតុលាការ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអំណាចនិងដំណើរការអនុវត្តន៍ច្បាប់របស់មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ។

**មាត្រា៩២** ជំពូកទី១៥បទល្មើសព្រៃឈើនិងទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីព្រៃឈើ

ប្រាក់ពិន័យអន្តរការណ៍ប្រាក់ពិន័យតាមសាលក្រមតុលាការឬប្រាក់បានមកពីការលក់វត្ថុតាងត្រូវបង់ចូលថវិកាជាតិ។រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ។

**មាត្រា៩៣**ជំពូកទី១៥បទល្មើសព្រៃឈើនិងទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីព្រៃឈើ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មដូចតទៅ ៖

១-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំទៅដប់(១០)ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ។

២-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំទៅប្រាំ(៥)ឆ្នាំនិងឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន(១០,០០០,០០០)រៀលទៅមួយរយលាន(១០០,០០០,០០០)រៀល។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ។

៣-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែទៅមួយ(១)ឆ្នាំឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១,០០០,០០០)រៀលទៅដប់លាន(១០,០០០,០០០)រៀល។វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ។

៤-ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀម ឬលិខិតអនុញ្ញាតិ។

តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តន៍ឯកភាពទូទាំងប្រទេស។

**មាត្រា១០០** ជំពូកទី១៥បទល្មើសព្រៃឈើនិងទោសប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និងធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយ នឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬរាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ចំនួនពីដប់លាន (១០,០០០,០០០)រៀល ទៅមួយរយលាន (១០០,០០០,០០០)រៀល។

**មាត្រា១០១** ជំពូកទី១៥បទល្មើសព្រៃឈើនិងទោសប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ

ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០,០០០,០០០)រៀល ទៅមួយរយលាន (១០០,០០០,០០០)រៀល។

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

២-ចូលរួមទាំងស្រុង ឬដោយផ្នែក និងដោយផ្ទាល់ ក្នុងសកម្មភាពណាមួយនៃអាជីវកម្ម ព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

៣-អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ។

៤-ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬធ្វើជានិយោជិក ឬអ្នកជានាឲ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ(១)ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ។

៥-មិនបានរាយការណ៍ ឬមិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី១ ដែលបានកើតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្សណ៍អក្សរដែលជាមូលហេតុបង្កឲ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី១។

-**មាត្រា១០២** ជំពូកទី១៦ ការអនុវត្តន៍សាលក្រមតុលាការ នៃច្បាប់ស្តីពីព្រៃឈើ

ការអនុវត្តន៍សាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ ជាភារកិច្ចរបស់រដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចលើកលែងតែទោសជាប់ពន្ធនាគារ។

-**មាត្រា១០៣** ជំពូកទី១៦ ការអនុវត្តន៍សាលក្រមតុលាការ នៃច្បាប់ស្តីពីព្រៃឈើ

រាល់សម្រង់សាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច។

-**មាត្រា១០៤** ជំពូកទី១៦ ការអនុវត្តន៍សាលក្រមតុលាការ នៃច្បាប់ស្តីពីព្រៃឈើ

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរវត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលព្រៃឈើ។

+**ជលផល**

+**ច្បាប់ស្តីពីជលផល**(ព្រះរាជក្រម នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ខែឧសភាឆ្នាំ២០០៦)

**ជំពូកទី១៤ : នីតិវិធីដោះស្រាយបទល្មើសជលផល**

-**មាត្រា៧២** នៃច្បាប់ស្តីពីជលផល

បទល្មើសជលផលជា ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតដោយឡែកដូចមានចែងក្នុងច្បាប់នេះ។

មន្ត្រីរដ្ឋបាលជលផល មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតរាល់បទល្មើសជលផល និងចងក្រងសំណុំរឿងប្តឹងទៅតុលាការមានសមត្ថកិច្ច។

ការស្រាវជ្រាវត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលជលផល ដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តន៍ស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

-**មាត្រា៧៣** នៃច្បាប់ស្តីពីជលផល

នៅពេលបំពេញបេសកកម្មស្រាវជ្រាវត្រួតពិនិត្យទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល មន្ត្រីរដ្ឋបាលជលផលត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

មន្ត្រីរដ្ឋបាលជលផលត្រូវធ្វើសច្ចាប្រណិធានចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីទទួលនីតិសម្បទាបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌។

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើនិងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសជលផលតាមដែនសមត្ថកិច្ចរបស់ខ្លួន។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលជលផលត្រូវកំណត់ដោយអនុក្រឹត្យ។

-**មាត្រា៧៤**. នៃច្បាប់ស្តីពីជលផល

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតត្រូវបង្កភាពងាយស្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលឬថែរក្សាវត្ថុតាងបទល្មើសជលផលជាបណ្តោះអាសន្នក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងកថាខណ្ឌខាងលើនេះបានជួបប្រទះនូវបទល្មើសជលផលជាក់ស្តែងអាជ្ញាធរទាំងនោះ :

១-ត្រូវជូនព័ត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចដែលនៅជិតបំផុត។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស និងដកហូតទុកវត្ថុតាងនៃបទល្មើសជាបណ្តោះអាសន្នរួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលជលផលដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី។

៣-មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងនៃបទល្មើសជលផលដោយផ្ទាល់ឡើយ។

-**មាត្រា៧៥**នៃច្បាប់ស្តីពីជលផល

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចមានសិទ្ធិដូចតទៅ៖

១.ត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទ និងការធ្វើវារីវប្បកម្មគ្រប់ប្រភេទ។

២.ត្រួតពិនិត្យការដឹកជញ្ជូន ផែត្រី កន្លែងកែច្នៃ កន្លែងធ្វើសន្និធិ ឬទីតាំងទិញលក់ផល ផលិតផលជលផល។

៣.បញ្ឈប់ និងត្រួតពិនិត្យលើគ្រប់មធ្យោបាយ ដែលសង្ស័យថាមានផ្ទុកវត្ថុតាងនៃបទល្មើសជលផល។

៤.ចូលត្រួតពិនិត្យឬឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រកំពង់ផែទន្លេ ផែស្ងួត ផែត្រី ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយរថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។

៥.សាកសួរបុគ្គលនានាអំពីព័ត៌មានដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសជលផល។

៦.ដកហូតឃាត់ទុកជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះបើសិនជាបុគ្គលកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

ចំពោះមន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិដូចតទៅ៖

១.លែង រក្សាទុកជាប្រយោជន៍សាធារណៈ ឬបំផ្លាញចោលនូវផល ផលិតផលជលផល ល្មើសច្បាប់ដែលបានដកហូត ឃាត់ទុក និង លក់ចំពោះវត្ថុតាងណាដែលងាយខូចខាតដោយមានការចូលរួមជាសាក្សីពីអាជ្ញាធរមូលដ្ឋានឬសមត្ថកិច្ចនានាដែលនៅជិតនោះដោយមានកំណត់ហេតុត្រឹមត្រូវ។

២.បំផ្លាញចោលដោយមានកំណត់ហេតុត្រឹមត្រូវនូវវត្ថុតាងនៃបទល្មើស ជលផលមានជាអាទិ៍ ឧបករណ៍នេសាទហាមឃាត់ ឬឧបករណ៍នេសាទឬសម្ភារៈបរិក្ខារល្មើសច្បាប់ឬឡជ្បូងប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង។

៣.ក្នុងករណីបទល្មើសជាក់ស្តែង ចូលឆែកឆេរនៅក្នុងទីធ្លាអគារ ឬក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌជរមាន។

**-មាត្រា៧៦**នៃច្បាប់ស្តីពីជលផល

ក្នុងករណីបទល្មើសជលផលជាក់ស្តែង មន្ត្រីរដ្ឋបាលជលផល មានសមត្ថកិច្ចមានសិទ្ធិដកហូតឃាត់ទុកជាបណ្តោះអាសន្ន ៖

១.ផលផលិតផល ជលផល ដែលបានមកពីការធ្វើអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម ការកែច្នៃ ការធ្វើសន្និធិ ការទិញ ការលក់ផែត្រី ឬការដឹកជញ្ជូនដែលល្មើសនឹងច្បាប់នេះ។

២.ផល អនុផលព្រៃលិចទឹក និងព្រៃកោងកាងដែលបានមកពីការកាប់ ការគ្ការ ការរាន ការឈូសឆាយដោយល្មើសនឹងច្បាប់នេះ។

៣.ឧបករណ៍នេសាទ និងមធ្យោបាយរួមផ្សំដែលប្រើប្រាស់ក្នុង ការប្រព្រឹត្តបទល្មើស។

៤.ប្រភេទផល ផលិតផលជលផលកំពុងរងគ្រោះថ្នាក់

៥.សម្ភារៈបរិក្ខារ ឬមធ្យោបាយដឹកជញ្ជូននានាដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ជលផល ឬយកចេញបរិក្ខារណាមួយសម្រាប់ដំណើរការនាវា ឬយានយន្ត។

៦.ឯកសារផ្សេងៗ ដែលពាក់ព័ន្ធបទល្មើសជលផល។

៧.លិខិតអនុញ្ញាតគ្រប់ប្រភេទក្នុងករណី ដែលអ្នកទទួលសិទ្ធិតាមលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិសម្រេចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស ជលផលបានរយៈពេល ៤៨ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ។

**-មាត្រា៧៧**នៃច្បាប់ស្តីពីជលផល

ការកសាងសំណុំរឿងបទល្មើសជលផល ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

-មាត្រា៧៨.នៃច្បាប់ស្តីពីជលផល

វត្ថុតាងនៃបទល្មើសជលផល ត្រូវកំណត់ដូចខាងក្រោម :

១-ផល ផលិតផលជលផល និងឧបករណ៍នេសាទ ឬ ផលអនុផលព្រៃលិចទឹក និងព្រៃកោងកាងដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស។

២-សម្ភារៈបរិក្ខារនិងមធ្យោបាយដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

វត្ថុតាងដែលមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចបានដកហូតឃាត់ទុកជាបណ្តោះអាសន្នត្រូវតែរក្សាទុករហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរតាមការបង់ប្រាក់ពិន័យអន្តរការណ៍ ឬតាមការជំនុំជម្រះរបស់តុលាការ។

ក្នុងករណីមិនអាចទុកយូរបានបណ្តាលមកពីការពុកផុយហួតហែងធ្វើឲ្យបាត់បង់បរិមាណ និងគុណភាពមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចអាចលក់វត្ថុតាងទាំងនោះយកប្រាក់មកតម្កល់ទុកបាន។

ក្នុងពេលកំពុងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសអ្នកបើកបរមធ្យោបាយអូស ឬរុញឬដឹកជញ្ជូនវត្ថុតាងនៃបទល្មើសដែលគ្មានម្ចាស់នៅជាមួយត្រូវឃាត់ខ្លួនជាបណ្តោះអាសន្នដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើសនិងអ្នកសមគំនិត។

-មាត្រា៧៩នៃច្បាប់ស្តីពីជលផល

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ។

-មាត្រា៨០នៃច្បាប់ស្តីពីជលផល

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ពាក់ព័ន្ធនឹងសំណុំរឿង បទល្មើស ជលផលមានសិទ្ធិ និងកាតព្វកិច្ចចូលបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសជលផលនោះជូនតុលាការ។

-មាត្រា៨១នៃច្បាប់ស្តីពីជលផល

អាជ្ញាយុកាលនៃបទល្មើសជលផលត្រូវស្របតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ។

**-មាត្រា៨៤នៃច្បាប់ស្តីពីជលផល**

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិផ្អាកសកម្មភាពនេសាទនៅក្នុងទីតាំងនេសាទទាំងមូល ឬមួយផ្នែកជាបណ្តោះអាសន្នដើម្បីចាត់ការតាមនីតិវិធី ក្នុងករណីរូបវន្តបុគ្គលឬនីតិបុគ្គលនោះប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬល្មើសនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀងរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់។

**-មាត្រា ៨៥.-នៃច្បាប់ស្តីពីជលផល**

បុគ្គលណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចមានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលសេចក្តីសម្រេចនេះទៅប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។

ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេលសាមសិប(៣០) ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹងតវ៉ានោះ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ក្នុងករណីមិនអាចទទួលយកបាន ជននោះមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច។

ការតវ៉ាក្រោមមាត្រានេះនឹងមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអំណាចនិងដំណើរការអនុវត្តច្បាប់របស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ។

**-មាត្រា១០៥. ជំពូកទី១៦ ការអនុវត្តសាលក្រមតុលាការនៃច្បាប់ស្តីពីជលផល**

ការអនុវត្តសាលក្រម ឬ សាលដីកាស្ថាពរនៃបទល្មើសជលផល ជាភារកិច្ចរបស់រដ្ឋបាលជលផលមានសមត្ថកិច្ចលើកលែងតែទោសដាក់ពន្ធនាគារ។

**-មាត្រា១០៦.-ជំពូកទី១៦ ការអនុវត្តសាលក្រមតុលាការនៃច្បាប់ស្តីពីជលផល**

ពល់សម្រង់សាលក្រម ឬសាលដីកានៃបទល្មើសជលផល ត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលជលផលមានសមត្ថកិច្ច។

**-មាត្រា ១០៧.-ជំពូកទី១៦ ការអនុវត្តសាលក្រមតុលាការនៃច្បាប់ស្តីពីជលផល**

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរវត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋឬបំផ្លាញចោលត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលជលផល។

+**ច្បាប់ស្តីពីសហគមន៍កសិកម្ម** (ព្រះរាជក្រម នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៩ខែមិថុនា ឆ្នាំ២០១៣)

**ជំពូកទី១៦ ការតាមដាន និងការដោះស្រាយវិវាទ**

**មាត្រា ១០២**_នៃច្បាប់ស្តីពីសហគមន៍កសិកម្ម

អង្គភាពចុះបញ្ជីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចក្នុងការតាមដានលើរាល់ដំណើរការប្រតិបត្តិការមុខរបរ និងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម សហភាព សហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាក្នុងគោលបំណងជំរុញ និងតម្រង់ទិសក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម។

**មាត្រា ១០៣**_នៃច្បាប់ស្តីពីសហគមន៍កសិកម្ម

វិវាទទាំងឡាយដែលកើតចេញពីសមាជិកនិងសមាជិកសហគមន៍កសិកម្ម រវាងសមាជិក និងសហគមន៍កសិកម្មត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មសាមីនោះ។

ក្នុងករណីមហាសន្និបាតមិនអាចដោះស្រាយវិវាទបាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុងស្រុកខណ្ឌសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីមិនអាចដោះស្រាយវិវាទបានមន្ទីរកសិកម្មរាជធានី ខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមី ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

**មាត្រា ១០៤**_នៃច្បាប់ស្តីពីសហគមន៍កសិកម្ម

វិវាទទាំងឡាយដែលកើតរវាងសហគមន៍កសិកម្ម និងសហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានីខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

**មាត្រា ១០៥**._នៃច្បាប់ស្តីពីសហគមន៍កសិកម្ម

វិវាទទាំងឡាយដែលកើតចេញពីសហគមន៍កសិកម្មជាសមាជិក និងសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំឬមហាសន្និបាតវិសាមញ្ញនៃសហភាពសហគមន៍កសិកម្មសាមី ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

ក្នុងករណីមហាសន្និបាតនៅមិនអាចដោះស្រាយបាន គណៈអភិបាលរាជធានីខេត្តសាមី និងនាយកដ្ឋានអភិវឌ្ឍសហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។

**មាត្រា ១០៦**._នៃច្បាប់ស្តីពីសហគមន៍កសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់វិវាទទាំងឡាយដែលមិនអាចបញ្ចប់បានរវាង៖

ក- សមាជិក និងសមាជិកសហគមន៍កសិកម្ម

ខ- សមាជិក និងសហគមន៍កសិកម្ម

គ-សហគមន៍កសិកម្ម និងសហគមន៍កសិកម្ម

ឃ- សហគមន៍កសិកម្មជាមួយសហភាពសហគមន៍កសិកម្ម

ង- សហគមន៍កសិកម្មឬសហភាពសហគមន៍កសិកម្មជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ឬអង្គភាពក្រៅណាមួយជាមួយសហគមន៍កសិកម្ម។

ក្នុងករណីភាគីពាក់ព័ន្ធដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិធ្វើបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធ ឬតុលាការរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេច។

**<u>ក្រសួងបរិស្ថាន</u>**

+**<u>ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ</u>** (ព្រះរាជក្រម នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨)

**ជំពូកទី៩ ការអនុវត្តច្បាប់ និងនីតិវិធីដោះស្រាយបទល្មើស**

-**មាត្រា៤៥**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចបានចែងក្នុងច្បាប់នេះ។

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាបទប់ស្កាត់បទល្មើសធនធានធម្មជាតិ នៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីសាលក្រម ឬសាលដីកាចូលជាស្ថាពរវត្ថុតាងដែលបានរឹបអូសទុកជាសម្បត្តិរដ្ឋត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលការពារ និងអភិរក្សធនធានធម្មជាតិ នៃក្រសួងបរិស្ថាន។

**-មាត្រា ៤៦**.នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់កងកម្លាំងប្រដាប់អាវុធ ស្ថាប័នពាក់ព័ន្ធដទៃទៀតនិងសាធារណជនត្រូវបង្កភាពងាយស្រួលផ្តល់ព័ត៌មាន និងជួយសហការផ្តល់កម្លាំងក្នុងការចុះធ្វើការស្រាវជ្រាវ ការស៊ើបអង្កេត ការទប់ស្កាត់ ការបង្ក្រាបបទល្មើសលើធនធានធម្មជាតិ ឬការថែរក្សាវត្ថុតាងបទល្មើសជាបណ្តោះអាសន្នក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ ស្តីពីបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ដោយសហការជាមួយអាជ្ញាធរដែនដី ដើម្បីការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

**-មាត្រា ៤៧**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

នៅពេលបំពេញភារកិច្ចចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិនៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួននិងនៅពេលចូលបំភ្លឺក្នុងសវនាការរបស់តុលាការ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវមានសម្លៀកបំពាក់ឯកសណ្ឋាន និងពាក់ផ្លាកសញ្ញាសម្គាល់ត្រឹមត្រូវ។

-**មាត្រា ៤៨**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ មានសិទ្ធិប្រើប្រាស់អាវុធស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

អាវុធត្រូវបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។

-**មាត្រា ៤៩**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

ការកសាងសំណុំរឿងនៃបទល្មើសក្នុងតំបន់ការពារធម្មជាតិត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើស ក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌។

-**មាត្រា ៥០**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

វត្ថុតាងនៃបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិត្រូវបានកំណត់ដូចខាងក្រោម :

១-ផលអនុផលធនធានធម្មជាតិ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស

២-សម្ភារៈបរិក្ខា និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

វត្ថុតាងដូចមានចែកក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរតាមការបង់ពិន័យអន្តរការណ៍ ឬតាមការជំនុំជម្រះរបស់តុលាការ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផលអនុផលធនធានធម្មជាតិល្មើសដែលគ្មានម្ចាស់នៅជាមួយនោះអ្នកបើកបរមធ្យោបាយដឹកជញ្ជូនត្រូវឃាត់ខ្លួនជាបណ្តោះអាសន្នស្របតាមបទបញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសមគំនិត។

ផល អនុផលធនធានធម្មជាតិដែលបានឃាត់ទុកហើយងាយខូចខាតរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសិទ្ធិលែងឬបំផ្លាញចោលឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ។

-**មាត្រា ៥១**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពទាំងមូលឬមួយផ្នែកជាបណ្តោះអាសន្នរបស់បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបំពានលើកិច្ចសន្យារហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់។

**មាត្រា ៥២**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

បុគ្គលណាមិនពេញចិត្តចំពោះការសម្រេចណាមួយដែលធ្វើឡើងដោយមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដូចមានចែងក្នុងច្បាប់នេះ លើកលែងការសម្រេចពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ ដូចមានចែងក្នុងមាត្រា៥៤ មាត្រា៥៦ ចំណុច១ នៃមាត្រា៥៧ មានសិទ្ធិធ្វើពាក្យប្តឹងតវ៉ាមកប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្តាលក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់កើតហេតុ ឬប្តឹងទៅតុលាការ។

ប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្តាលត្រូវសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្តាលក្នុងករណីនៅតែមិនអាចទទួលយកបានបុគ្គលនោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការបានក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ យ៉ាងយូរ។

ការតវ៉ាក្រោមមាត្រានេះ មិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ។

## ជំពូកទី១០ បទល្មើសធនធានធម្មជាតិ និងទោសប្បញ្ញត្តិ

**មាត្រា ៦៣**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

ជនណាដែលធ្វើការគម្រាមកំហែងដល់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិធ្វើឲ្យរាំងស្ទះដល់ការបំពេញភារកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ឆ្នាំទៅប្រាំ(៥)ឆ្នាំនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់ប្រាំលាន(១៥,០០០,០០០)រៀល ទៅមួយរយហាសិបលាន(១៥០,០០០,០០០)រៀល។

ជនណាដែលសមគំនិតឬជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសដូចតារីដែរ។

**មាត្រា ៦៤**.-នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬភ្នាក់ងារអធិការកិច្ច ឬមន្ត្រីបរិស្ថានរូបណាដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្នឬមិនគោរពទៅតាមបទប្បញ្ញត្តិ នៃច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល និង/ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ។

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬភ្នាក់ងារអធិការកិច្ច ឬមន្ត្រីបរិស្ថានរូបណាដែលសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលការប្រព្រឹត្តបទល្មើសនេះត្រូវផ្តន្ទាទោសដូចតារីដែរ។

**ក្រសួងហិរញ្ញវត្ថុ**

+**ច្បាប់ស្តីពីគយ** (ព្រះរាជក្រម នស/រកម/០៧០៧/០១៧ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧)

+**គយ**

-**មាត្រា៥៨**នៃច្បាប់ស្តីពីគយ

មន្ត្រីគយដែលបានសច្ចាប្រណិធានអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ បានលុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

មន្ត្រីគយដែលបានទទួលនីតិសម្បទានជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសគយតាមដែនសមត្ថកិច្ចរបស់ខ្លួន។

នៅពេលបំពេញបេសកកម្មស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ មន្ត្រីគយ ត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសម្គាល់ ពាក់ឋានន្តរសក្តិ លើកលែងតែមានការណែនាំដោយឡែកពីនាយកទីចាត់ការគយ និងរដ្ឋាករ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីគយត្រូវកំណត់ដោយអនុក្រឹត្យ។

-**មាត្រា៦០**នៃច្បាប់ស្តីពីគយ

មន្ត្រីគយដែលបានសច្ចាប្រណិធាន មានលក្ខណៈសម្បត្តិជានគរបាលយុត្តិធម៌ អាចសម្រេចឃាត់ខ្លួនបានក្នុងរយៈពេលសែសិបប្រាំបី(៤៨) ម៉ោងយ៉ាងយូរដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

-**មាត្រា២៨**នៃច្បាប់ស្តីពីគយ

<u>រដ្ឋបាលគយអាចផ្តល់បាននូវការបង្វិលសងវិញទាំងស្រុង ឬភាគខ្លះនូវពន្ធ និងអាករនាំចូលដែលបានបង់រួចចំពោះ៖</u>

ក-ការបង់លើសដោយប្រការណាមួយរាប់បញ្ចូលទាំងករណីដែលបណ្តាលមកពីការភ័ន្តច្រឡំរដ្ឋបាលផង។

ខ-ទំនិញនាំចូលដែលនៅមុនពេលអនុញ្ញាតឲ្យយកចេញពីគយត្រូវពិនិត្យឃើញថាតិចជាងបែកបាក់ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬបំផ្លាញចោលក្រោមការគ្រប់គ្រងឃ្លាំមើលរបស់គយទោះបីនៅក្រោយពេលអនុញ្ញាតឲ្យយកចេញពីគយរួចហើយក៏ដោយ។

គ-ការបង់លើសដែលបានរកឃើញតាមរយៈសេចក្តីសម្រេចរបស់អាជ្ញាធរទទួលបន្ទុកដោះស្រាយការតវ៉ាដូចមានចែងក្នុងមាត្រា៦៤ នៃច្បាប់នេះឬដោយតុលាការមានសមត្ថកិច្ច។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសស្តីពីការបង្វិលសងវិញដែលបានរៀងរាប់ខាងលើ និងការបង្វិលសងវិញដោយមូលហេតុផ្សេងទៀតរួមទាំងការកម្រិតពេលវេលាផងដែរ។

-**មាត្រា៥៧** នៃច្បាប់ស្តីពីគយ

តាមពេលវេលាដែលច្បាប់អនុញ្ញាត មន្ត្រីគយមានសិទ្ធិចូលក្នុងទីតាំង ឬទីកន្លែងដែលរក្សាទុកឯកសារដូចចែងក្នុងមាត្រា៥១នៃច្បាប់នេះហើយមានសិទ្ធិធ្វើសវនកម្ម ឬពិនិត្យផ្ទៀងផ្ទាត់ឯកសារទាំងនោះដែលពាក់ព័ន្ធនឹងកិច្ចចម្លងការដោយឡែកឬភាពត្រឹមត្រូវ និងអាចទទួលយកបាននៃប្រព័ន្ធកត់ត្រាដោយដៃ ឬប្រព័ន្ធអេឡិចត្រូនិកដែលនៅក្នុងប្រព័ន្ធនោះឯកសារទាំងនេះត្រូវបានបង្កើត និងរក្សាទុក។

មន្ត្រីគយអាចធ្វើអធិការកិច្ចបានលើឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ឬទ្រព្យសម្បត្តិកិច្ចដំណើរការឬកិច្ចការផ្សេងទៀតដែលមន្ត្រីគយយល់ថាចាំបាច់ និងពាក់ព័ន្ធ នឹងគោលដៅនៃការប្រមូលពន្ធនិងអាករក្រោមបញ្ញត្តិនៃច្បាប់នេះ សម្រាប់ អនុវត្តតាមគោលបំណងបំពេញនូវភារកិច្ចរបស់មន្ត្រីគយ ឬក្នុងគោលបំណងនៃការប្រមូលព័ត៌មានដែលតម្រូវដោយច្បាប់នេះ។

មន្ត្រីគយមានសិទ្ធិចេញ និងចូលទៅគ្រប់ទីតាំងកន្លែង អគារ និងទីកន្លែងនានា ព្រមទាំងមានសិទ្ធិឆែកឆេរ ឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀតទោះបីជាស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យ របស់អ្នកទទួលបានអាជ្ញាប័ណ្ណអ្នកនាំចេញ ឬអ្នកនាំចូល ឬបុគ្គលណាផ្សេងទៀត។

មន្ត្រីគយអាចដកស្រង់ព័ត៌មាន ឬថតចម្លងនូវកំណត់ត្រា ឬឯកសារនានា ដកហូតយកដោយមានកំណត់ហេតុនិងរក្សាទុកឯកសារដែលបានបង្ហាញពាក់ព័ន្ធនឹងការប្រកាសណាមួយឬតាមតម្រូវការនៃច្បាប់នេះដោយគ្មានជាប់បន្ទុកចំណាយអ្វីឡើយ។

តាមសំណើរបស់ជនដែលកាន់កាប់ឯកសារ មន្ត្រីគយត្រូវផ្តល់ដល់ជននោះនូវឯកសារថតចម្លងត្រឹមត្រូវដោយមានការបញ្ជាក់ពីរដ្ឋបាលគយ។

-**មាត្រា៦២** នៃច្បាប់ស្តីពីគយ

អ្នកបើកបរមធ្យោបាយដឹកជញ្ជូនក្នុងការធ្វើចលនាមធ្យោបាយដឹកជញ្ជូនរបស់ខ្លួនត្រូវគោរពតាមបញ្ជារបស់មន្ត្រីគយ។

មន្ត្រីគយអាចប្រើប្រាស់បរិក្ខារសមស្របដើម្បីឃាត់បញ្ឈប់មធ្យោបាយដឹកជញ្ជូនកាលបើអ្នកបើកបរមិនឈប់តាមការបញ្ជាឲ្យឈប់។

នៅពេលមានការស្នើសុំអាជ្ញាធរមានសមត្ថកិច្ច នគរបាល និងយោធាត្រូវជួយជាបន្ទាន់ដល់មន្ត្រីគយ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ។

-**មាត្រា៦៦** នៃច្បាប់ស្តីពីគយ

មន្ត្រីគយមានសិទ្ធិឃាត់ទុកបណ្តោះអាសន្ននូវទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលចូលរួមក្នុងការរំលោភបំពានលើបទប្បញ្ញត្តិនានានៃច្បាប់នេះ។ ទំនិញនិងមធ្យោបាយដឹកជញ្ជូនទាំងនោះអាចជាកម្មវត្ថុនៃការរឹបអូសដោយតុលាការមានសមត្ថកិច្ច។

នៅក្រៅវង់អំណាចគយការឃាត់ទុកបណ្តោះអាសន្នអាចត្រូវធ្វើឡើងនៅក្នុងការិយាល័យគយកន្លែងសន្និធិគយបណ្តោះអាសន្នភណ្ឌាគារគយមានដែនកំណត់និងកន្លែងផ្សេងទៀតដែលស្ថិតនៅក្រោមអនុរក្សរបស់រដ្ឋបាលគយ។

ទំនិញដូចមានចែងនៅក្នុងកថាខណ្ឌទី២មាត្រា៨ នៃច្បាប់នេះ អាចត្រូវបានឃាត់ទុកជាបណ្តោះអាសន្ននៅគ្រប់ទីកន្លែងក្នុងដែនគយ។

ការឃាត់ទុកបណ្ដោះអាសន្ន អាចត្រូវបានអនុវត្តផងដែរនៅគ្រប់ទីកន្លែងក្នុងដែនគយក្នុងករណីមានការដេញប្រផាប់ចាប់ប្រកីង ឬការរកឃើញដោយចៃដន្យនូវទំនិញដែលមិនស៊ីគ្នានឹងការប្រកាសឬឯកសារដែលមានជាប់នឹងអ្នកកាន់កាប់។

មន្ត្រីគយមានសិទ្ធិថតចម្លង ឬដកហូតឯកសារ ឬវត្ថុផ្សេងៗទៀតដែលជាភ័ស្តុតាងនៃការរំលោភបំពានច្បាប់នេះ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងការឃាត់ទុកបណ្ដោះអាសន្ននូវទំនិញមធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុផ្សេងៗទៀតព្រមទាំងការថតចម្លង ឯកសារទាំងនោះ។

-**មាត្រា៦៨**នៃច្បាប់ស្ដីពីគយ

មន្ត្រីគយដែលធ្វើការឃាត់ទំនិញត្រូវធ្វើកំណត់ហេតុឃាត់ទុកដោយមិនបង្អែបង្អង់។

បើជនល្មើសវត្តមានត្រូវចុះក្នុងកំណត់ហេតុថា បានអានសេចក្ដីឲ្យសាមីខ្លួនស្ដាប់បានហៅសាមីខ្លួនឲ្យអាន និងចុះហត្ថលេខាព្រមទាំងបានផ្ដល់ជាបន្ទាន់នូវកំណត់ហេតុមួយច្បាប់ដល់ជននោះ។

បើជនល្មើសអវត្តមានសេចក្ដីចម្លងកំណត់ហេតុត្រូវបិទផ្សាយ ក្នុងរយៈពេលម្ភៃបួន (២៤)ម៉ោងបន្ទាប់ ពីកំណត់ហេតុត្រូវបានផ្ញើរួចនៅការិយាល័យគយជិតបំផុត ឬនៅការិយាល័យអាជ្ញាធរមូលដ្ឋានជិតបំផុត ប្រសិនបើទីនោះគ្មានការិយាល័យគយ។

សេចក្ដីលម្អិតនានាពាក់ព័ន្ធនឹងទម្រង់ខ្លឹមសារនីតិវិធីសម្រាប់ការរៀបចំ និងការដាក់ជូនទៅតុលាការនៃកំណត់ហេតុដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

-**មាត្រា៧១**នៃច្បាប់ស្ដីពីគយ

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀតអាចតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករក្នុងអំឡុងពេលសាមសិប(៣០)ថ្ងៃ ក្រោយបានទទួលសេចក្ដីជូនដំណឹងពីទោសទណ្ឌ ឬការឃាត់ទុកដោយបញ្ជាក់ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិជានាស្របតាមបញ្ញត្តិមាត្រា៤១ នៃច្បាប់នេះ។

នាយកទីចាត់ការគយនិងរដ្ឋាករត្រូវចេញសេចក្ដីសម្រេចលើការតវ៉ាក្នុងអំឡុងពេលហុកសិប (៦០)ថ្ងៃ គិតជាពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថាបានទទួលការយល់ព្រម។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងដំណើរការតវ៉ានេះ។

**-មាត្រា៧៧**នៃច្បាប់ស្ដីពីគយ

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលចំពោះបទល្មើសគយដែលមានចែងក្នុងច្បាប់នេះ។ សិទ្ធិសម្រុះសម្រួលនេះប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ។ក្នុងករណីមិនអាចសម្រុះសម្រួលបានរដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងនេះទៅតុលាការមានសមត្ថកិច្ច។

ការសម្រុះសម្រួលអាចធ្វើទៅបាននៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ច។

ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តសិទ្ធិក្នុងការសម្រុះសម្រួលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**-មាត្រា២៤**នៃច្បាប់ស្ដីពីគយ

បុគ្គលអ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួនដែលមិនពេញចិត្តចំពោះហេតុផល ឬភាពត្រឹមត្រូវនៃការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាងដើមកំណើតឬតម្លៃគិតពន្ធគយដែលបានផ្ដល់ជូនក្នុងប្រវេសន៍ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌ ក និង កថាខណ្ឌ ខ មាត្រា១៨ នៃច្បាប់នេះ អាចជំទាស់ទៅនឹងការ សម្រេចនេះជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយនិងរដ្ឋាករក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ គិតពីថ្ងៃ ដែលប្រតិវេទករបានទទួលប្រវេសន៍ពីការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាងដើមកំណើត ឬតម្លៃគិតពន្ធគយនេះ។

នៅក្នុងករណីដែលតម្លៃគិតពន្ធគយ គឺជាកម្មវត្ថុនៃការតវ៉ាទំនិញត្រូវបានអនុញ្ញាតឲ្យយកចេញពីគយដោយគ្មានការបង់ប្រាក់ពន្ធ និងអាករឡើយប្រសិនបើអ្នកនាំចូលតម្កល់នូវនិមុត្តិធានាគ្រប់គ្រាន់ដើម្បីធានាប្រាក់ពន្ធ និងអាករ។

នាយកទីចាត់ការគយ និងរដ្ឋាករត្រូវធ្វើសេចក្ដីសម្រេចលើការជំទាស់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ក្នុងរយៈពេលហុកសិប (៦០)ថ្ងៃបន្ទាប់ពីការជំទាស់ត្រូវបានទទួល។ បើមិនដូច្នោះទេ ការជំទាស់នឹងត្រូវចាត់ទុកថា បានយល់ព្រមហើយនិមុត្តិធានាត្រូវប្រគល់ជូនវិញ។

បុគ្គលណាដែលជំទាស់ទៅនឹងការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការតាវាងពន្ធគយបាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការតាវាងពន្ធគយត្រូវកំណត់ដោយអនុក្រឹត្យ។

អ្នកនាំចេញឬអ្នកនាំចូលមានសិទ្ធិធ្វើការតវ៉ាទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងការសម្រេចរបស់គណៈកម្មាធិការតាវាងពន្ធគយក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតពីថ្ងៃបានទទួលនូវសេចក្ដីជូនដំណឹងពីការសម្រេចនេះ។

+-**ពន្ធដារ**

**អនុក្រឹត្យលេខ០០៣ អនក្រ.បក ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ចុះខែមករា ឆ្នាំ២០១៦**

-មាត្រា១នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អនុក្រឹត្យនេះមានគោលបំណងធានាតម្លាភាពអព្យាក្រឹតភាព នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តបាននៃការដោះស្រាយវិវាទសារពើពន្ធ។

មាត្រា២នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធដែលសរសេរជាអក្សរកាត់ថា "**គ.វ.ស**" ស្របតាមមាត្រា២៤ នៃច្បាប់ស្ដីពីគយ និងមាត្រា១២៣ នៃច្បាប់ស្ដីពីសារពើពន្ធ។

-មាត្រា៣នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះវិវាទគយ រដ្ឋាករ និងពន្ធដារដែលកើតចេញពីការមិនពេញចិត្តរបស់អ្នកជាប់ពន្ធចំពោះសេចក្ដីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។

មាត្រា៤នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

**គ.វ.ស** [2]មានសមាសភាព ដូចតទៅ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | អនុប្រធាន |
| ៣-តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ០១រូប | សមាជិក |

[2] គណៈកម្មាធិការ ដោះស្រាយវិវាទសារពើពន្ធ សរសេរអក្សរកាត់ថា គ.វ.ស

៨-អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សមាជិក

៩-អគ្គនាយនៃអគ្គនាយដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ច.ស** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-<u>មាត្រា៥នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

**គ.ច.ស**[3] មានភារកិច្ច ដូចតទៅៈ

-ពិនិត្យ ដោះស្រាយ និងសម្រេចលើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការចុងក្រោយរបស់អគ្គនាយដ្ឋានពន្ធដារពាក់ព័ន្ធវិវាទពន្ធដារដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

-ពិនិត្យ ដោះស្រាយ និងសម្រេចលើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាពាក់ព័ន្ធវិវាទគយនិងរដ្ឋាករដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

-ពិនិត្យ ដោះស្រាយ និងសម្រេចលើសេចក្តីសម្រេចឬវិធានការពាក់ព័ន្ធវិវាទសារពើពន្ធចុងក្រោយផ្សេងទៀត ដែលបង្កើតជាកាតព្វកិច្ចចំពោះសាមីអ្នកប្តឹងតវ៉ាផ្ទាល់។

-<u>មាត្រា៧ នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

**គ.ច.ស** មានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួង ស្ថាប័ន សវនករតំណាងវិស័យឯកជនពាក់ព័ន្ធដើម្បីបំភ្លឺ ឬផ្តល់យោបល់តាមការចាំបាច់។

អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចបំភ្លឺលើពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធតាមការអញ្ជើញរបស់ **គ.ច.ស** ។

### ជំពូកទី៤ នីតិវិធីដោះស្រាយបណ្តឹងតវ៉ា

-<u>មាត្រា១០នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងសេចក្តីសម្រេច ឬវិធានការដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅអគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចឬវិធានការរបស់អគ្គនាយកដ្ឋានពន្ធដារ។

---

[3] គណៈកម្មាធិការ ដោះស្រាយវិវាទសារពើពន្ធ សរសេរអក្សរកាត់ថា គ.វ.ស

អ្នកជាប់ពន្ធដែលមិនពេញចិត្ត នឹងសេចក្តីសម្រេច ឬវិធានការដែលចេញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសិទ្ធិដាក់ពាក្យបណ្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេច ឬវិធានការរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

មាត្រា១១នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារត្រូវពិនិត្យដោះស្រាយសម្រេចឬមានវិធានការឆ្លើយតបលើពាក្យបណ្តឹងរបស់អ្នកជាប់ពន្ធក្នុងរយៈពេលមិនលើសពី៦០ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង។

វិធាន និងនីតិវិធីនៃការដោះស្រាយវិវាទគយ និងរដ្ឋាករនៅកម្រិតអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាព្រមទាំងវិធាន និងនីតិវិធីនៃការដោះស្រាយវិវាទពន្ធដារនៅកម្រិតអគ្គនាយកដ្ឋានពន្ធដារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-មាត្រា១២នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិប្តឹងតវ៉ាមក **គ.វ.ស**[4]ក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ាឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឬអគ្គនាយកដ្ឋានពន្ធដារដោយចម្លងជូនសាមីអគ្គនាយកដ្ឋាន។

-មាត្រា១៣នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក

អ្នកជាប់ពន្ធត្រូវដាក់ពាក្យបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន **គ.វ.ស**។

ពាក្យបណ្តឹងតវ៉ាត្រូវមានព័ត៌មានកម្មវត្ថុ និងមូលហេតុនៃបណ្តឹងជាអាទិ៍ដូចខាងក្រោម៖

---

[4] គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ សរសេរអក្សរកាត់ថា គ.វ.ស

-ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធនៃអ្នកជាប់ពន្ធដែលធ្វើការតវ៉ា

-ព័ត៌មានលម្អិតនៃសេចក្តីសម្រេច ឬវិធានការដែលជាកម្មវត្ថុនៃការតវ៉ា

-ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃការតវ៉ា

-ហេតុផល ឬមូលដ្ឋានគតិយុត្តនៃការតវ៉ា

-កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬអ្នកតំណាងរបស់អ្នកជាប់ពន្ធ

-ឯកសារព័ត៌មានលិខិតយុត្តិការនិងភ័ស្តុតាងចាំបាច់ដែលជាមូលដ្ឋាននៃការតវ៉ា

-ឯកសារ ព័ត៌មាន លិខិតយុត្តិការ និងភ័ស្តុតាងផ្សេងទៀតពាក់ព័ន្ធនឹងការតវ៉ាតាមការកំណត់របស់ **គ.ទ.ស** គំរូនៃពាក្យបណ្តឹងតវ៉ាត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

<u>-មាត្រា១៨នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

ក្នុងករណីពាក្យបណ្តឹងតវ៉ាពុំបំពេញតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះលេខាធិការដ្ឋាន **គ.ទ.ស** ត្រូវស្នើសុំឲ្យអ្នកប្តឹងតវ៉ាបំពេញចំណុចដែលខ្វះខាត។

**គ.ទ.ស** អាចចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងតវ៉ាក្នុងករណីលក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹងតវ៉ាពុំត្រូវបានបំពេញគ្រប់គ្រាន់ដោយអ្នកប្តឹងតវ៉ា។

<u>-មាត្រា១៩នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ាលេខាធិការដ្ឋាន **គ.ទ.ស**[5] ពិនិត្យស្រាវជ្រាវ និងរៀបចំរបាយការណ៍ស្តីពីបណ្តឹងតវ៉ាជូន **គ.ទ.ស** ។

<u>-មាត្រា១៦នៃអនុក្រឹត្យលេខ០០៣ អនក្រ.បក</u>

ការដោះស្រាយវិវាទសារពើពន្ធ អាចឆ្លងកាត់ការសម្រុះសម្រួលជាមុនទៅតាមកម្រិតដូចខាងក្រោម៖

-ក្នុងកម្រិតអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬអគ្គនាយកដ្ឋានពន្ធដារ ការសម្រុះសម្រួលត្រូវសម្រេចដោយអគ្គនាយកនៃសាមីអគ្គនាយកដ្ឋាននីមួយៗ។

-ក្នុងកម្រិត **គ.ទ.ស** ការសម្រុះសម្រួលត្រូវសម្រេចដោយប្រធាន **គ.ទ.ស**។

ការសម្រុះសម្រួលត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពី៣០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងឬក្នុងរយៈពេលសមស្របអាស្រ័យលើទំហំនិងប្រភេទរឿងនីមួយៗ។

---

[5] គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ សរសេរអក្សរកាត់ថា គ.ទ.ស

-<u>មាត្រា១៧នៃអនុក្រឹត្យលេខ២០០៣ អនក្រ.បក</u>

ក្នុងការដោះស្រាយវិវាទ **គ.វ.ស** ពិនិត្យទាំងលើអង្គហេតុ និងអង្គច្បាប់។

ក្នុងករណីចាំបាច់ប្រធាន **គ.វ.ស** អាចសម្រេចឲ្យមានការស្រាវជ្រាវបន្ថែម ឬអធិការកិច្ចលើពាក្យបណ្ដឹងតវ៉ាដើម្បីបញ្ជាក់ ឬប្រមូលព័ត៌មាន ឬភ័ស្ដុតាងបន្ថែមពាក់ព័ន្ធអង្គហេតុ។

-<u>មាត្រា១៨នៃអនុក្រឹត្យលេខ២០០៣ អនក្រ.បក</u>

**គ.វ.ស**[6] ត្រូវពិនិត្យនិងសម្រេចដោះស្រាយបណ្ដឹងតវ៉ា ក្នុងរយៈពេលមិនលើសពី៦០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹង ឬក្នុងរយៈពេលសមស្របអាស្រ័យលើទំហំ និងប្រភេទរឿងនីមួយៗ។

-<u>មាត្រា១៩នៃអនុក្រឹត្យលេខ២០០៣ អនក្រ.បក</u>

ក្នុងករណីមិនពេញចិត្តនិងសេចក្ដីសម្រេចរបស់ **គ.វ.ស** អ្នកជាប់ពន្ធអាចដាក់ពាក្យបណ្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០ ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្ដីពីសេចក្ដីសម្រេចរបស់ **គ.វ.ស** ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បណ្ដឹងរបស់អ្នកជាប់ពន្ធទៅតុលាការពុំមានអនុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចរបស់ **គ.វ.ស** ឡើយ។

-<u>មាត្រា២០នៃអនុក្រឹត្យលេខ២០០៣ អនក្រ.បក</u>

**គ.វ.ស** ត្រូវចាត់តំណាងរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

+**<u>ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ</u>**

<u>(ព្រះរាជក្រម នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២)</u>

**ជំពូកទី១០ ការដោះស្រាយវិវាទ និងបណ្ដឹងតវ៉ា**

**<u>មាត្រា៦២</u>** នៃច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ

សាមីស្ថាប័នអនុវត្តលទ្ធកម្មមានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃនៅដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម។

អ្នកប្ដឹងដែលមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្មអាចប្ដឹងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងដោះស្រាយ។

---

[6] គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ សរសេរអក្សរកាត់ថា គ.វ.ស

បែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងនៅស្ថាប័នអនុវត្តលទ្ធកម្មនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣** នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

+**អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ**

(អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦)

**ជំពូកទី៨ ការប្តឹងតវ៉ា និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម**

-**មាត្រា៣៨** នៃអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ

អ្នកដេញថ្លៃ ឬទីប្រឹក្សា មានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរនៅគ្រប់ដំណាក់កាលនៃដំណើរការធ្វើលទ្ធកម្ម។ ពាក្យប្តឹងតវ៉ានេះ ត្រូវដាក់ជូនសាមីស្ថាប័ន អនុវត្តលទ្ធកម្មដោយបំពេញឈ្មោះ និងចុះហត្ថលេខាលើពាក្យប្តឹងតវ៉ា ហើយត្រូវចម្លងបណ្តឹងនេះបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការពិនិត្យពាក្យប្តឹង និងផ្តល់ចម្លើយក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។

ប្រសិនបើពាក្យប្តឹងតវ៉ាត្រូវបានធ្វើឡើង ក្នុងអំឡុងពេលវាយតម្លៃប្រគល់កិច្ចសន្យាសាមីស្ថាប័នអនុវត្តលទ្ធកម្មត្រូវបញ្ជាក់ថាបានទទួលនិងលើកអង្គសេចក្តីនៃពាក្យប្តឹងតវ៉ានេះ ទៅពិចារណាក្នុងនីតិវិធីវាយតម្លៃ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយទៅនឹងការតវ៉ាភ្លាមៗ បន្ទាប់ពីការប្រគល់កិច្ចសន្យារួចហើយ។ លិខិតឆ្លើយតបនេះត្រូវចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយច្បាប់។

-**មាត្រា៣៩**នៃអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ

អ្នកដេញថ្លៃ ឬទីប្រឹក្សា ដែលមិនពេញចិត្តនឹងចម្លើយរបស់ស្ថាប័នអនុវត្តលទ្ធកម្ម មានសិទ្ធិប្តឹងបន្តថែមក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលស្ថាប័នអនុវត្ត លទ្ធកម្មបានផ្តល់ចម្លើយ និងសុំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ចម្លើយក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃមទួលពាក្យប្តឹងតវ៉ា។

**មាត្រា៤០** នៃអនុក្រឹត្យស្ដីពីលទ្ធកម្មសាធារណៈ

សេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះបណ្ដឹងតវ៉ាជាសេចក្ដីសំរេចចុងក្រោយ។ ប៉ុន្តែសេចក្ដីសំរេចនេះអាចជាកម្មវត្ថុនៃបណ្ដឹងតវ៉ាទៅតុលាការបានក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃចេញសេចក្ដីសម្រេច។

**មាត្រា៤១** នៃអនុក្រឹត្យស្ដីពីលទ្ធកម្មសាធារណៈ

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការសាងសង់ និងទីប្រឹក្សានៅក្រោមកិច្ចសន្យាហិរញ្ញប្បទានសាធារណៈត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈខ្ពស់បំផុតនៅក្នុងអំឡុងពេលជ្រើសរើស និងការអនុវត្តន៍កិច្ចសន្យា។

រាជរដ្ឋាភិបាលមានសិទ្ធិធ្វើអធិការកិច្ច និងពិនិត្យឡើងវិញលើកឯកសារដែលជាប់ពាក់ព័ន្ធនឹងការដេញថ្លៃ សំណើសុំដេញថ្លៃ និងកិច្ចសន្យារបស់អ្នកដេញថ្លៃអ្នកទទួលការអ្នកផ្គត់ផ្គង់ និងទីប្រឹក្សាទាំងអស់។

+**ច្បាប់ស្ដីពីការធានារ៉ាប់រង**

(ព្រះរាជក្រម នស/រកម/០៨១២/០២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១២)

**ជំពូកទី៩ ការផ្សះផ្សាវិវាទ**

**មាត្រា៨៩** នៃច្បាប់ស្ដីពីការធានារ៉ាប់រង

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុន នឹងប្ដឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

**មាត្រា ៩០**_នៃច្បាប់ស្ដីពីការធានារ៉ាប់រង

ក្រោយពីភាគីបានដាក់វិវាទជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសាកសួរភាគីទាំងសងខាង និងព្យាយាមផ្សះផ្សាវិវាទដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលនៃការផ្សះផ្សាវិវាទដោយមានបញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមរបស់ភាគីលើការផ្សះផ្សាវិវាទ។ កំណត់ហេតុផ្សះផ្សាវិវាទត្រូវចុះហត្ថលេខាដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីទាំងសងខាង និងត្រូវចម្លងជូនដល់គ្រប់ភាគីពាក់ព័ន្ធ។

រាល់កិច្ចព្រមព្រៀងផ្សះផ្សាវិវាទដែលបានធ្វើឡើងនៅចំពោះមុខក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវមានអានុភាពអនុវត្តភ្លាម។

**មាត្រា ៩១**-នៃច្បាប់ស្តីពីការធានារ៉ាប់រង

ក្នុងពេលផ្សះផ្សាវិវាទ នៅពេលដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងមានកំហុសហើយសាមីខ្លួនព្រមទទួលស្គាល់កំហុសនោះ រាល់ការទាមទារទាំងឡាយ របស់អ្នកត្រូវបានធានារ៉ាប់រងដែលមានចែងក្នុងលក្ខខណ្ឌទូទៅនៃបណ្ណសន្យារ៉ាប់រង នឹងត្រូវចាត់ទុកជាអសារបង់។

-**មាត្រា ៩២**-នៃច្បាប់ស្តីពីការធានារ៉ាប់រង

ក្នុងករណីដែលគ្មានការសះជានឹងគ្នា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបញ្ជូនកំណត់ហេតុនៃការមិនសះជាទៅកាន់វេទិកាមជ្ឈត្តកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច។អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្មឬបណ្តឹងទៅតុលាការមានសមត្ថកិច្ចមានរយៈពេល ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃដែលភាគីពុំបានសះជានឹងគ្នាបើពុំនោះទេសិទ្ធិប្តឹងនោះនឹងត្រូវបាត់បង់។

អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចត្រូវបានរលត់ដោយស្វ័យប្រវត្តិក្នុងករណីមានការព្រមព្រៀងសះជា នឹងគ្នារវាងគូភាគី និងមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការសះជានោះ។

-**មាត្រា ៩៣**-នៃច្បាប់ស្តីពីការធានារ៉ាប់រង

នីតិវិធីនៃការផ្សះផ្សាវិវាទត្រូវកំណត់ដោយអនុក្រឹត្យ។

**+ក្រសួងកិច្ចការនារី**

**+ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ**
(ព្រះរាជក្រម នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥)

-**មាត្រា១០** នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះមន្ត្រីនៃក្រសួងកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឲ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

-**មាត្រា១១** នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះមន្ត្រីសមត្ថកិច្ចដទៃទៀតរួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាលកងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រូវបានទទួលអំណាចពីច្បាប់នេះដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ។កំណត់ហេតុនេះមានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបានបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ។

-**មាត្រា២៦** នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សា ឬ សម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហាដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-**មាត្រា២៧** នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

អនុលោមលើខ្លឹមសារនៃមាត្រា២៥ ខាងលើ តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សាក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ។ក្នុងការផ្សះផ្សាសម្រុះសម្រួលគ្នាតុលាការត្រូវចៀសវាងធ្វើសម្ពាធលើគូភាគីដែលមិនព្រមចុះស្រុះស្រួលគ្នា ឬបង្ខិតបង្ខំភាគីណាមួយឲ្យចូលផ្សះផ្សា ឬបង្ខិតបង្ខំឲ្យចុះកិច្ចព្រមព្រៀងដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរឡើយ។

-**មាត្រា២៨**នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារ និងការពារសុខុមាលភាពកុមារធ្វើការតាមដានបញ្ហានេះ។ក្នុងករណីធ្ងន់ធ្ងរអាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងទៅតុលាការ។

អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់រួមទាំងព្រះរាជអាជ្ញាផងត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ។

តុលាការអាចផ្តល់អាណត្តិដល់ស្ថាប័នមានសមត្ថកិច្ច ដើម្បីរកជំនួយនិងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារព្រមទាំងការពារសុវត្ថិភាព និងសុខុមាលភាពជនរងគ្រោះពេលតុលាការកំពុងបំពេញនីតិវិធី។

-**មាត្រា៣៥**នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណាដែលចូលជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

-**មាត្រា៣៤**នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ក្រសួង ស្ថាប័នទាំងឡាយរបស់រដ្ឋត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការនានា និងផ្នែកឯកជន ដើម្បីជម្រុញកម្មវិធីផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

មន្ត្រីពាក់ព័ន្ធទាំងឡាយ និងភ្នាក់ងារអង្គការនានាត្រូវបានទទួលការបណ្តុះបណ្តាលអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ និងវិធានការទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះដើម្បីឲ្យយល់ពីមូលហេតុចម្បងនានាដែលបង្កឲ្យមានការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសទាំងឡាយដែលពាក់ព័ន្ធវិស័យនេះ។

-**មាត្រា២១**នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

មានតែតុលាការខេត្ត ក្រុងទេដែលមានសមត្ថកិច្ចចេញដីកាការពារជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិលក្តីជាផ្នែករដ្ឋបាលក្តី ឬជាផ្នែកព្រហ្មទណ្ឌក្តី។

-**មាត្រា២២**នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការអាចធ្វើឡើងដោយ :

១-ជនរងគ្រោះ ឬ តំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ។

២-ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន។

-**មាត្រា២៤** នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ននៅពេលទទួលបណ្តឹងការពារដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ។

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**+ច្បាប់ស្តីពីទូរគមនាគមន៍** (ព្រះរាជក្រម នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥)

-**មាត្រា៧១**នៃច្បាប់ស្តីពីទូរគមនាគមន៍

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ទទួលនីតិសម្បទា ជានគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះដោយអនុវត្តឲ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រី **ក.ប.ទ**[7] ។

[7] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា ក.ប.ទ

-**មាត្រា៧២**នៃច្បាប់ស្តីពីទូរគមនាគមន៍

ក្នុងក្របខណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យនិងការស៊ើបអង្កេតបទល្មើស ដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាងកោះហៅ បុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀតដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យមន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវទទួលការអនុញ្ញាត និងត្រូវស្ថិតនៅក្រោមការដឹកនាំសម្របសម្រួលដោយផ្ទាល់ពីព្រះរាជអាជ្ញា។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសមត្ថកិច្ចអាចស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀតដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

-**មាត្រា៧៣**នៃច្បាប់ស្តីពីទូរគមនាគមន៍

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ។ នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋានសញ្ញាសម្គាល់និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

-**មាត្រា៧៤**នៃច្បាប់ស្តីពីទូរគមនាគមន៍

នៅក្នុងដំណើរការអធិការកិច្ចវិស័យទូរគមនាគមន៍ ក្នុងករណីមានភស្តុតាងជាក់ស្តែង ឬលទ្ធផលវិភាគផ្ទៀងផ្ទាត់បញ្ជាក់ថាសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ណាមួយមានលក្ខណៈបច្ចេកទេសផ្ទុយពីស្តង់ដាដែលត្រូវបានកំណត់នៅក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀតនៅពេលស្នើសុំការចុះបញ្ជី ឬមានប្រតិបត្តិការណាមួយបង្កប់នូវចរិតលក្ខណៈផ្ទុយពីគោលការណ៍នៃការប្រកួតប្រជែងស្របច្បាប់ដែលបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀតមន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសមត្ថកិច្ចចាត់វិធានការផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សេវាការផ្គត់ផ្គង់ការចែកចាយគ្រឿងសម្ភារៈបរិក្ខារ ទូរគមនាគមន៍ និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធ នឹងបទល្មើសដើម្បីដោះស្រាយតាមនីតិវិធី។

**-មាត្រា៧៥** នៃច្បាប់ស្តីពីទូរគមនាគមន៍

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចប្តឹងតវ៉ាក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ នៅ **ក.ប.ទ**[8] គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

រដ្ឋមន្ត្រី **ក.ប.ទ** ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ទ** ជននោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាលឬទៅតុលាការតាមនីតិវិធី។

**-មាត្រា៧៦** នៃច្បាប់ស្តីពីទូរគមនាគមន៍

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញាដើម្បីធ្វើការបំផ្លាញចោលដោយអនុលោមតាមនីតិវិធីជាធរមាន។

ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់នេះគឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស។ ករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបានស្គាល់រាល់ការចំណាយជាបន្ទុករបស់រដ្ឋ។

**-ជំពូកទី១២ ការដោះស្រាយវិវាទនៃច្បាប់ស្តីពីទូរគមនាគមន៍**

**-មាត្រា៦៧** នៃច្បាប់ស្តីពីទូរគមនាគមន៍

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធ នឹងវិស័យទូរគមនាគមន៍ ជាអាទិ៍វិវាទរវាងប្រតិបត្តិករទូរគមនាគមន៍ និងប្រតិបត្តិករទូរគមនាគមន៍ និងរវាងប្រតិបត្តិករទូរគមនាគមន៍ និងអ្នកប្រើប្រាស់ភាគីវិវាទត្រូវដាក់សំណុំរឿងទៅ **ន.ទ.ក**[9] ដើម្បីធ្វើការផ្សះផ្សា។

នីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយ **ក.ប.ទ**[10]។ កម្រៃសេវាសម្រាប់ការដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

---

[8] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា ក.ប.ទ

[9] និយ័តករទូរគមនាគមន៍កម្ពុជា សរសេរកាត់ថា ន.ទ.ក

[10] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា ក.ប.ទ

**មាត្រា៦៨** នៃច្បាប់ស្ដីពីទូរគមនាគមន៍

លទ្ធផលនៃការផ្សះផ្សាត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយ**ន.ទ.ក**។ កំណត់ហេតុនេះត្រូវចុះពីការយល់ព្រមសះជាឬការមិនយល់ព្រមសះជារវាងភាគីវិវាទ និងត្រូវចុះហត្ថលេខាដោយ **ន.ទ.ក** និងភាគីវិវាទទាំងអស់រួចត្រូវចម្លងជូនគ្រប់ភាគីវិវាទ។

ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខ **ន.ទ.ក** មានអានុភាពអនុវត្តក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលបានកំណត់ហេតុសះជា។

ក្នុងករណីពុំព្រមអនុវត្តតាមការព្រមព្រៀងដូចមានក្នុងកំណត់ហេតុសះជា ឬក្នុងករណីពុំមានការយល់ព្រមសះជាភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តការ ឬប្ដឹងទៅតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន។

ដើម្បីទទួលបានគុណវុឌ្ឍិជាមជ្ឈត្តករក្នុងវិស័យទូរគមនាគមន៍មជ្ឈត្តករក្នុងន័យនៃបទប្បញ្ញត្តិស្ដីពីមជ្ឈត្តការពាណិជ្ជកម្មត្រូវទទួលការបណ្ដុះបណ្ដាលបន្ថែមពី **ក.ប.ទ**។ លក្ខខណ្ឌនៃការបណ្ដុះបណ្ដាលនេះត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ** ។

បទប្បញ្ញត្តិនៃមាត្រានេះពុំអនុវត្តចំពោះចំណុច (ង) នៃមាត្រា ៣១នៃច្បាប់នេះទេ។

**មាត្រា៩៣**នៃច្បាប់ស្ដីពីទូរគមនាគមន៍

អំពើគំរាមកំហែងថា នឹងប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្ដងហើយម្ដងទៀត តាមគ្រប់មធ្យោបាយទូរគមនាគមន៍ទោះបីជាបង្ហាញឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្ដីត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែទៅ ៦ (ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០,០០០ (មួយសែន)រៀល ទៅ ១,០០០,០០០ (មួយលាន)រៀល។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារៈ

-ពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០(មួយលាន)រៀល ទៅ៤,០០០,០០០(បួនលាន)រៀល កាលបើអំពើនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ។

-ពី ៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ទៅ៤,០០០,០០០ (បួនលាន)រៀល កាលបើអំពើនេះជាអំពើគំរាមកំហែងថានឹងសម្លាប់។

-ពី១ (មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ (ពីរលាន)រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន)រៀល កាលបើអំពើនេះជាអំពើគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ។

**__មាត្រា៩៥__** នៃច្បាប់ស្តីពីទូរគមនាគមន៍

អំពើគំរាមកំហែងថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម ឬការធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់ជនដទៃ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀតតាមគ្រប់មធ្យោបាយទូរគមនាគមន៍ទោះបីជាបង្ហាញ ឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្តីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ៦ (ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០,០០០ (មួយសែន)រៀល ទៅ ១,០០០,០០០ (មួយលាន)រៀល។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២,០០០,០០០ (ពីរលាន)រៀល ទៅ៤,០០០,០០ (បួនលាន)រៀល កាលបើអំពើគំរាមកំហែងនេះមានភ្ជាប់នូវបញ្ជាឲ្យបំពេញឬមិនបំពេញកិច្ចអ្វីមួយ។

-**__មាត្រា៩៧__** នៃច្បាប់ស្តីពីទូរគមនាគមន៍

ការលបស្តាប់ ឬការលបថតការសន្ទនាដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដោយបុគ្គលដែលពុំមែនជាភាគីនៃការសន្ទនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ១ (មួយ)ឆ្នាំ និងទទួលពិន័យ ជាប្រាក់ពី ១០០,០០០ (មួយសែន)រៀល ទៅ ២,០០០,០០០ (ពីរលាន)រៀល។

បទប្បញ្ញត្តិកថាខណ្ឌទី១ខាងលើនេះមិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលការស្តាប់ ឬការថតការសន្ទនានោះធ្វើឡើងដោយមានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធ ឬដោយមានការអនុញ្ញាតពីអាជ្ញាធរជម្មានុរូប។

ត្រូវផ្តន្ទាទោសដូចគ្នាចំពោះការផ្សព្វផ្សាយខ្លឹមសារនៃការសន្ទនាដោយពុំបានទទួលសិទ្ធិស្របច្បាប់ពីភាគីនៃការសន្ទនា ឬពីអាជ្ញាធរជម្មានុរូប ឬពីបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៩៩** នៃច្បាប់ស្តីពីទូរគមនាគមន៍

ការផលិត ការដំឡើង ឬការចែកចាយដោយគ្មានការអនុញ្ញាតពីអាជ្ញាធរ ជម្មានរូបទូរកម្មវិធីសូហ្វវែរឬឧបករណ៍ស្តាប់ឬថតការសន្ទនាដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០(មួយលាន)រៀល ទៅ៤,០០០,០០០(បួនលាន)រៀល។

**មាត្រា១០១**នៃច្បាប់ស្តីពីទូរគមនាគមន៍

ការយកអត្តសញ្ញាណតតិយជនដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ក្នុងកាលៈទេសៈដែលនាំឲ្យមានឬដែលអាចនាំឲ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី២,០០០,០០០(ពីរលាន)រៀលទៅ៦,០០០,០០០(ប្រាំមួយលាន)រៀល។

**មាត្រា១០៦** នៃច្បាប់ស្តីពីទូរគមនាគមន៍

ចំពោះបទល្មើសប្រព្រឹត្តដោយរូបវន្តបុគ្គលដូចមានចែងក្នុងច្បាប់នេះទោសបន្ថែមមួយ ឬច្រើនដែលមានចែងក្នុងក្រមព្រហ្មទណ្ឌដូចខាងក្រោមនេះអាចត្រូវបានប្រកាស៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ។

៤-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាវត្ថុនៃបទល្មើស។

៧-ការរឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលបំពាក់អទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៩-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

**មាត្រា១០៧** នៃច្បាប់ស្តីពីទូរគមនាគមន៍

អំពើល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលគឺ ជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីប្រយោជន៍របស់នីតិបុគ្គលនោះ។

អង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គលសំដៅដល់អង្គការឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមនីតិបុគ្គលស្របតាមលក្ខន្តិកៈរបស់នីតិបុគ្គលនោះ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលមិនលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនោះទេ។

**មាត្រា១០៨** នៃច្បាប់ស្តីពីទូរគមនាគមន៍

មន្ត្រី **ក.ប.ទ** និង **ន.ទ.ក** ណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរាំងការអនុវត្តច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមានដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**ក្រសួងទេសចរណ៍**

**+ច្បាប់ស្តីពីទេសចរណ៍** (ព្រះរាជក្រម នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩)

**មាត្រា៥៩** នៃច្បាប់ស្តីពីទេសចរណ៍

មន្ត្រីអធិការកិច្ចត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងបណ្ណបេសកកម្ម ឬលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្មមុនចាប់ផ្តើមធ្វើអធិការកិច្ច។ មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវមាននីតិសម្បទាជានគរបាលយុត្តិធម៌។

**មាត្រា៦១**នៃច្បាប់ស្តីពីទេសចរណ៍

ប្រសិនបើមន្ត្រីអធិការកិច្ចឃើញថាមានការរំលោភបទប្បញ្ញត្តិនៃច្បាប់នេះ មន្ត្រីអធិការកិច្ចនោះអាចចាត់វិធានការតាមច្បាប់នេះ និងក្នុងករណីចាំបាច់ត្រូវស្នើសុំឲ្យមានកិច្ចសហការពីសមត្ថកិច្ចពាក់ព័ន្ធ។ បើជាករណីធ្ងន់ធ្ងរត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងទេសចរណ៍ដើម្បីចាត់វិធានការតាមច្បាប់។

ក្នុងករណីដែលពិនិត្យឃើញឬមានហេតុផលជាមូលដ្ឋានអាចជឿជាក់ថាមានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចនោះត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៃតំបន់ពាក់ព័ន្ធនោះ ដើម្បីចាត់វិធានការតាមនីតិវិធីនៃច្បាប់។

**មាត្រា៧២**នៃច្បាប់ស្តីពីទេសចរណ៍

ជនណាដែលបង្កឲ្យមានការប្រព្រឹត្តល្មើសឬការពារអាជីវកម្មទេសចរណ៍ដែលប្រព្រឹត្តរំលោភនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវប្រឈមនឹងទណ្ឌកម្មខាងរដ្ឋបាល ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌនិងសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត។

**មាត្រា៧៣**នៃច្បាប់ស្តីពីទេសចរណ៍

ជនណាដែលបន្លំ ឬបោកបញ្ឆោតក្នុងការលក់ផលិតផល ឬសេវាកម្មទេសចរណ៍ក្លែងក្លាយដល់ភ្ញៀវត្រូវទទួលពិន័យអន្តរការណ៍ដែលមានចំនួនទ្វេដងនៃថ្លៃលក់ផលិតផលឬសេវាកម្មទេសចរណ៍។ប្រសិនបើអំពើនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ក្នុងករណីនេះក្រសួងទេសចរណ៍អាចលុបចោល ឬព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ជំពូកទី៧ ការដោះស្រាយវិវាទទេសចរណ៍** នៃច្បាប់ស្តីពីទេសចរណ៍

**មាត្រា៥៤**នៃច្បាប់ស្តីពីទេសចរណ៍

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតគណៈកម្មការមួយ ហៅថា "**គណៈកម្មការដោះស្រាយវិវាទទេសចរណ៍**" ដើម្បីសម្របសម្រួល ដោះស្រាយវិវាទ និងការប្រតិបត្តិតាមកាតព្វកិច្ចក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវចេញប្រកាសដើម្បីផ្សព្វផ្សាយអំពីប្រភេទនៃវិវាទនានាដែលក្រសួងមានតួនាទីជាអ្នកទទួលដោះស្រាយ។

**មាត្រា៥៥នៃច្បាប់ស្តីពីទេសចរណ៍**

ប្រភេទវិវាទដែលក្រសួងទេសចរណ៍មានតួនាទីជាអ្នកទទួលសម្របសម្រួល និងដោះស្រាយរួមមានវិវាទរវាងប្រតិបត្តិករអាជីវកម្មទេសចរណ៍ ភ្នាក់ងាររបស់គេ និយោជិត អ្នកជាប់កិច្ចសន្យាមន្ត្រីសមត្ថកិច្ចដែលពាក់ព័ន្ធនឹងទេសចរណ៍ និង អ្នកពាក់ព័ន្ធផ្សេងៗទៀត។

គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ត្រូវពិចារណាដោះស្រាយ វិវាទប្រកបដោយយុត្តិធម៌។ប្រសិនបើគណៈកម្មការមិនអាចដោះស្រាយវិវាទនោះ បានទេភាគីណាមួយអាចបន្តរឿងក្តីនោះទៅតុលាការ ដើម្បីរកដោះស្រាយតាម ផ្លូវច្បាប់។

ការចំណាយនិងសោហ៊ុយរបស់គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**+ អង្គភាពប្រឆាំងអំពើពុករលួយ**

**+ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ**(ព្រះរាជក្រម នស/រកម/០៤១០/០០៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥)

**មាត្រា២៣** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការផ្តល់នីតិសម្បទា ចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ

ប្រធាន និងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានគុណសម្បត្តិ ជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់ ដើម្បីបំពេញមុខងាររបស់ខ្លួន។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយអាចទទួលបាននីតិសម្បទាជាមន្ត្រី នគរបាលយុត្តិធម៌ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចរៀបចំបញ្ជីឈ្មោះមន្ត្រី នៃអង្គភាពប្រឆាំងអំពើពុករលួយដែលត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាល យុត្តិធម៌ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា២៤** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ សម្បថ

ប្រធាន អនុប្រធាន និងមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបាន ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្បថថាបំពេញមុខងាររបស់ខ្លួន ដោយស្មោះត្រង់តាមលក្ខខណ្ឌដែលមានចែងនៅក្នុង មាត្រា៦៣ (សម្បថនៃមន្ត្រី នគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២២** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ

ប្រធាន អនុប្រធាន និងមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចស៊ើបអង្កេតលើបទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

អង្គភាពផ្សេងទៀតដែលបានដឹងអំពីបទល្មើសពុករលួយទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌត្រូវប្តឹងទៅអង្គភាព ឬការិយាល័យរាជធានី-ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា២៥** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា អំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេត បទល្មើសពុករលួយដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិនៅក្នុងច្បាប់នេះ។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចស៊ើបអង្កេតបទល្មើសពុករលួយ។ក្នុងករណីស៊ើបអង្កេតបទល្មើសពុករលួយហើយរកឃើញបទល្មើសផ្សេងទៀតដែលមានអង្គហេតុទាក់ទិននឹងបទល្មើសដែលកំពុងស៊ើបអង្កេតមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយអាចធ្វើការស៊ើបអង្កេតបទល្មើសទាំងនោះរហូតដល់ចប់នីតិវិធី។

អង្គភាពប្រឆាំងអំពើពុករលួយមិនអាចចាប់ផ្តើមការស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយបានទេលើកលែងតែមានបញ្ជាពីអាជ្ញាធរតុលាការឲ្យអង្គភាពប្រឆាំងអំពើពុករលួយស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយ។

តុលាការអាចបញ្ជាឲ្យអង្គភាពប្រឆាំងអំពើពុករលួយធ្វើកោសលវិច័យនានាដើម្បីជួយដល់ការវិនិច្ឆ័យរបស់តុលាការ។

នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតទាំងនេះនិងដោយបដិប្បញ្ញត្តិទៅនឹងមាត្រា៨៩ (អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង) មាត្រា៩១ (ការឆែកឆេរ) មាត្រា៩៤ (បទបញ្ជាឲ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង) និងមាត្រា១១៤(ការបញ្ជាឲ្យចូលខ្លួនការស៊ើបអង្កេតបឋម) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រធាន អង្គភាពប្រឆាំងអំពើពុករលួយ ឬតំណាងដែលខ្លួនបានចាត់តាំងយ៉ាងត្រឹមត្រូវមានតួនាទី ដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យបេសកកម្មរបស់មន្ត្រីទាំងនេះជំនួសតួនាទីរបស់ព្រះរាជអាជ្ញា រហូតដល់មានការឃាត់ខ្លួនជនសង្ស័យ។

បន្ទាប់ពីមានការឃាត់ខ្លួនព្រះរាជអាជ្ញាអនុវត្តអំណាចរបស់ខ្លួនដូចបានកំណត់នូវក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅចុងបញ្ចប់នៃការស៊ើបអង្កេតនីមួយៗ អង្គភាពប្រឆាំងអំពើពុករលួយត្រូវបញ្ជូនរាល់កិច្ចនីតិវិធីទាំងអស់ទៅព្រះរាជអាជ្ញា ដើម្បីចាត់ការបន្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២៦**-នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំពីអាជ្ញាធរឋានានុក្រមពាក់ព័ន្ធឲ្យផ្អាកជាបណ្តោះអាសន្ននូវមុខងារនៃបុគ្គលទាំងឡាយណាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជាប់ទាក់ទិននឹងរឿងហេតុនៃបទល្មើសពុករលួយ។

ប្រសិនបើជាជនសង្ស័យរត់គេចខ្លួនទៅបរទេសប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើបត្យាប័នតាមបទប្បញ្ញត្តិជាធរមាន។

អង្គភាពប្រឆាំងអំពើពុករលួយអាចរៀបចំឲ្យមានទីកន្លែងមួយចំនួនជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នសមស្របសម្រាប់ការឃាត់ខ្លួននានាដែលធ្វើឡើងស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ។នៅកន្លែងណាដែលអង្គភាពប្រឆាំងអំពើពុករលួយមិនអាចរៀបចំឲ្យមានទីកន្លែងជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នសមស្របសម្រាប់ការឃាត់ខ្លួនអង្គភាពប្រឆាំងអំពើពុករលួយអាចសុំឲ្យស្ថាប័នមានសមត្ថកិច្ចរក្សាទុកជនដែលត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយឃាត់ខ្លួន។

**មាត្រា២៧** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការតាមដាន

ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា១០៩ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍) និងមាត្រា១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ)នៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងករណីដែលមានតម្រុយជាក់លាក់ថាមានបទល្មើសពុករលួយអង្គភាពប្រឆាំងអំពើពុករលួយអាច ៖

ក- ពិនិត្យ និងដាក់ឲ្យស្ថិតក្រោមការឃ្លាំមើលនូវគណនីធនាគារ ឬគណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ។

ខ- ធ្វើការត្រួតពិនិត្យ និងបង្គាប់ឲ្យផ្តល់ឬថតចម្លងលិខិតយថាភូត ឬលិខិតឯកជន ឬឯកសារធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់។

គ- តាមដាន ឃ្លាំមើល លបស្តាប់ លបថតសំឡេង និងរូបភាព និងដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ និងថត។

ឃ-ចូលទៅពិនិត្យឯកសារនានាព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

ង- រៀបចំប្រតិបត្តិការដែលមានគោលដៅប្រមូលភស្តុតាងជាក់ស្តែង។

វិធានការខាងលើនេះ មិនត្រូវចាត់ទុកថាជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ។ ការសម្ងាត់របស់ធនាគារក៏មិនមែនជាយុត្តិកម្មសម្រាប់បដិសេធមិនផ្តល់ភស្តុតាងពាក់ព័ន្ធនឹងបទល្មើសពុករលួយដែលមានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ។

**មាត្រា២៨** នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យសម្បត្តិរបស់បុគ្គល

តាមការស្នើសុំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយរាជរដ្ឋាភិបាលអាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង បង្កកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងច្បាប់នេះនិងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

ទ្រព្យសម្បត្តិរបស់បុគ្គលដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះរាប់បញ្ចូលទាំងមូលនិធិដែលបានមក ឬបង្កើតបានជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់បុគ្គលនោះ។

**មាត្រា២៩** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើអធិបញ្ញាដល់អាជ្ញាធរសាធារណៈមន្ត្រីរាជការពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ព្រមទាំងបណ្តាអង្គភាពនៃវិស័យឯកជនពាក់ព័ន្ធមានជាអាទិ៍ស្ថាប័នហិរញ្ញវត្ថុ ធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីនៃអង្គភាពក្នុងការងារស៊ើបអង្កេត។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយក៏អាចស្នើសុំការសហការពីស្ថាប័នជាតិ និងអន្តរជាតិក្នុងការធ្វើកោសលវិច័យនានាទាក់ទងនឹងការស៊ើបអង្កេតរបស់ខ្លួនផងដែរ។

**មាត្រា៣០** -នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានចែងថា ការចាប់យក

ការចាប់យកត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**+ច្បាប់ស្តីពីការងារ** (ព្រះរាជក្រម ជស/រកម/០៣៩៧/០១ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧)

**ជំពូកទី១២ ការដោះស្រាយវិវាទការងារ**

**-មាត្រា៣០០ នៃច្បាប់ស្តីពីការងារបានចែងថា**

វិវាទបុគ្គលគឺជាវិវាទដែលកើតមានឡើងរវាងនិយោជកនិងកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ ឬច្រើននាក់តាមរឿងរៀងៗខ្លួនហើយទាក់ទងនឹងការបកស្រាយ ឬការអនុវត្តន៍បទប្បញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទប្បញ្ញត្តិការងារនៃអនុសញ្ញារួមព្រមទាំងច្បាប់បញ្ញត្តិជាធរមានផង។

មុននឹងប្តឹងទៅតុលាការគ្រប់រឿងវិវាទបុគ្គលអាចឲ្យភាគីណាមួយផ្តើមគំនិតនាំយកទៅប្តឹងអធិការការងារនៃខេត្ត ក្រុងខ្លួនឲ្យធ្វើការផ្សះផ្សាជាមុនសិន។

**-មាត្រា៣០១នៃច្បាប់ស្តីពីការងារបានចែងថា**

អធិការការងារ ក្រោយដែលបានទទួលពាក្យបណ្តឹងហើយត្រូវសាកសួរភាគីទាំងសងខាងឲ្យដឹងពីកម្មវត្ថុនៃការវិវាទរួមល្បងផ្សះផ្សាភាគីដោយយកច្បាប់បទបញ្ជា អនុសញ្ញារួម ឬកិច្ចសន្យាការងារម្នាក់ៗជាមូលដ្ឋាន។

ចំពោះបញ្ហានេះ អធិការការងារកំណត់ពេលប្រជុំផ្សះផ្សា ក្នុងរយៈពេលបីសប្តាហ៍យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យប្តឹង។

ភាគីទាំងឡាយអាចឲ្យគេជួយអម ឬឲ្យគេតំណាងខ្លួនបាន។

លទ្ធផលនៃការផ្សះផ្សាត្រូវមានចុះក្នុងកំណត់ហេតុធ្វើដោយអធិការការងារបញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមផ្សះផ្សានៃភាគី។ កំណត់ហេតុត្រូវមានចុះហត្ថលេខាអធិការការងារនិងភាគីទាំងអស់ និងត្រូវចម្លងចែកភាគីផង។

ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខអធិការការងារគឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់។

ក្នុងករណីដែលគ្មានការសះជានឹងគ្នាសាមីភាគីអាចប្តឹងទៅសាលាក្តីមានសមត្ថកិច្ចនៅក្នុងរយៈពេលពីរខែពុំនោះទេសិទ្ធិប្តឹងនេះនឹងត្រូវផុតកំណត់។

## ផ្នែកទី២ ការវិវាទការងាររួម

### ក-ការផ្សះផ្សារ

**-មាត្រា៣០២ នៃច្បាប់ស្តីពីការងារបានចែងថា**

វិវាទការងាររួមគឺជាវិវាទដែលកើតឡើង រវាងនិយោជកម្នាក់ ឬច្រើននាក់នឹងបុគ្គលិករបស់ខ្លួនមួយចំនួនអំពីរឿងល័ក្ខខ័ណ្ឌការងារការប្រើប្រាស់សិទ្ធិដែលប្រគល់ឲ្យអង្គការវិជ្ជាជីវៈការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាសបញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយការវិវាទនេះអាចបណ្តាលឲ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួលឬធ្វើឲ្យខូចសន្តិភាពសង្គម។

**មាត្រា៣០៣នៃច្បាប់ស្តីពីការងារបានចែងថា**

បើក្នុងអនុសញ្ញាគ្មានបានគ្រោងនីតិវិធីសំរាប់ដោះស្រាយទេភាគីត្រូវជូនដំណឹង អំពីវិវាទការងាររួមទៅអធិការការងារនៃខេត្ត ក្រុងខ្លួន។ប៉ុន្តែចំពោះវិវាទការងាររួមដែលភាគីពុំបានឲ្យដំណឹងមកខ្លួនទេនោះអធិការការងារអាចចាត់ការផ្សះផ្សាតាមនីតិវិធីដែលមានបញ្ញត្តិទុកក្រោយពីបានដំណឹងអំពីវិវាទនោះភ្លាម។

**-មាត្រា៣០៤នៃច្បាប់ស្តីពីការងារបានចែងថា**

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារចាត់តាំងផ្សះផ្សាម្នាក់ក្នុងរយៈពេលសែសិបប្រាំបីម៉ោងគិតចាប់ពីពេលបានទទួលពាក្យប្តឹង ឬបានដឹងដោយខ្លួនឯងពីវិវាទការងាររួម។

-មាត្រា៣០៥ នៃច្បាប់ស្ដីពីការងារបានចែងថា

ការផ្សះផ្សា ត្រូវធ្វើក្នុងរយៈពេលដប់ប្រាំថ្ងៃគិតចាប់ពីពេលបានទទួលសេចក្ដីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ ការផ្សះផ្សានេះអាចធ្វើឡើងវិញបានតែតាមសំណូមពររួមនៃភាគីវិវាទ។

-មាត្រា៣០៦ នៃច្បាប់ស្ដីពីការងារបានចែងថា

នៅពេលកំពុងផ្សះផ្សា ភាគីវិវាទត្រូវបញ្ឈប់គ្រប់វិធានការនៃការវិវាទ។ ភាគីទាំងនោះត្រូវតែចូលរួមនៅគ្រប់ពេលប្រជុំដែលអ្នកផ្សះផ្សា បានកោះអញ្ជើញ។ អវត្តមានដែលគ្មានការបញ្ជាក់មូលហេតុត្រឹមត្រូវ ក្នុងពេលប្រជុំណាមួយនៃការដោះស្រាយវិវាទត្រូវទទួលពិន័យដូចមានចែងក្នុងវិធាននៃជំពូកទី១៦។

-មាត្រា៣០៧នៃច្បាប់ស្ដីពីការងារបានចែងថា

ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគីនិងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សាមានតម្លៃនិងអានុភាពដូចគ្នា នឹងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលឲ្យគេតំណាងខ្លួន។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិតពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀងនេះមិនជំទាស់ទាំងចំពោះអង្គការសហជីពនោះទាំងចំពោះកម្មករនិយោជិតដែលឲ្យគេតំណាងខ្លួន។

-មាត្រា៣០៨នៃច្បាប់ស្ដីពីការងារបានចែងថា

បើគ្មានការព្រមព្រៀងនឹងគ្នាទេ អ្នកផ្សះផ្សាត្រូវកត់ត្រាបញ្ជាក់នូវចំណុចទាំងឡាយដែលការផ្សះផ្សាមិនសះជាហើយត្រូវសរសេររបាយការណ៍អំពីវិវាទនេះ។ អ្នកផ្សះផ្សាត្រូវបញ្ជូនសំណុំលិខិតទាំងអស់នោះទៅជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារយ៉ាងយូរបំផុតក្នុងរយៈពេលសែសិបប្រាំបីម៉ោង ក្រោយពេលបញ្ចប់ការផ្សះផ្សា។

## ខ-ការសំរេចនៃអាជ្ញាកណ្ដាល

-មាត្រា៣០៩នៃច្បាប់ស្ដីពីការងារបានចែងថា

ក្នុងករណីដែលការផ្សះផ្សាពុំបានសះជាវិវាទការងារត្រូវដាក់ឲ្យដោះស្រាយតាម៖

ក-ឬមួយនីតិវិធីដែលមានចែងក្នុងអនុសញ្ញារួមអំពីអាជ្ញាកណ្ដាលប្រសិនបើមាន

ខ-ឬមួយនីតិវិធីផ្សេងទៀត ដែលមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ

គ-ឬមួយក៏នីតិវិធីអំពីអាជ្ញាកណ្ដាលដែលមានចែងក្នុងផ្នែកនេះ។

**-មាត្រា៣១០នៃច្បាប់ស្តីពីការងារបានចែងថា**

ចំពោះករណីដែលមានចែងក្នុង *កថាខ័ណ្ឌ"គ" នៃមាត្រា៣០៩* ខាងលើ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារត្រូវប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេល បីថ្ងៃក្រោយពីបានទទួលរបាយការណ៍ដែលមានចែងក្នុង *មាត្រា៣០៨* ខាងលើ ពីអ្នកផ្សះផ្សា។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវធ្វើការរួមប្រជុំជាដាច់ខាតក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីបានទទួលបណ្តឹង។

**-មាត្រា៣១១នៃច្បាប់ស្តីពីការងារបានចែងថា**

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជ្រើសរើសក្នុងចំណោមចៅក្រម សមាជិកនៃគណៈកម្មការប្រឹក្សាការងារហើយនិងជាទូទៅបណ្តាឥស្សរជនដែលគេស្គាល់ថាមានគុណសម្បត្តិខាងផ្លូវចរិយា និងមានសមត្ថភាពខាងសេដ្ឋកិច្ច និងសង្គមកិច្ចហើយមាននាមក្នុងបញ្ជីតែងតាំងរៀងរាល់ឆ្នាំ ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

**-មាត្រា៣១២ នៃច្បាប់ស្តីពីការងារបានចែងថា**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានការកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ ចំពោះការវិវាទដែលទាក់ទង និងការបកស្រាយ និងការអនុវត្តន៍បញ្ញត្តិច្បាប់ឬអនុសញ្ញារួមណាមួយ។ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ច នៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតបានគ្រប់យ៉ាងនៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗព្រមទាំងអាចមានអំណាចចាត់ឲ្យភាគីជូនឯកសារឬព័ត៌មានខាងសេដ្ឋកិច្ចគណនេយ្យ ស្ថិតិហិរញ្ញវត្ថុ ឬរដ្ឋបាលដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មខ្លួន។ ក្រុមប្រឹក្សានេះអាចសុំឲ្យអ្នកជំនាញការជួយបានទៀតផង។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និងឯកសារទាំងឡាយដែលគេបានជូនមកឲ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មខ្លួន។

ការរួមប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែប្រព្រឹត្តទៅដោយបិទទ្វារ។

-**<u>មាត្រា៣១៣នៃច្បាប់ស្តីពីការងារបានចែងថា</u>**

ក្នុងរយៈពេលដប់ប្រាំថ្ងៃរាប់ពីថ្ងៃ ដែលខ្លួនបានទទួលសំណុំរឿងក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបញ្ជូនសេចក្តីសំរេចរបស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារហើយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារចាត់ការឲ្យដំណឹងទៅភាគីភ្លាម។ភាគីមានសិទ្ធិប្តឹងជំទាស់នឹងដំណោះស្រាយរបស់អាជ្ញាកណ្តាលនេះដោយជូនដំណឹង ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារតាមសំបុត្រអនុសិដ្ឋ ឬតាមមធ្យោបាយដែលទុកជាបានការផ្សេងទៀតក្នុងរយៈពេលប្រាំបីថ្ងៃពេញចាប់ពីថ្ងៃទទួលដំណឹង។

-**<u>មាត្រា៣១៤នៃច្បាប់ស្តីពីការងារបានចែងថា</u>**

សេចក្តីសន្និដ្ឋាននៃដំណោះស្រាយរបស់អាជ្ញាកណ្តាលដែលគ្មានភាគីណាប្តឹងជំទាស់ទេអាចយកទៅអនុវត្តបានភ្លាម។

ដំណោះស្រាយរបស់អាជ្ញាកណ្តាល ដែលអាចយកទៅអនុវត្តបានហើយត្រូវតំកល់ទុកនិងចុះបញ្ជិកាទៅតាមបែបបទដូចគ្នានិងអនុសញ្ញារួមដែរ។

-**<u>មាត្រា៣១៥នៃច្បាប់ស្តីពីការងារបានចែងថា</u>**

កំណត់ហេតុព្រមព្រៀងសះជានិងដំណោះស្រាយរបស់អាជ្ញាកណ្តាលដែលគ្មាននរណាប្តឹងជំទាស់ទេនោះត្រូវបិទផ្សាយក្នុងទីស្ថានទាំងឡាយនៃសហគ្រាសដែលមានកើតវិវាទ និងក្នុងការិយាល័យនៃអធិការដ្ឋានការងារនៃខេត្ត ក្រុង។

-**<u>មាត្រា៣១៦នៃច្បាប់ស្តីពីការងារបានចែងថា</u>**

នីតិវិធីនៃការផ្សះផ្សា និងអាជ្ញាកណ្តាល ត្រូវធ្វើដោយឥតគិតថ្លៃ។

**<u>ក្រសួងមុខងារសាធារណៈ</u>**

**+ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិ**

នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសាឆ្នាំ២០១៦

**+ជំពូកទី១៧ អំពីការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ**

-**<u>មាត្រា៦៧</u>** នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បានចែងថា

ក្រសួងមុខងារសាធារណៈតាមរយៈគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈជាស្ថាប័នមានសមត្ថកិច្ចក្នុងការពិនិត្យនិងដោះស្រាយរាល់ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្រោមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៦៨** នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បានចែងថា

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការអំពីករណីដែលពាក់ព័ន្ធទៅនឹងមុខងារសាធារណៈថ្នាក់ក្រោមជាតិ។ ប៉ុន្តែជាការចាំបាច់បុគ្គលិកនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន។

នៅដំណាក់កាលដំបូងសមត្ថកិច្ចដោះស្រាយទំនាស់ខាងលើនេះត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថាគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ។

-**មាត្រា៦៩** នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បានចែងថា

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ មានសមាសភាពដូចខាងក្រោម ៖

-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ប្រធាន

-តំណាងក្រុមប្រឹក្សារាជធានី ខេត្ត សមាជិក

-នាយករដ្ឋបាលរាជធានី ខេត្ត សមាជិក

-ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត សមាជិកអចិន្ត្រៃយ៍

-បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្របខណ្ឌជាមួយគ្នាចំនួន២(ពីរ)នាក់ ដែលមានឋានន្តរស័ក្តិខ្ពស់ជាងឬមានអតីតភាពការងារចាស់ជាង ក្នុងថ្នាក់ស្មើគ្នា សមាជិក

-ប្រធានការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្សនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត លេខាធិការ

បែបបទនិងនីតិវិធីក្នុងការដោះស្រាយវិវាទមុខងារសាធារណៈនឹងត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ។

**មាត្រា៧០** នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ បានចែងថា

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិមានសមត្ថកិច្ចទទួលដោះស្រាយ និងសម្រុះសម្រួលរាល់ទំនាស់ពាក់ព័ន្ធកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិនៅកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវដាក់ពាក្យបណ្តឹងនៅមុខមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដែលសាមីជនកំពុងបំពេញការងារ។

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ ត្រូវដោះស្រាយពាក្យបណ្តឹងនេះក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប) ថ្ងៃ ក្រោយពីពាក្យបណ្តឹងត្រូវបានដាក់នៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

ក្នុងករណីពុំមានដំណោះស្រាយក្នុងរយៈពេលកំណត់ខាងលើ ឬសាមីជនមិនឯកភាពចំពោះដំណោះស្រាយរបស់គណៈកម្មាធិការ សាមីជនអាចដាក់ពាក្យបណ្តឹងបន្តទៅគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធ នឹងកិច្ចការមុខងារសាធារណៈនៅក្រសួងមុខងារសាធារណៈ។

**ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**

**+ច្បាប់ស្តីពីអសុរាមិករណ៍** ( នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០)

**ជំពូកទី៦ ការដោះស្រាយទំនាស់**

**មាត្រា ៣២**_នៃច្បាប់ស្តីពីអស្សាមិករណ៍

គណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាមានសមត្ថកិច្ចទទួលពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា។

**មាត្រា ៣៣**_នៃច្បាប់ស្តីពីអស្សាមិករណ៍

ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។

**មាត្រា ៣៤**_នៃច្បាប់ស្តីពីអស្សាមិករណ៍

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌។

បែបបទ និងនីតិវិធីត្រូវកំណត់ដោយអនុក្រឹត្យ។

**<u>សហជីព</u>**

+**<u>ច្បាប់ស្តីពីសហជីព</u>** (នស/រកម/០៤១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦)

**<u>ជំពូកទី១៤</u> ការដោះស្រាយវិវាទរបស់សហជីព ឬសមាគមនិយោជក**

**<u>មាត្រា ៧៥</u>_ ការដោះស្រាយវិវាទរបស់សហជីព ឬសមាគមនិយោជក**

*វិវាទដែលកើតឡើងរវាងសហជីពមួយ និងសហជីពមួយទៀតត្រូវដោះស្រាយតាមរយៈការសម្របសម្រួល និងការយោគយល់គ្នាឲ្យអស់ពីលទ្ធភាពដោយសហជីពពាក់ព័ន្ធនៅក្នុងវិវាទនោះ និងដោយក្រុមប្រឹក្សាជាតិសហជីព។*

*វិវាទដែលកើតឡើងរវាងសមាគមនិយោជកមួយ និងសមាគមនិយោជកមួយទៀតព្រមទាំងវិវាទដែលកើតឡើងរវាងសហជីពឬក្រុមប្រឹក្សាជាតិសហជីព និងសមាគមនិយោជកឬសហព័ន្ធនិយោជកក៏ត្រូវដោះស្រាយតាមរយៈការពិភាក្សាឲ្យអស់ពីលទ្ធភាពដោយរក្សាឲ្យបាននូវសេវាអប្បបរមា សេវាជាសារវន្ត និងសណ្តាប់ធ្នាប់សាធារណៈ។*

*ប្រសិនបើការពិភាក្សាដូចមានចែងនៅក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២នៃមាត្រានេះមិនបានឈានដល់ការព្រមព្រៀងគ្នាទេ វិវាទត្រូវដោះស្រាយទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។*

**ជំពូកទី៧ សិទ្ធិ និងករណីយកិច្ចរបស់សហជីព**

**<u>មាត្រា ៥១</u>_ គោលការណ៍នៃភាពសុចរិត និងស្មោះត្រង់**

*សហជីពមានករណីយកិច្ចចូលរួមជាមួយនិយោជកប្រកបដោយភាពស្មោះត្រង់ក្នុងគោលបំណងតំណាងឲ្យផលប្រយោជន៍សមាជិករបស់ខ្លួនក្នុងការកំណត់ប្រការផ្សេងៗ និងលក្ខខណ្ឌការងារហើយធានាឲ្យមានការគោរពប្រការផ្សេងៗទាំងនោះលក្ខខណ្ឌដែលបានព្រមព្រៀងនិងសិទ្ធិស្របច្បាប់ទាំងឡាយ។ ករណីយកិច្ចតម្រូវឲ្យមានភាពស្មោះត្រង់នេះរាប់បញ្ចូលទាំងករណីយកិច្ចជួបជាមួយនិយោជកនិងការចូលរួមប្រជុំឲ្យបានទាន់ពេល និងឲ្យបានញឹកញាប់សម្រាប់គោលបំណងនៃការពិភាក្សាដើម្បីដោះស្រាយបញ្ហា ឬចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមទាក់ទងនឹងប្រការផ្សេងៗ និងលក្ខខណ្ឌការងារស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក៏ដូចជាការពិចារណាទៅលើសំណើសម្រាប់ដោះស្រាយបណ្តឹងតវ៉ាឬសំណួរទាំងឡាយដែលកើតចេញពីកិច្ចព្រមព្រៀង។ករណីយកិច្ចនេះរាប់បញ្ចូលនូវករណីយកិច្ចធ្វើការសម្របសម្រួល ឬធ្វើការជំទាស់ដែលមានការពិចារណាសមស្របប្រសិនបើមានការស្នើសុំពីភាគីណាមួយនោះ។*

## ជំពូកទី៨
## ករណីយកិច្ចរបស់និយោជក និងសមាគមនិយោជក

### មាត្រា ៥២.- បញ្ជីឈ្មោះកម្មករនិយោជិតសម្រាប់សុំភាពជាតំណាងបំផុត

និយោជកត្រូវរក្សាទុក និងធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះកម្មករ និយោជិតប្រចាំខែ ដែលមានបញ្ជាក់ឈ្មោះ ស្ថានភាពកិច្ចសន្យាការងារ និងចំណាត់ថ្នាក់ការងារសម្រាប់ការត្រួតពិនិត្យភ្លាមៗ ក្នុងករណីដែលសហជីពសុំបញ្ជាក់ភាពជាតំណាងបំផុត។ បែបបទអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

### មាត្រា ៥៣.- គោលការណ៍នៃភាពសុចរិត និងស្មោះត្រង់

សមាគមនិយោជក និងនិយោជកទាំងអស់ មានករណីយកិច្ចចូលរួមចរចារដោយស្មោះត្រង់ជាមួយសហជីព និងតំណាងស្របច្បាប់របស់សហជីព ក្នុងគោលបំណងតំណាងឲ្យផលប្រយោជន៍របស់សមាជិកខ្លួនទទួលយកនូវការគោរពទៅលើប្រការផ្សេងៗ លក្ខខណ្ឌដែលបានព្រមព្រៀង និងសិទ្ធិស្របច្បាប់ទាំងឡាយ។

ករណីយកិច្ចតម្រូវឲ្យមានភាពស្មោះត្រង់នេះរាប់បញ្ចូលទាំងករណីយកិច្ចដែលជាប់ទាក់ទងនឹងសហជីពដែលត្រូវបានបញ្ជាក់ថាមានភាពជាតំណាងបំផុតដើម្បីជួបនិងកោះប្រជុំឲ្យបានទាន់ពេល និងឲ្យបានញាប់សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួមទាក់ទងនឹងប្រការផ្សេងៗ និងលក្ខខណ្ឌការងារស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ក៏ដូចជាការពិចារណាទៅលើសំណើសម្រាប់ដោះស្រាយបណ្តឹងតវ៉ា ឬសំណួរទាំងឡាយដែលកើតចេញពីកិច្ចព្រមព្រៀង។ ករណីកិច្ចនេះមានលើសពីកិច្ចប្រជុំនិងការពិគ្រោះយោបល់ជាធម្មតាហើយរាប់បញ្ចូលទាំងការផ្តល់ឲ្យសហជីពដែលមានភាពជាតំណាងបំផុតនូវលក្ខណៈងាយស្រួលទាំងឡាយដើម្បីធ្វើការចរចាផ្តល់នូវព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងការចរចាដែលបានស្នើឡើងដោយសហជីព និងការអនុវត្តកិច្ចសន្យា ឬអនុស្សរណៈនៃការយោគយល់គ្នាជាលាយលក្ខណ៍អក្សរដោយដាក់បញ្ចូលនូវកិច្ចព្រមព្រៀងទាំងនេះ ប្រសិនបើមានការស្នើសុំពីភាគីណាមួយ ប៉ុន្តែមិនតម្រូវឲ្យនិយោជក ឬសមាគមនិយោជកមានករណីយកិច្ចយល់ព្រមទៅ នឹងសំណើជាក់លាក់ណាមួយដែលស្នើឡើងដោយសហជីពឡើយ។

ភាគីទាំងពីរនៃការចរចា ត្រូវគោរពតាមគោលការណ៍នៃភាពសុចរិត និងស្មោះត្រង់។

# ជំពូកទី១០
# ការអនុវត្តមិនត្រឹមត្រូវដោយនិយោជក

## មាត្រា ៦២._ការមិនរើសអើងដោយសារតែសកម្មភាពរបស់សហជីព

និយោជកមិនត្រូវរើសអើងដោយយកលេសអំពីការជាប់ទាក់ទង នឹងការកាន់តំណែងជាថ្នាក់ដឹកនាំរបស់សហជីព ឬការចូលរួមរបស់កម្មករ និយោជិតក្នុងសកម្មភាពសហជីពដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឲ្យចូលធ្វើការ ការដឹកនាំ ការបែងចែកការងារ ការដំឡើងតួនាទី មុខតំណែង ការផ្តល់ប្រាក់ឈ្នួល ការផ្តល់អត្ថប្រយោជន៍វិធានការដាក់វិន័យនិងការបញ្ចប់កិច្ចសន្យាការងារដែលរួមបញ្ចូលទាំងការបញ្ឈប់ ឬការមិនបន្តកិច្ចសន្យាការងារដែលមានជាបន្តគ្នាដោយខុសនីតិវិធី។

## មាត្រា៦៣._សកម្មភាពរបស់និយោជកដែលចាត់ទុកជាអនុវត្តមិនត្រឹមត្រូវ

ការអនុវត្តមិនត្រឹមត្រូវរបស់និយោជកដូចខាងក្រោមត្រូវចាត់ទុកថាខុសច្បាប់ ៖

ក-ធ្វើការជ្រៀតជ្រែកតាមវិធីណាមួយជាមួយនឹងកម្មករ និយោជិតនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីរៀបចំសហជីពដោយខ្លួនឯង

ខ-ដាក់ចេញនូវលក្ខខណ្ឌការងារ ឬការបន្តធ្វើការងារដែលតម្រូវឲ្យបុគ្គលនោះមិនត្រូវចូលរួមក្នុងសហជីពឬដកខ្លួនចេញពីសហជីពដែលខ្លួនជាសមាជិក

គ-ធ្វើកិច្ចសន្យានូវសេវាកម្ម ឬមុខងារដែលបំពេញដោយសមាជិករបស់សហជីពនៅពេលដែលការធ្វើបែបនេះអាចជ្រៀតជ្រែកទៅដល់សិទ្ធិរបស់កម្មករ និយោជិតនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីរៀបចំសហជីពដោយខ្លួនឯង

ឃ-ផ្តួចផ្តើមគំនិតត្រួតត្រា ជាអាទិ៍ជួយជ្រោមជ្រែង ឬជ្រៀតជ្រែកដល់ការបង្កើត ឬការគ្រប់គ្រងផ្នែករដ្ឋបាលរបស់សហជីពណាមួយ ឬការរួបរួមគ្នានៃសហជីពទាំងឡាយ រួមមានទាំងការផ្តល់ហិរញ្ញវត្ថុ ឬការឧបត្ថម្ភគាំទ្រដល់សហជីពនោះ ឬស្ថាបនិកនៃសហជីពនោះ ឬអ្នកគាំទ្រទាំងឡាយក្នុងវិធីណាក៏ដោយក្រៅពីអ្វីដែលមានចែងនៅក្នុងច្បាប់នេះ

ង-ធ្វើការរើសអើងទាក់ទិននឹងប្រាក់ឈ្នួល ម៉ោងធ្វើការ ប្រការផ្សេងៗ និងលក្ខខណ្ឌការងារផ្សេងៗទៀត ដើម្បីលើកទឹកចិត្ត ឬមិនលើកទឹកចិត្តឲ្យចូលជាសមាជិកនៃសហជីពណាមួយ

ច-បណ្តេញចេញ បញ្ឈប់ ឬធ្វើបុរេនិច្ឆ័យ ឬក៏រើសអើងប្រឆាំងនឹងកម្មករនិយោជិតដែលបានផ្តល់ឬដែលនឹងផ្តល់កសិណសាក្សីផ្តល់ភស្តុតាង ឬព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់នេះ ឬបទដ្ឋានការងារផ្សេងៗទៀតជាធរមាន

ឆ-រំលោភករណីយកិច្ចចរចារអនុសញ្ញារួមដូចមានចែងនៅក្នុងច្បាប់នេះ ឬរំលោកបំពាន ឬបង្កឲ្យមានការរំលោកបំពានលើលក្ខន្តិកៈ កិច្ចសន្យាការងារ អនុស្សរណៈនៃការយោគយល់គ្នាកិច្ចព្រមព្រៀង អនុសញ្ញារួម ឬបទប្បញ្ញត្តិច្បាប់ ឬរារាំងដំណើរការចរចារ និងអនុវត្តអនុសញ្ញារួម

ជ-ឡុកអៅខុសនីតិវិធីដែលកំណត់ដោយច្បាប់

ឈ-រារាំងខ្ទប់ទ្វារអាគារសហគ្រាស ឬគ្រឹះស្ថាន ឬច្រកចេញចូលដោយមធ្យោបាយផ្សេងៗ ឬរារាំងតាមរយៈការគំរាមកំហែង ការបង្កឲ្យមានហិង្សាមកលើកម្មករនិយោជិតដែលបានចូលរួម ឬមានបំណងចូលរួមធ្វើកូដកម្ម

ញ-មិនបានបំពេញបញ្ចប់កាតព្វកិច្ចទាំងឡាយដែលពាក់ព័ន្ធក្នុងវិស័យការងារនៅពេលបិទលែងដំណើរការសហគ្រាស ឬគ្រឹះស្ថាន។

## ជំពូកទី១១

## ការអនុវត្តមិនត្រឹមត្រូវដោយសហជីព

### មាត្រា ៦៤_ ការរើសអើងសមាជិកភាព

ត្រូវចាត់ទុកថាជាការអនុវត្តមិនត្រឹមត្រូវរបស់បុគ្គលិក កម្មករ និយោជិតសហជីព ឬតំណាងរបស់សហជីពចំពោះការបដិសេធនូវសមាជិកភាពដូចមានចែងនៅក្នុងមាត្រា៦ (ការមិនរើសអើងនៅក្នុងសមាជិកភាព) នៃច្បាប់នេះ។

### មាត្រា៦៥_ សកម្មភាពរបស់សហជីពដែលចាត់ទុកថាអនុវត្តមិនត្រឹមត្រូវ

ការអនុវត្តដូចខាងក្រោមរបស់សហជីព ឬតំណាងរបស់សហជីពត្រូវចាត់ទុកថាខុសច្បាប់៖

ក-ដាក់កម្រិត ឬបង្ខិតបង្ខំកម្មករនិយោជិតក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការរៀបចំសហជីពដោយខ្លួនឯង។ ទោះបីជាយ៉ាងណាក៏ដោយក៏សហជីពត្រូវមានសិទ្ធិកំណត់ចេញនូវវិធានរបស់ខ្លួននៅក្នុងការជ្រើសរើស ឬការរក្សាទុកនូវសមាជិកភាព

ខ-បង្ខំឬព្យាយាមធ្វើឲ្យនិយោជករើសអើងប្រឆាំងទៅនឹងកម្មករ និយោជិត រួមទាំងការបញ្ឈប់កម្មករ និយោជិតមិនត្រឹមត្រូវតាមច្បាប់ និងលក្ខខណ្ឌធម្មតា ដូចជាយកហេតុផលថាសាមីកម្មករ និយោជិតនោះបដិសេធចូលជា ឬស្នើសុំចេញពីសមាជិកសហជីពខ្លួនជាដើម

គ-រំលោភករណីយកិច្ចនៃភាពសុចរិត និងស្មោះត្រង់ក្នុងការចរចាអនុសញ្ញារួមក្នុងលក្ខខណ្ឌដែលសហជីពនោះមានភាពជាតំណាងបំផុត

ឃ-បង្ករឿង ឬព្យាយាមធ្វើឲ្យនិយោជកបង់ប្រាក់ ឬប្រគល់ ឬយល់ព្រមបង់ប្រាក់ ឬប្រគល់ប្រាក់ ក្នុងចំនួនណាមួយ ឬជាវត្ថុអ្វីមួយផ្សេងទៀតសម្រាប់សេវាកម្មដែលមិនត្រូវបានបំពេញឬមិនបានបំពេញរាប់បញ្ចូលទាំងការទាមទារប្រាក់សេវាសម្រាប់ការចរចារបស់សហជីព

ង-រំលោភបំពាន ឬបង្កឲ្យមានការរំលោភបំពានលើលក្ខន្តិកៈ កិច្ចសន្យាការងារអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង អនុសញ្ញារួម ឬបទប្បញ្ញត្តិច្បាប់ឬរាំងដំណើរការចរចារ និងអនុវត្តអនុសញ្ញារួម

ច-បង្ករឿងសម្រាប់តែគោលបំណងបម្រើឲ្យនិន្នាការនយោបាយឬមហិច្ឆតាផ្ទាល់ខ្លួន ឬប្រព្រឹត្តអំពើហិង្សានៅកន្លែងការងារ និងកន្លែងដទៃទៀត

ឆ-ធ្វើឲ្យកកស្ទះ ឬធ្វើការរាំងខ្ទប់ផ្លូវចូល និងផ្លូវចេញពីបរិវេណសហគ្រាស ឬគ្រឹះស្ថាន ឬញុះញង់អុចអាល ឬគំរាមកំហែង ឬទប់ស្កាត់ដោយហិង្សា ឬបង្ខិតបង្ខំកម្មករ និយោជិតដែលពុំមែនជាកូដករតាមគ្រប់មធ្យោបាយមិនឲ្យធ្វើការ និងបិទផ្លូវសាធារណៈ

ជ-ដឹកនាំធ្វើកូដកម្ម ឬបាតុកម្មដែលផ្ទុយនឹងនីតិវិធីច្បាប់

ឈ-បំផ្លិចបំផ្លាញទ្រព្យសម្បត្តិបុគ្គល ឬសមូហភាព ឬសាធារណៈ។

**<u>មាត្រា ៩៨</u>**.- ជំពូកទី១៦ នៃច្បាប់ស្តីពីសហជីពចែងថា **តុលាការការងារ**

នៅពេលមិនទាន់បង្កើតតុលាការការងាររាល់វិវាទដែលកើតឡើងចំពោះការអនុវត្តច្បាប់នេះ ត្រូវទុកជូនតុលាការអាជ្ញាគតិដោះស្រាយ។

*** *** ***

## សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

+**ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល** (នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥)

-**មាត្រា២៤** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

-**មាត្រា២៥** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់មិនឲ្យហួសពីដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់។ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយព្រមទាំងឯកសារគម្រោងកម្មវិធីការងារនិងកិច្ចព្រមព្រៀងហិរញ្ញប្បទាន១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រមដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ។

ក្នុងករណីចាំបាច់ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម។

អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំមួយច្បាប់ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។

ក្នុងករណីចាំបាច់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យនិងធ្វើសវនកម្មលើសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

**មាត្រា៣០** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា១០ ឬមាត្រា២៤ ឬកថាខណ្ឌទី១ ឬកថាខណ្ឌទី២ នៃមាត្រា២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជាបណ្តោះអាសន្ន រយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្អាកសកម្មភាពជាបណ្តោះអាសន្នដោយទុករយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តក្រសួងមហាផ្ទៃ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។

ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជាដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា៣១** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជីការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេច។

**មាត្រា៣២**នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ក្នុងករណីមិនរាងចាលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវពិន័យជាប្រាក់ពី ៥,០០០,០០០ (ប្រាំលាន)រៀល ទៅ ១០,០០០,០០០ (ដប់លាន)រៀល ដោយក្រសួងមហាផ្ទៃ។ក្នុងករណីនៅតែបន្តធ្វើសកម្មភាពបន្តទៀតអាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការដើម្បីចាត់វិធានការ តាមច្បាប់ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៣** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា១៧ ឬមាត្រា២៤ ឬកថាខណ្ឌទី៣ នៃមាត្រា២៥ នៃច្បាប់នេះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រត្តិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមានក្រសួងការបរទេស និងសហប្រត្តិបត្តិការអន្តរជាតិត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ។

**មាត្រា៣៤** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបន្ថែមទាក់ទងនឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើការងារនៅក្នុងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលប្រព្រឹត្តល្មើសខាងលើដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**<u>មាត្រា៣៥</u>**នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសអនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា។

**<u>មាត្រា៣៦</u>**នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀតត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

***      ***      ***

## VI-គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

( យោងតាមផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិឃុំមានសុវត្ថិភាព" ផែនការណែនាំលេខ០៤២ ជ.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ជំនួសឲ្យផែនការណែនាំលេខ០២០ ជ.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០)

ភូមិ ឃុំ មានសុវត្ថិភាពគឺភូមិ ឃុំ ដែលមានលក្ខណៈសម្បត្តិ ៩យ៉ាង ដូចខាងក្រោម:

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។

៣-គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហឹង្សាក្នុងគ្រួសារ។

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

៦-គ្មានគ្រោះថ្នាក់ចរាចរណ៍។

៧-គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨-មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព

៩-គ្មានការត្រួតពិនិត្យខុសច្បាប់។

# ព្រឹទ្ធសភា នីតិកាលទី៣
# គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា
(ហៅកាត់ថា គណៈកម្មការទី៦ ព្រឹទ្ធសភា)

## I.គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

១-ឯកឧត្តម **អ៊ុក ម៉ុនឈឿន** ប្រធានគណៈកម្មការ

២-ឯកឧត្តម **ជា សុន** អនុប្រធានគណៈកម្មការ

៣-ឯកឧត្តម **ថុង ចន់** លេខាធិការគណៈកម្មការ

៤-ឯកឧត្តម **ហេង បូរ៉ា** សមាជិកគណៈកម្មការ

៥-ឯកឧត្តម **ជុំ ទង** សមាជិកគណៈកម្មការ

## II.ជំនួយការឯកទេសជាន់ខ្ពស់អមប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា

១-លោក **គង់ សារិទ្ធ** ជំនួយការឯកទេសជាន់ខ្ពស់អមប្រធានគណៈកម្មការទី៦ ព្រឹទ្ធសភា

## III.លេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា

១-លោក **នៃ នីន** ប្រធានលេខាធិការដ្ឋាន

២-លោក **អ៊ុក រិទ្ធី** អនុប្រធានលេខាធិការដ្ឋាន

៣-លោកស្រី **ជី តេង** អនុប្រធានលេខាធិការដ្ឋាន

៤-លោក **លី វិសាល** មន្ត្រីលេខាធិការដ្ឋាន

៥-លោក **សុខ សម្ផស្ស** មន្ត្រីលេខាធិការដ្ឋាន

៦-លោកស្រី **ជី សុភា** មន្ត្រីលេខាធិការដ្ឋាន

៧-លោកស្រី **យស់ ច័ន្ទរដ្ឋា** មន្ត្រីលេខាធិការដ្ឋាន